ព្រះរាជាណាចក្រ កម្ពុជា

ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ

# ទស្សនាវដ្តីគ្រូបង្រៀន

ព្រលឹងខ្មែរ

ខែ វិច្ឆិកា ១៩៦៣

ឆ្នាំទី ១៧

លេខ ៣

ផ្សាយចេញរាល់ខែ

**ពិទីចាត់ការគរុកោសល្យ**

២៧០ មហាវិថីព្រះបាទមុនីវង្ស (ភ្នំពេញ)



CA39

ការហត្ថកម្មនៅសាលារៀនពោធិចិនតុង

ព្រះរាជាណាចក្រកម្ពុជា

ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង វិចិត្រសិល្បៈ

ឆ្នាំ ទី ១៧ លេខ ៣ ខែវិច្ឆិកា គ.ស. ១៩៦៣

ទស្សនាវដ្ដីគ្រូបង្រៀនខ្មែរ

# មាតិការឿង

ទំព័រ


## ១ – សមាគមបុគ្គលិកសិក្សាខ្មែរ :

– លក្ខន្តិកសមាគមបុគ្គលិកសិក្សាខ្មែរ « គ »

– ជំពូកទី ៣ ការគ្រប់គ្រង . . . . . . . . . ៧

## ២ – ផ្នែកកិច្ចការរាជការ :

– លំហែយ៉ាំងយូរ . . . . . . . . . . ១៣

– លំហែពិសេស . . . . . . . . . . ១៤

– លំហែនៅពេលសំរាលកូន . . . . . . . . ១៥

– ការដាក់ឲ្យតុលាការជំនុំជំរះ . . . . . . ២៤

– ខណ្ឌកម្ម . . . . . . . . . . . ២៥

– ផ្ទេរក្របខណ្ឌ . . . . . . . . . . ២៦

## ៣– បិត្តសាស្ត្រ - គរុកោសល្យ :


– មិនធ្វេសប្រហែស . . . . . . . . . . ២៧


## ៤ – ភាគសិក្សា :

### ក – រៀនអាន :


– ព្រៃឈើ . . . . . . . . . . . . ៣៣

– សត្វព្រៃ . . . . . . . . . . . ៣៤

– បំការដំណាំ . . . . . . . . . . . ៣៦

សួនផ្កា . . . . . . . . . . . . ៣៧

– ម្ហូបអាហារ . . . . . . . . . . . ៣៩

– សុភាវធម៌ . . . . . . . . . . . . ៤០


### ខ – ឆត្វត្តសាស្ត្រ :


– សេចក្តីណែនាំសំរាប់ថ្នាក់បឋមភូមិ . . . . . ៤៥

– សេចក្តីណែនាំក្នុងការធ្វើនិងប្រើប្រាស់សម្ភារសិក្សា . ៥៣


### គ – ប្រវត្តិសាស្ត្រ :


– បាឋកថាព្រះរាជបេសកកម្មតាមទារឯករាជ្យជាតិ . . ៦០

ឃ - ភូមិសាស្ត្រ :

- អង្គការសង្គមកិច្ច . . . . . . . . . . . ៧៣
- គ្រឿងការពារសុខភាពពលរដ្ឋ . . . . . . . ៧៩
- អង្គការរដ្ឋបាល . . . . . . . . . . . . ៨១

ង - សោតទស្សនៈ:

- ការសិក្សាសិល្បៈ ក្នុងរង្វង់សាលារៀន (ក) . . ៨៤

ច - ផ្នែកផ្សាយវិជ្ជាហត្ថកម្មៈ

- ការរៀបចំដីឥដ្ឋ . . . . . . . . . . . ៩១
- របៀបដាំបន្លែ . . . . . . . . . . . ៩៧
- វិជ្ជាមេផ្ទះ :
- អនាគតនៃមាតា (ក) . . . . . . . . ១០៧

៥ - អនាម័យសិក្សា :

- ការចំរើនសុខភាពនៃកុមារ (ក) . . . . . . ១១១

៦ - កីឡា:

- ផ្នែកដើរ . . . . . . . . . . . . . ១១៦
- ផ្នែកតុល្យភាព . . . . . . . . . . . . ១១៨
- ផ្នែកកំសាន្ត សំនួរដោយរូបភាព . . . . . . ១២១

៧ - នយោបាយសេដ្ឋកិច្ច :

– អភិលាភ នឹងប្រាក់ចំណេញ . . . . . . . . ១២២

៨ – ពត៌មានទូទៅ:

– ពាក្យខ្មែរប្រែពីបរទេស . . . . . . . . . . ១៣០

– វត្ថុជាតិចំខ្សែក . . . . . . . . . . . ១៣៩

– របៀបប្រើពាក្យ . . . . . . . . . . ១៤២

– សេចក្ដីស្នើ . . . . . . . . . . . ១៤៦

– វចនានុក្រម សំស្ក្រឹត ខ្មែរ . . . . . . . ១៤៩

៩ – ការប្រឡង :

– ជោគជ័យនៃនិស្សិតរបស់យើងក្នុងឆ្នាំ ១៩៦២ - ៦៣ .

១០ – វេទិកាស្វែរិន :

– សេចក្ដីស្នើអំពីសំឡេងព្យញ្ជនៈសំយោគ . . . . ១៥៧

– ចម្លើយ (ការកគ្មី?). . . . . . . . . . . ១៦៣

ដំណឹងចុងក្រោយបង្អស់ . . . . . . . . . . ១៦៤

១១ – មរណភាព : ១៦៨

ស.ប.ស.ខ

លក្ខន្តិកៈ សមាគមបុគ្គលិក

សិក្សាខ្មែរ

ត ពីទស្សនាវដ្តី ខែ តុលា ឆ្នាំ ១៩៦៣

## ២ – ជំពូកទី ៣

## ការគ្រប់គ្រង

ប្រការ ១២ – សមាគមមានគណៈកម្មាធិការកណ្តាល ១ ប្រកប ដោយសមាជិក ១២ នាក់គ្រប់គ្រងគឺ :

| | | |
|---|---|---|
| ប្រធាន | | ម្នាក់ |
| អនុប្រធាន | | ម្នាក់ |
| អគ្គលេខាធិការ | | ម្នាក់ |
| អនុលេខាធិការ | | ម្នាក់ |
| អគ្គហិរញ្ញិក | | ម្នាក់ |
| អនុហិរញ្ញិក | | ម្នាក់ |
| បណ្ណារក្ស | ២ | នាក់ |
| ស្នងការ | ៤ | នាក់ |

ប្រការ ១៣ — សមាជិកនៃគណៈកម្មាធិការកណ្ដាល ត្រូវឲ្យមហាសន្និបាតបោះឆ្នោតរើសសម្រាប់ ១ នាក់ក្នុងចំណោមសមាជិកនៃសមាគមដែលមានទីលំនៅ ៗ ភ្នំពេញ ។

សមាជិកដែលត្រូវបានគេរើសតាំងហើយ ដល់ទៅឆ្នាំក្រោយៗ អាចឈរឈ្មោះឲ្យគេរើសទៀតបាន ។

ប្រការ ១៤ — ការបោះឆ្នោតត្រូវធ្វើដោយសម្ងាត់ ហើយយកតាមភាគច្រើនលើស ១ ។ បើបេក្ខជនច្រើនគ្នាបានសំឡេងស្មើគ្នា ត្រូវរើសយកអ្នកណា ដែលមានអាយុច្រើនជាងគេ ។

ប្រការ ១៥ — បើមានសមាជិកម្នាក់ ឬច្រើនគ្នាពេះតែមានធុរៈមកប្រជុំពុំបាន ឬក៏ត្រូវបណ្ដេញចេញ ឬក៏ស្លាប់ ឬក៏ត្រូវរាជការផ្លាស់ប្ដូរទៅខេត្តក្រៅ ឬក៏សុំលាលែងពីគណៈកម្មាធិការកណ្ដាល គណៈកម្មាធិការកណ្ដាលត្រូវរកសមាជិកឯទៀត នៃសមាគមមកជំនួសជាបណ្ដោះអាសន្ន ។

ប្រការ ១៦ — សមាជិកនៃគណៈកម្មាធិការកណ្ដាលណាដែលមិនបានមកប្រជុំ ៤ ដងជាប់ៗគ្នាដោយគ្មានធុរៈអ្វីមាំទាំ ទុកដូចជាសុំលាលែង ។

ប្រការ ១៧ — នៅក្នុងមហាសន្និបាតវិសាមញ្ញ ប្រសិនណាបើមានសមាជិកភាគច្រើនបានបញ្ចេញសេចក្ដីមិនទុកចិត្ត ចំពោះគណៈកម្មាធិការកណ្ដាល នេះគណៈកម្មាធិការត្រូវតែសុំលាលែង ១ រំពេច ហើយមហាសន្និបាតដដែលនោះបោះឆ្នោតរើសគណៈកម្មាធិការថ្មី ១ មកធ្វើការជំនួស រហូតដល់មានមហាសន្និបាតសាមញ្ញក្រោយទៀត ។

ប្រការ ១៨ — សមាជិកគណៈកម្មាធិការកណ្ដាលត្រូវធ្វើការឲ្យសមាគមទទេ ។ បើសមាជិកណា ត្រូវតម្រូវឲ្យទៅបំពេញបេសកកម្មណាមួយដែលមានបង់ខាតសោហ៊ុយ សមាគមត្រូវចេញសោហ៊ុយនោះឲ្យ ។

ប្រការ ១៩ — បើសមាជិកគណៈកម្មាធិការកណ្ដាលណាមិនបំពេញមុខងារខ្លួន ដូចមានកំណត់ក្នុងលក្ខន្តិកៈនេះឲ្យបានត្រឹមត្រូវ គណៈកម្មាធិការកណ្ដាលត្រូវហូតងារសមាជិកនោះចេញ ។

ប្រការ ២០ — កាលណាប្រធានគណៈកម្មាធិការកណ្ដាល ឬសមាជិកភាគច្រើននៃគណៈកម្មាធិការកណ្ដាលនោះអញ្ជើញឲ្យប្រជុំ គណៈកម្មាធិការកណ្ដាល ត្រូវតែប្រជុំយ៉ាងតិច ១ ដងក្នុង ១ ខែ ឬក៏ពេលដែលដងណាដែលត្រូវការប្រជុំប្រយោជន៍ឲ្យសមាគមបានជឿនទៅមុខ ។

ប្រការ ២១ — ទីងសម្រេចអ្វីមួយ ត្រូវឲ្យភាគច្រើនលើស ១ យល់ព្រម ។ កាលណាមានសំឡេងស្មើគ្នា សំឡេងទុកជាបានការ ។ រូប

ប្រជុំហើយត្រូវធ្វើសេចក្ដីកត់ហេតុ ១ ឲ្យគណៈកម្មាធិការចុះហត្ថលេខា ។

ប្រការ ២២ — គណៈកម្មាធិការកណ្ដាល អាចប្រជុំសម្រេចការផ្សេង ៗ បាន លុះត្រាតែសមាជិកភាគច្រើនមកប្រជុំផង ។

ប្រការ ២៣ — គណៈកម្មាធិការកណ្ដាលទទួលភារៈអនុវត្តវិធាន-ការ នឹងសេចក្ដីសម្រេចរបស់មហាសន្និបាត ព្រមទាំងចាត់ចែងការដែលជាប្រយោជន៍ដល់សមាគមផង នៅខេត្តមួយ ៗ នឹងនៅក្រុងភ្នំពេញ ។

ប្រការ ២៤ — គណៈកម្មាធិការកណ្ដាល មានគណៈកម្មាធិការ ១ ជាជំនួស ។ គណៈកម្មាធិការនោះ មានសមាសភាពដូចតទៅ :

— ប្រធាន ម្នាក់

— អនុប្រធាន ម្នាក់

— អគ្គលេខាធិការ ម្នាក់

— លេខាធិការបណ្ណារក្ស ម្នាក់

— ហិរញ្ញិក ម្នាក់

— អនុហិរញ្ញិក ម្នាក់

— សមាជិកពី ២ ទៅ ៤ នាក់ តាមខេត្តធំ-តូច ។

ប្រការ ២៥ – សមាជិកនៃគណៈកម្មាធិការខេត្រ ឬក្រុងភ្នំពេញ ត្រូវបោះឆ្នោតរើសតាមរបៀបដូចគណៈកម្មាធិការកណ្ដាល ។

សមាជិកនៃគណៈកម្មាធិការកណ្ដាល មិនអាចឈរឈ្មោះឲ្យគេបោះឆ្នោតតាំងជាសមាជិកគណៈកម្មាធិការខេត្រ ឬក្រុងភ្នំពេញ ទៀតទេ ។

ប្រការ ២៦– នៅមហាសន្និបាតសមាគមម្ដងៗ ត្រូវតែមានសមាជិកក្នុងគណៈកម្មាធិការខេត្រ ឬ ក្រុងភ្នំពេញ ៣ នាក់យ៉ាងតិចចូលប្រជុំផង ។

ប្រការ ២៧ – មហាសន្និបាតត្រូវបោះឆ្នោតរើសគណៈកម្មការត្រួតពិនិត្យ ១ ផង មានសមាជិក ៣ នាក់ រើសយកក្រៅពីគណៈកម្មាធិការកណ្ដាល ដើម្បីត្រួតពិនិត្យការកាន់កាប់ខាងហិរញ្ញវត្ថុរបស់គណៈកម្មាធិការ ។ គណៈកម្មការនេះ ត្រូវប្រជុំគ្នាយ៉ាងតិច ៦ ខែម្ដង ហើយត្រូវរាយការណ៍ ១ ឆ្នាំម្ដងជូនមហាសន្និបាត ។

ប្រការ ២៨ – ដំណើរការនិងបទបញ្ជារបស់គណៈកម្មាធិការខេត្រ និងគណៈកម្មាធិការក្រុងភ្នំពេញ មានសភាពដូចគ្នា និងដំណើរការនិងបទបញ្ជារបស់គណៈកម្មាធិការកណ្ដាល ។

ប្រការ ២៩ – គណៈកម្មាធិការខេត្រ ឬគណៈកម្មាធិការក្រុងភ្នំពេញ អាចទុកប្រាក់នៅក្នុងហិបខ្លួនបានត្រឹមតែ ៩ ភាគ ក្នុង ១០ ភាគ ដែលប្រមូលបានមកកពល់ត្រីមាសប៉ុណ្ណោះ ។ លើសពីនេះត្រូវបញ្ជូន

ទៅគណៈកម្មាធិការកណ្ដាលដាក់ទុកក្នុងធនាគារណាមួយ នៅ ភ្នំពេញ ក្នុងនាមសមាគមទាំងមូល ។ ការបញ្ចេញប្រាក់លើសមកគណៈកម្មាធិការកណ្ដាល ត្រូវធ្វើក្នុង ២ អាទិត្យក្រោយពីជាប់ត្រីមាសមក ។

ប្រការ ៣០ គណៈកម្មាធិការកណ្ដាល ត្រូវតែធ្វើសេចក្ដីរាយការណ៍មួយ អំពីសកម្មភាពរបស់ខ្លួនរាល់ត្រីមាស ផ្ញើទៅគ្រប់គណៈកម្មាធិការខេត្ត និងក្រុង ភ្នំពេញ ឲ្យបានដឹងផង ។

ឯគណៈកម្មាធិការខេត្ត និងក្រុង ភ្នំពេញវិញ ក៏ត្រូវធ្វើសេចក្ដីរាយការណ៍ ១ អំពីសកម្មភាពរបស់ខ្លួនរាល់ត្រីមាស ផ្ញើឲ្យគណៈកម្មាធិការកណ្ដាលវិញដែរ ។

# ផ្នែកកិច្ចការរាជការ

## លំហែអស់ពេលដ៏យូរ

ប្រកាសលេខ ១៧២៣ ចុះថ្ងៃទី ២២-៦-៦៣

លំហែអស់ពេលដ៏យូរសម្រាប់រយៈពេល ២ ខែ បានត្រូវអនុញ្ញាត ឲ្យមន្ត្រីសិក្សាទាំងឡាយ ដូចមាននាមខាងក្រោមៈ—

សម្រាប់លើកទី ១

គិតពីថ្ងៃទី ៣០-៥-៦៣

— លោក រុំ-សាលី អត្តលេខ ១៦៩៩ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់ លេខ ៣ ធ្វើការនៅសាលា ទួលគី (កណ្ដាល) ដើម្បីកំសាន្ត នៅភ្នំពេញ ។

សម្រាប់លើកទី ២

គិតពីថ្ងៃទី ២៩-៥-៦៣

— កញ្ញា អ៊ុម ជឿន អត្តលេខ ៩៨៤ គ្រូបឋមសិក្សាបំពេញ វិជ្ជាថ្នាក់លេខ ៤ ពីមុនធ្វើការនៅសាលា គគីរ (កណ្ដាល) ដើម្បី កំសាន្តនៅ កណ្ដាល ។

— លោក សាយ ឆានស្រី អត្តលេខ ២០៨៧ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ១ ពីមុនធ្វើការនៅសាលា តាព្រហ្ម-មានជ័យ (ភ្នំពេញ) ដើម្បីកំសាន្ត នៅកណ្ដាល ។

សម្រាប់លើកទី ៤

គិតពីថ្ងៃទី ២៣-៣-៦៣

— អ្នកស្រី សរ សាង នាមដើម កែវ-សាវណ្ណ អត្តលេខ ៤៣០៣ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ពីដើមធ្វើការនៅសាលាសំរោង (កណ្ដាល) ដើម្បីកំសាន្តនៅកណ្ដាល ។

នៅក្នុងរយៈពេលលំហែនេះ សាមីខ្លួនមានសិទ្ធិបើកបៀវត្សរ៍ដែលបានអត្រាទុកក្នុងលក្ខណៈបង្ហាញក្នុងមាត្រា ២៤ នៃព្រះរាជក្រមលេខ ៨៤៦ ន-ស ចុះថ្ងៃទី ១០ កុម្ភៈ ១៩៦៣ ។

## លំហែពិសេស

ប្រកាសលេខ ១៧៤៥ ចុះថ្ងៃទី ២៨-៦-៦៣

លំហែពិសេសក្នុងសម័យបោះឆ្នោត ពីថ្ងៃទី ២០-៥ ទៅថ្ងៃទី ២៣-៦-៦៣ ដើម្បីជ្រើសរើសយកតំណាងថ្មីនៃក្រុមអ្នករាជការ ដើម្បីឲ្យទៅធ្វើការនៅទីប្រឹក្សាព្រះរាជអាណាចក្រ បានត្រូវអនុញ្ញាតឲ្យដល់មន្ត្រីសិក្សាទាំងឡាយ ដូចមានរាយនាមតទៅនេះ៖

– លោក ហែម - គ្រាញ់ អត្តលេខ ២៣ គ្រូបឋមសិក្សាបំពេញវិជ្ជា ដើមខ្សែថ្នាក់លេខ ២ ធ្វើការនៅអធិការដ្ឋានភ្នំពេញ ។

– លោក ជា - តាលាយ អត្តលេខ ១៧០ គ្រូបឋមសិក្សាជាន់ដំបូង ដើមខ្សែថ្នាក់លេខ១ធ្វើការនៅសាលាឥន្ទ្រទេវី នៅ(ភ្នំពេញ)។

គិតរយៈពេលលំហែនេះ សាមីខ្លួនមានសិទ្ធិបើកប្រាក់បៀវត្ស ដូចមានចែងនៅមាត្រា ១៣ នៃច្បាប់បោះឆ្នោត ។

## លំហែទៅពេលសំរាលកូន

ប្រកាសលេខ ១៩៨០ ចុះថ្ងៃទី ២៤-៦-៦៣:

លំហែសម្រាប់សម្រាលកូនអស់រយៈពេល ២ ខែ បានត្រូវអនុញ្ញាតឲ្យដល់មន្ត្រីសិក្សាទាំងឡាយ ដូចមានរាយនាមខាងក្រោម: –

គិតពីថ្ងៃទី ១ មេសា ១៩៦៣

– អ្នកស្រី សាញ់ - អៀង នាមដើម មាស - តុង អត្តលេខ ៧៨៦ គ្រូបង្ហាត់វិជ្ជាខ្សែថ្នាក់លេខ ២ ធ្វើការនៅសាលា បុទុមរាជា (ភ្នំពេញ) ។

– អ្នកស្រី ទៀង - ណៃហោង នាមដើម យិន - គីមឡេង អត្តលេខ ៣៦៤១ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅសាលា ពញាក្រែក (ភ្នំពេញ) ។

– អ្នកស្រី លឹម ផាន់ឡុង នាមដើម រស់ - យ៉ាលីសែ អត្តលេខ ១២៧៧ គ្រូបឋមសិក្សាបំពេញវិជ្ជាបំរុងកជការធ្វើការនៅ អនុវិទ្យាល័យ ជ័យវរ្ម័នទី ៧ ( ដីឥដ្ឋ ) ។

– អ្នកស្រី តាន់ - ហួតឆាយ នាមដើម ជា - ប៊ិយ អត្តលេខ ៣៧៣៦ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៣ ធ្វើការនៅសាលា ព្រះពុទ្ធឃករាជ្យ (សៀមរាប) ។

– អ្នកស្រី សំ - ក្លួន នាមដើម អ៊ុច - ឃន អត្តលេខ ៤៧៣៩ គ្រូបឋមសិក្សាជាន់ដំបូងបំរុងកជការ ធ្វើការនៅសាលា កំពង់ក្តី (សៀមរាប) ។

– អ្នកស្រី ខាន់ - ថន នាមដើម ស៊ា - អាំងជៀង អត្តលេខ ១១៨៣ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៣ ធ្វើការនៅសាលា ព្រះសុ-រាម្រឹត (ភ្នំពេញ) ។

– អ្នកស្រី ណាន - ឌុក នាមដើម រាម - ឈួនស្រេន អត្តលេខ ៩៩៤ គ្រូបឋមសិក្សាជាន់ដំបូង ដើមខ្សែថ្នាក់លេខ ២ ធ្វើការនៅសាលា ចៅពញាហុក (ភ្នំពេញ) ។

– អ្នកស្រី ត្វច - ឆ្វ នាមដើម ជឹម - រិន អត្តលេខ ១០៣៤ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅសាលា ក្រាំងឡាញ់ (សៀមរាប) ។

– អ្នកស្រី ទេស - សាអ៊ុន នាមដើម ណាង - សៅសុគន្ធ អត្តលេខ ៩៤១ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅអនុវិទ្យាល័យ សម្ដេចឪ នៅអង្គតាសោម (តាកែវ) ។

–អ្នកស្រី យក់-វ៉ុន នាមដើម ហុង-សៃយ៉ន អត្តលេខ ៤០៤៧ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ៥ ធ្វើការនៅសាលា សាចាន (តាកែវ) ។

– អ្នកស្រី ពៅ - ប៊ុនធុន នាមដើម ប៊ុក - រិន អត្តលេខ ៤៧៤៦ គ្រូបឋមសិក្សាជាន់ដំបូងបំរុងរាជការ ធ្វើការនៅសាលាតំរូ អង្គតាសោម (តាកែវ) ។

– អ្នកស្រី យិន - ផុនហ៊ាង នាមដើម អ៊ុង - សំអាន អត្តលេខ ៣០៨៩ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៣ ធ្វើការនៅសាលាជីផុះ (កំពង់ចាម) ។

– អ្នកស្រី អៀង - ហោង នាមដើម ជុំ - ស៊ីម៉ាល័យ អត្តលេខ ២០៩១ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ធ្វើការនៅសាលា ស្តង់ (កំពង់ចាម) ។

– អ្នកស្រី សេង-ហាន នាមដើម ហ៊ឹម-សំបូរ អត្តលេខ ៣១៣៦ គ្រូបង្ហាត់វិជ្ជាខ្ទរថ្នាក់លេខ ៤ ធ្វើការនៅសាលា ឃកាភម (ព្រៃវែង) ។

គិតពីថ្ងៃទី ៤ មេសា ១៩៦៣

– អ្នកស្រី ឈន-សុភាព អត្តលេខ ១៩០០ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅសាលា ព្រះកែវមរកត (ភ្នំពេញ) ។

គិតពីថ្ងៃទី ៥ មេសា ១៩៦៣

– អ្នកស្រី ហៃ-វុឌ នាមដើម ស៊ុន-សំព្រៀង អត្តលេខ ៣៩១០ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅសាលា សន្ធរម៉ុក (ភ្នំពេញ) ។

– អ្នកស្រី អៀង-ស៊ីមសាគូ នាមដើម សោម-ចិន អត្តលេខ ៤៣៣៩ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅសាលា ព្រះកែវមរកត (ភ្នំពេញ) ។

– អ្នកស្រី ឌី-យុន នាមដើម ញឹក-គឹមជូ អត្តលេខ ១០៧០ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅសាលា ព្រះអង្គអេង (ភ្នំពេញ) ។

តាំងពីថ្ងៃទី ១០ មេសា ១៩៦៣ :

-អ្នកស្រី ធី-ចា៉ះ នាមដើម ឌុង-សាមឿង អត្តលេខ ៥២៩៦ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៥ ធ្វើការនៅសាលាត្រាំកក់ (តាកែវ) ។

តាំងពីថ្ងៃទី ១៥ មេសា ១៩៦៣ :

-អ្នកស្រី ប៉ែន-ផាន នាមដើម សេង-ជឹម អត្តលេខ ៤០១១ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅអនុវិទ្យាល័យតាំងគោក (កំពង់ធំ) ។

-អ្នកស្រី ស៊ុន-ឈាង នាមដើម រស់-សយ អត្តលេខ ៣០៩៦ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ធ្វើការនៅសាលាព្រៃទទឹង (កំពង់ស្ពឺ) ។

តាំងពីថ្ងៃទី ១៧ មេសា ១៩៦៣:

-អ្នកស្រី អ៊ុត-ហៃ នាមដើម ស្រី-សា៉ក់ងា៉លី អត្តលេខ ៤២៨៦ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅឧត្តរសាលា (បាត់ដំបង) ។

គិតពីថ្ងៃទី ១៩ មេសា ១៩៦៣ :

–អ្នកស្រី ខៀវ-យ៉ុន នាមដើម រស់-សុខុន អត្តលេខ ៣០៩៧ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ធ្វើការនៅសាលាចាក់-អង្រែលើ (កណ្ដាល) ។

គិតពីថ្ងៃទី ២០ មេសា ១៩៦៣ :

–អ្នកស្រី ខៀវ-ឌឹម នាមដើម គឹម-ណារី អត្តលេខ ៣៧៣២ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៥ ធ្វើការនៅសាលាច្បារអំពៅ (កណ្ដាល) ។

គិតពីថ្ងៃទី ២៦ មេសា ១៩៦៣:

–អ្នកស្រី ស៊ិន-តៀង នាមដើម លាង-ស៊ីវហោង អត្តលេខ ៤៣២៨ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ធ្វើការនៅសាលាក្រាំង (តាកែវ) ។

គិតពីថ្ងៃទី ២៩-មេសា ១៩៦៣

– អ្នកស្រី សុខ-ឆាយ នាមដើម សាំង-សារី អត្តលេខ ៥០៩២ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៥ ធ្វើការនៅសាលា ឥន្ទ្រទេវី (ភ្នំពេញ) ។

– អ្នកស្រី អៀង-គឹមលាង នាមដើម អាង-វួចឆេង អត្តលេខ ១៣៦២ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅវិទ្យាល័យព្រះរាជសម្ភារៈ (កំពត) ។

គិតពីថ្ងៃទី ១ ធ្នូ ១៩៦៣

– អ្នកស្រី អ៊ុក-អុង នាមដើម ម៉ុំ-សំអៀង អត្តលេខ ២២៦៤ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅសាលាបឋម-សិក្សាបំពេញវិជ្ជាផ្នែកមជ្ឈមណ្ឌល (កំពត) ។

– អ្នកស្រី ថាច-ប្រឌីថា នាមដើម ត្រឹង-សុមន្ថា អត្តលេខ ៤៧៧៦ គ្រូបឋមសិក្សាជាន់ដំបូងបំរុងរាជការ ធ្វើការនៅសាលា ពោធិសាត់ ក្រុង ។

គិតពីថ្ងៃទី ២០ ធ្នូ ១៩៦៣

– អ្នកស្រី កាង-ស៊ូម៉េត នាមដើម ប្លាត-បូឈាត អត្តលេខ ១៤៩២ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅទីចាត់ការអប់រំមូលដ្ឋានខេត្ត (ស្វាយរៀង) ។

គិតពីថ្ងៃទី ១-៦-៦៣

– អ្នកស្រី ភាម-យស់សរ នាមដើម លឹម-វុឌ្ឍី អត្តលេខ ៥០៩៤ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅអនុវិទ្យាល័យព្រះបាទសុរាម្រិត (កំពង់ឆ្នាំង) ។

– អ្នកស្រី អុត-សួង នាមដើម ទៀវ-សារុន អត្តលេខ ១៤៩០ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៣ ធ្វើការនៅអធិការដ្ឋានបឋមសិក្សា (ភ្នំពេញ) ។

គិតពីថ្ងៃទី ២៨-៦-៦៣

– អ្នកស្រី ឆាយ-តាំង នាមដើម ហាយ-សួអន អត្តលេខ ៣៦០៩ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅសាលាស្វាយរៀង (ក្រុង) ។

គិតពីថ្ងៃទី ១-៧-៦៣

– អ្នកស្រី សរ-ភ៉ន់ធុន នាមដើម ម៉ម-សុខន អត្តលេខ ១០៩៣ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅទីចាត់ការអប់រំមូលដ្ឋានជាតិ (ភ្នំពេញ) ។

គិតពីថ្ងៃទី ៤-៧-៦៣

- អ្នកស្រី ជូ-សាន នាមដើម សុខ-ដុស អត្តលេខ ៣៥៩៩ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៤ ធ្វើការនៅសាលា ព្រែកសរ (ស្វាយរៀង) ។

គិតពីថ្ងៃទី ៨-៧-៦៣

- អ្នកស្រី ជ្រៅ-រួត នាមដើម គឹក-ស៊ីណាយ អត្តលេខ ២៤៧២ គ្រូបឋមសិក្សាជាន់ដំបូងដើមខ្សែថ្នាក់លេខ ១ ធ្វើការនៅការិយាល័យបុគ្គលិកនៃទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ ។

គិតពីថ្ងៃទី ២៤-៧-៦៣ :

- អ្នកស្រី គួរ-ជេងអ៊ិង នាមដើម តាង់-គឹមហួច អត្តលេខ ១០៦៩ គ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៤ ធ្វើការនៅសាលា ព្រះជ័យចេស្តា (ភ្នំពេញ) ។

គិតពីថ្ងៃទី ៣០-៧-៦៣ :

- អ្នកស្រី អ៊ឹម-ជ្រុន នាមដើម មៀវ-សៃឡួន អត្តលេខ ៣៧១០ គ្រូបង្ហាត់វិជ្ជាខ្សែថ្នាក់លេខ ៥ ធ្វើការនៅសាលា ចាន់ជ័យក្រោម (ក្រចេះ) ។

គិតពីថ្ងៃទី ១០-៨-៦៣ :

-អ្នកស្រី ម៉ែន - ស៊ីផាន នាមដើម អ៊ុម - ស៊ីវណ្ណា អត្តលេខ ៤៦៦០ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៣ ធ្វើការនៅសាលាព្រះសីហនុ ទូកមាស (កំពត) ។

## ការដាក់ឲ្យតុលាការជំនុំជំរះ

មន្ត្រីសិក្សាដូចមានឈ្មោះខាងក្រោម បានត្រូវអនុញ្ញាតឲ្យតុលាការជំនុំជំរះ :-

ប្រកាសលេខ ១៣៨២ ចុះថ្ងៃទី ២៧-៦-៦៣

-លោក អ៊ុម - ស៊ាង អត្តលេខ ១៦៦០ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ២ ធ្វើការនៅកំពង់ចាម ពីបទបំពារបំពានដោយចេតនាលើរូបកាយក្មេងម្នាក់ឈ្មោះប៉ុង - សុខ ។

ប្រកាសលេខ ១៣៨២ ចុះថ្ងៃទី ២៧-៦-៦៣ :

-លោក រស់ - លី អត្តលេខ ៩១១៦ គ្រូបង្ហាត់ជួយថ្នាក់លេខ ៤ ធ្វើការនៅភ្នំពេញពីបទបំពារបំពានដោយចេតនាលើរូបកាយស្ត្រីម្នាក់ឈ្មោះនាងគីម - សារុន ។

ប្រកាសលេខ ១៨៦៧ ចុះថ្ងៃទី ១០-៧-៦៣ :

លោក សៀម-សែម អត្តលេខ ១០២៨ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៤ ធ្វើការនៅតាកែវ ត្រូវចោទពីបទបំពារបំពានដោយប្រតនាលើរូបកាយគ្នាទៅវិញទៅមក ។

## ទណ្ឌកម្មនៃវិន័យ

ប្រកាសលេខ ១៨៤៤ ចុះថ្ងៃទី ៨-៧-៦៣ :

លោក អួត-មួន អត្តលេខ ២៥៤ គ្រូបង្ហាត់វិជ្ជាខ្មែរ ធ្វើការនៅ កំពង់ចាម (បឋមសិក្សា) បានត្រូវដាក់ឲ្យនៅក្នុងភាពទំនេរឥតបៀវត្សក្នុងរយៈពេលមួយឆ្នាំ គិតពីថ្ងៃទី ១១ កញ្ញា ១៩៦២ ជាកាលបរិច្ឆេទដែលសាមីខ្លួនបានបោះបង់កន្លែងធ្វើការ ។

ប្រកាសលេខ ១៨៦៦ ចុះថ្ងៃទី ១១ - ៧ - ៦៣

ការស្ដីបន្ទោសយ៉ាងតឹងរ៉ឹង ព្រមទាំងលុបឈ្មោះចេញពីបញ្ជីឡើងឋានន្តរស័ក្ដិ ទោះតាមវេនជ្រើសរើសក្ដី តាមវេនអតីតភាពក្ដី បានត្រូវដាក់ទណ្ឌកម្មលើលោក ព្រហ្ម-សង់ហាង អត្តលេខ ១៨១៦ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ៧ធ្វើការនៅប៉ៃលិន (បាត់ដំបង) ពីដំណើរឈប់ឥតច្បាប់ ។

ប្រកាសលេខ ១៩៤១ ចុះថ្ងៃទី ២២ - ៧ - ៦៣

ការកាត់បៀវត្សចំនួន ២៣ ថ្ងៃ ពីថ្ងៃទី ១៧ មេសា ទៅដល់ថ្ងៃទី ៨ ឧសភា ១៩៦៣ បានត្រូវដាក់ទណ្ឌកម្មលើលោក រស់ - លី អត្តលេខ ៥១១៦ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ៥ ធ្វើការនៅសាលាជ្រោយចង្វារ ( ភ្នំពេញ ) ពីបទឈប់ឥតច្បាប់ ។

# ការផ្ទេរក្របខណ្ឌ

— លោក ម៉ៅ - ស៊ីម គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ១ ជាអ្នកមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម័យប្រឡងថ្ងៃទី ១-៣-៦៣ បានត្រូវផ្ទេរមកក្នុងក្របខណ្ឌគ្រូបឋមសិក្សាបំពេញវិជ្ជា ដោយមានឋានន្តរស័ក្តិ ជាគ្រូបឋមសិក្សាបំពេញវិជ្ជាថ្នាក់លេខ ៣ បៀវត្សប្រចាំឆ្នាំ ៤២ ០០០៛ អត្តលេខ ២២៧៦ ។

# ចិត្តសាស្ត្រ-គន្លុះកោសល្យ



អប្បមាទ៖ « ការមិនធ្វេសប្រហែស »

ផ្សំតាមចិត្តសាស្ត្រ ដោយ ញូរ - ហេង

មកដល់អាយុ ៤០ ឆ្នាំ អាយុល្មមមានការពិសោធន៍ ខ្ញុំសុំក្រឡប់ក្រោយក្រឡេកមើលកិច្ចការបង្រៀនខ្ញុំ កាលខ្ញុំនៅជានវៈគ្រូ ក្នុងពេលដែលកន្លងមក ១៩ ឆ្នាំទៅហើយ ដើម្បីរៀបរាប់ជូនអ្នកអានទាំងឡាយជ្រាប ។

ទីនេះខ្ញុំអធិប្បាយពីការធ្វេសចំពោះដំណេក ចំពោះចំណង់ និងចំពោះអំពើសាហាវខ្លះ ព្រោះថា កាលខ្ញុំនៅក្នុងវ័យក្មេងនៅឡើយ ខ្ញុំតែងជួបប្រទះនឹងអំពើទាំងលើនេះជាញឹកញយ ដែលជាហេតុមួយបណ្តាលឲ្យអស់កម្លាំងនឹងឲ្យល្អក់បញ្ញាស្មារតី ។

ការអត់ងងុយ នាំឲ្យអស់កម្លាំង ការអស់កម្លាំងនាំឲ្យទ្រុឌទ្រោមកាយ ឲ្យសរសៃវិញ្ញាណទន់ខ្សោយ ឲ្យសតិស្មារតីអន់ថយជាលំដាប់ ។ ដោយហេតុនេះយើងត្រូវប្រកាន់ក្បួនអនាម័យក្នុងការរស់នៅរបស់យើង ។

១ – គឺថាដេកឲ្យមានកំណត់កាល ហើយឲ្យគ្រប់គ្រាន់ផង ។

២ – ចាយវាយខាងចំណីអាហារចិញ្ចឹមជីវិតតាមចំនួនប្រាក់ខែ ។

៣ – ចេះរស់នៅស្របតាមមជ្ឈដ្ឋានដែលសាលារៀនឋិតនៅ ។

ទាំងអស់គ្នាជ្រាបស្រាប់ហើយថា នៅពីមុខគ្រូយើងម្នាក់ៗ មានសិស្សចំនួន ៤០ នាក់ ដែលយើងត្រូវអប់រំ ឲ្យចំរើនទាំងកាយ ទាំងបញ្ញា ទាំងចរិយា ។ បន្ទុកនេះមិនមែនស្រាលឯណា គេដឹងថាគ្រូម្នាក់ៗនឹងទទួលភារៈនេះបាន លុះណាតែគ្រូនោះមានសុខភាពមាំមួន មានការអប្បមាទហើយនឹងភាពរហ័សរហួនផង ។

គ្មានអ្វីធ្វើឲ្យគ្រូអស់កម្លាំង ជាងសិស្សខ្វះវិន័យទេ បើសិស្សមិនចូលចិត្តនឹងការរៀនសូត្រ ខ្លួនអ្នកនឹងក្លាយទៅជាចំណីរោគ ឬទៅជាចំណីជម្ងឺណាមួយមិនខាន ។ តែតាមការសង្កេតដែលធ្លាប់ឃើញមក សិស្សទាំងអស់ច្រើនចូលក្នុងវិន័យ ហើយបើមានផ្គាំផ្គងខ្លះ មិនពេញលក្ខណៈក៏ព្រោះតែមកអំពីសេចក្ដីយល់ខុសពីយើង តាមភាពគ្នាជាក្មេងប៉ុណ្ណោះ ។ ហេតុនេះបើយើងចេះដឹកនាំថ្នាក់យើងឲ្យមានសកម្មភាព

ជាប្រក្រតី យើងមុខជានឹងជួបប្រទះជ័យជំនះ ដែលកើតមកអំពីការប្រឹងប្រែងដោយអប្បមាទ ។ គ្រប់មេរៀនទាំងអស់ គ្រូនិងសិស្សត្រូវប្រឹងប្រែងរួបរួមគ្នាធ្វើការតាមចំណែករៀងខ្លួន ទើបបានសេចក្ដីសប្បាយក្នុងមុខការទាំងអស់គ្នា ។

នរៈគ្រូខ្លះ ប្រឹងប្រែងបង្រៀនសិស្សតែឯកឯងនៅក្នុងថ្នាក់ មិនទុកពេលសួរសិស្ស មិនទុកពេលឲ្យសិស្សគិតឆ្លើយ ច្រើនទេសនាតែឯង លុះដល់ចុងឆ្នាំសិស្សមិនបានពូកែ ក៏តាំងនិយាយថា សិស្សខ្ញុំខ្សោយណាស់មិនងាយគ្រូណាកែឡើងទេ ។ ការចោទសិស្សបែបនេះជាការស្រួលហើយ ព្រោះសិស្សមិនអាចហ៊ានឆ្លើយការពារខ្លួនគ្នាទេ ក៏ប៉ុន្តែលោកគ្រូ.អ្នកគ្រូដែលមានការពិសោធន៍យល់ថា លោកគ្រូណាត្អូញថាសិស្សខ្លួនខ្សោយ លោកគ្រូនោះត្រូវចោទខ្លួនឯងថា ខ្លួនមិនចេះអប់រំសិស្សទៅវិញ « ជាងមិនកើតតែងបន្ទោសដែក » ។

នរៈគ្រូ ត្រូវចេះលៃសំចៃកម្លាំងក្នុងការបង្រៀន មិនលុះតាមបំណង មិនប្រព្រឹត្តអំពើសាហាវ ។ ដោយចង់ឲ្យគ្នាឯងសរសើរ ឲ្យអ្នកដទៃដឹងឮថា ខ្ញុំខំធ្វើការ ឲ្យសិស្សអួតថា ចេះ នៅឆ្នាំដំបូងខ្ញុំបានស្រែកឡូឡាបង្រៀនសិស្ស តាំងព្រឹកតាំងល្ងាចគ្មានឈប់ ។ ដល់ម៉ោងចេញពីសាលារៀន ខ្ញុំអស់កម្លាំងល្វើយ ខ្ញុំមានដំណើរឃ្លង-

ឃ្លាំងបែបផ្សេងៗ សំឡេងខ្ញុំស្អក ស្អាបាត់ទឹកដមពីរោះ ទឹកមុខខ្ញុំបែបខឹងរហូតមកដល់ផ្ទះ ។

ការទម្លាប់ស្រែកបង្រៀនបែបនេះ មិនមែនគ្រាន់តែនាំឲ្យទឹកមុខខ្ញុំអន់បាត់សភាពរីករាយ ខូះសិរីសួស្ដីប៉ុណ្ណោះទេ គឺថែមទាំងឲ្យសិស្សខ្ញុំយកចិត្តទុកដាក់ស្ដាប់ខ្ញុំតែកាលណាខ្ញុំនិយាយសំឡេងគំហ៊ឹង ព្រោះវាយល់ថា កាលណាខ្ញុំនិយាយធម្មតា សិស្សថាការនិយាយនោះមិនសូវមានសារៈប៉ុន្មាន ។

អ្នកគ្រូម្នាក់បញ្ចប់បង្រៀនស្រែករខ្ញុំ ហើយបង្រៀនសិស្សនៅថ្នាក់ជាប់នឹងខ្ញុំទៀត គាត់បានស្រែកបង្រៀនសិស្សដូចខ្ញុំដែរ ។ ខ្ញុំមិនដឹងច្បាស់ថា គាត់បន្តស្រែកប្រណាំងនឹងខ្ញុំ ឬ គាត់ស្រែកព្រោះសម្រែកសំឡេងខ្ញុំ រំខានសិស្សគាត់ក៏មិនដឹង ។ មួយឆ្នាំក្រោយមក សំឡេងអ្នកគ្រូនោះ បាត់សូរស្រួយមុតដូចកាលគាត់ទើបនឹងចេញទៅបង្រៀន ។

កំហុសបង្រៀនស្រែក នាំសិស្សឲ្យមានគ្រោះថ្នាក់រង ។ ខ្ញុំស្ដាយទឹកមុខខ្ញុំ ដែលខ្ញុំបាត់រីករាយ ស្ដាយសំឡេងខ្ញុំបាត់ទឹកដមពីរោះ ស្ដាយខ្ញុំនិយាយឮពិបាកនឹងលើកដាក់សំឡេងតាមបំណុបពាក្យ ស្ដាយពិសេសជាងគេគឺស្ដាយដោយធ្វើសំឡេងអ្នកគ្រូម្នាក់ដែលជាសហសេវិករបស់ខ្ញុំ ឲ្យបាត់សំឡេងស្រួយមុត ឲ្យបាត់សំឡេងស្រើរហូតមកដល់សព្វថ្ងៃនេះ ។

ដើម្បីចៀសវាងកុំឲ្យមានការខូចខាងលើនេះ នោះគ្រូត្រូវរៀននិយាយមួយៗ ដូចគេរាប់ហើយត្រូវចេះលើកដាក់សំឡេងឲ្យធ្ងន់ស្រាលតាមចំណុចពាក្យផង ទើបសិស្សងាយស្ដាប់បាន ។ អប្បមាទជាធំបម្បងជាងកុសលធម៌ទាំងពួង ទឹងជាមាគ៌ានៃសេចក្ដីសុខចំរើន ។

# ភាគសិក្សា



នៅក្នុងទស្សនាវដ្តីលេខ ២ ខែ តុលា គ. ស. ១៩៦៣ ក្រុមគ្រូបង្រៀនតែងសៀវភៅសិក្សាបាន " ទិតៀនជាស្ថាបនា " នូវសៀវភៅ " រៀនអានថ្នាក់ទី ១១ ,, ដែលលោកបាងហ្វាងសាលារៀនគំរូ កំពង់ធំ ព្រមទាំងសហការីលោកនិងសិស្សបានរៀបរៀងហើយផ្ញើទៅឲ្យពិនិត្យ ។

## នៅក្នុងទស្សនាវដ្តីលេខ ១ ខែ កញ្ញា មុននេះ មានអត្ថបទខ្លះស្តីពី :

១ – ដើមរំពេក ២ – ការដាំដើមរំពេក

៣ – ប្រយោជន៍ដើមរំពេក ៤ – ការធ្វើកន្ទេលនឹងដើមរំពេក

## ទស្សនាវដ្តីលេខ ២ ខែ តុលា មុននេះ បានជូនដល់មិត្តអ្នក :

១ – ការធ្វើស្រែ

២ – ប្រដាប់ប្រដាសំរាប់ធ្វើស្រែ

៣ – ការដកស្ទូង

៤ – ការច្រូតកាត់នឹងការបោកបែន

៥ – ការស្រិតអង្ករ

តទៅ សូមជូនអត្ថបទខ្លះទៀត ។ គឺជាអត្ថបទរបស់សៀវភៅដដែលនេះ ហើយប្រាថ្នាជូនដល់មិត្ត ដើម្បីជាមេគំនិតក្នុងមុខរបរគ្រូបង្រៀន ។ ដូចជាបានជំរាបខ្លះមកហើយ យើងខ្ញុំរង់ចាំទទួលសេចក្តីទិតៀនពីអស់លោកអ្នកដោយមេត្រីភាព ។



# អំពីព្រៃឈើ

ថ្ងៃឈប់សំរាករៀន ខ្ញុំបានទៅលេងព្រៃជាមួយគូកនខ្ញុំ ៗ ក្នុងព្រៃព្រឹក្សា ស្ងាត់ណាស់គួរឲ្យខ្លាច ខ្ញុំនិងគូកនខ្ញុំ គ្មានឮសូរសំឡេងអ្វីក្រៅពីសត្វយំទេ យូរៗខ្ញុំឮសូរខ្យល់បក់ស្លឹកឈើម្តងៗ ។

នៅក្នុងព្រៃ ខ្ញុំឃើញមានដើមឈើធំៗជាច្រើន ដូចជា ស្រឡៅ ឈើទាល ផ្ចឹក បេង ក្រញូង សុក្រំ ម៉ៃសាក់ ។ល។ ឈើព្រៃទាំងនេះ សុទ្ធសឹងជារបស់មានប្រយោជន៍ទាំងអស់ ក្នុងការ ងសង់ទីលំនៅ ធ្វើទូក កប៉ាល់ ឡានរថយន្ត ស្ពាន ធ្វើសម្ភូល្បង គ នឹងប្រដាប់ប្រដាប្រើប្រាស់ទូទៅ ដូចជា តុ ទូ កៅអី គ្រែ ។ល។

ដូច្នេះ យើងមិនត្រូវកាប់បំផ្លាញព្រៃឈើ ឬ ចោលភ្លើងឲ្យឆេះ តប្រយោជន៍ទេ យើងត្រូវជួយថែគ្នាឲ្យបានដុះធំល្អ ។

# សត្វព្រៃ

នៅក្នុងព្រៃ មានសត្វច្រើនដូចជានៅក្នុងស្រុកដែរ ពួកសត្វចតុប្បាទទាំងនោះគឺដំរី ទន្សោង ទន្សាយ ខ្ទីង ប្រើស ក្តាន់ រមាស រមាំង ឈ្លូស ខ្លា ចចក សំពោច ស្វា ។ល។

សត្វព្រៃទាំងនេះ មានខ្លះស្លូត ដូចជាប្រើស ឈ្លូស ក្តាន់ រស៊ីស្មៅជាអាហារ ខ្លះទៀតកាចសាហាវណាស់ដូចជាដំរី ខ្លា ចចកជាដើម ។ ពោច ស្វាក្រិសនិងស្វាព្រាហ្មណ៍ចូលចិត្តរស់នៅលើព្រឹក្សា មានដៃជើងមុខមាត់ប្រហែលមនុស្ស ហើយមានប្រាជ្ញាជាងសត្វទាំងអស់ ។

សត្វព្រៃរស់នៅក្នុងព្រៃធំៗ ហើយឲ្យផលល្អៗមកយើងខ្លះដែរ សាច់វាមានរសជាតិពិសាជាងសត្វស្រុក ។ ស្បែក ស្នែង ភ្លុក ថ្គាម គេច្រើនយកទៅឆ្លាក់ឆ្នៃធ្វើរបស់ល្អៗ មានដម្លៃណាស់ ដូចជាមានតាំងលក់ក្នុងសាលាវិចិត្រសិល្បៈនៅភ្នំពេញ ។





# ចំការដំណាំ

ខាងជើងសាលារៀនខ្ញុំ មានចំការដំណាំមួយធំសមល្មម សំរាប់ពួកគូកនខ្ញុំ រៀនដាំបន្លែនៅពេលល្ងាចៗ ។

វេលាល្ងាច ខ្ញុំឃើញគូកនខ្ញុំ ធ្វើការកុះករក្នុងចំការដំណាំ ខ្លះកាប់ដីធ្វើរង ខ្លះបោចស្មៅ ខ្លះដាំបន្លែ ខ្លះស្រោចទឹក ខ្លះដាក់ជីយ៉ាងសប្បាយ ។

ដំណាំនឹងបន្លែ ដែលគូកនខ្ញុំដាំនោះ មានច្រើនមុខណាស់ ដូចជា ស្ពៃ ដំឡូង ប៉េងប៉ោះ ត្រប់ ការុត ត្រសក់ ម្រះ ។ល។

ពួកគូកនខ្ញុំសប្បាយចិត្តណាស់ កាលណាឃើញដំណាំដុះបានល្អពេញចំការ ។

# សួនផ្កា

ពេលល្ងាចត្រជាក់ លោកគ្រូនាំមិត្តសំឡាញ់ខ្ញុំ ចេញទៅធ្វើសួនផ្កានៅមុខសាលារៀន សិស្សទាំងអស់នាំគ្នាលើកដីធ្វើសួនខ្ពស់ៗ ។ បន្ទាប់មកលោកគ្រូឲ្យគេផ្កាផ្សេងៗមកដាំជាលំអ មិត្តខ្ញុំនាំគ្នាថែដើមផ្កាទាំងនោះជានិច្ច ខ្លះបោចសំអាតស្មៅ ខ្លះស្រោចទឹក ទីងបាក់ដីឲ្យផុះ ចាប់ហើស ។

រដូវភ្លៀង នៅក្នុងសួនសាលា ផ្ការីកស្រស់ស្អាត មានពណ៌ប្លែកៗ ហើយស្រស់បំព្រង ។ មិត្តខ្ញុំត្រេកអរនឹងសួនផ្កាគ្រប់គ្នា ។

សួនផ្កានៅសាលារៀនខ្ញុំ ល្អដូចសួនផ្កានៅផ្ទះខ្ញុំដែរ ។

( គំនូរសួនផ្កានៅទំព័រ ៣៨ )





# ម្ហូបអាហារ

ការបរិភោគអាហារ ត្រូវឲ្យទៀងពេល ក្នុងមួយថ្ងៃ ខ្ញុំបរិភោគ ៣ ដង គឺស្រស់ស្រូបពេលព្រឹក ថ្ងៃត្រង់និងពេលល្ងាច ។ ពេលខ្ញុំបរិភោគម្ដងៗ ត្រូវឲ្យមានបាយ សាច់ ស៊ុត បន្លែស្រស់និងផ្លែឈើ ។ បាយរួច ខ្ញុំផឹកទឹកឆ្អិនដែលដាំពុះ ។

រដូវក្ដៅ ខ្ញុំបរិភោគបន្លែស្រស់ៗ រដូវរងា ខ្ញុំបរិភោគជាតិខ្លាញ់ឲ្យច្រើន ។

ម្ហូបអាហារដែលខ្ញុំបរិភោគ ត្រូវបំអិននិងលាងទឹកឲ្យស្អាត ។ ចាន សម ស្លាបព្រា កែវ ខ្ញុំលាងនឹងសាប៊ូទុកក្នុងទូសំណាញ់ ។ ខ្ញុំត្រូវគ្របអាហារឲ្យជិត កុំឲ្យរុយរោមបាន ។ ការសំអាតនាំឲ្យមានសុខភាពល្អ ។

# សុភាវធម៌

ស្រង់ចេញពីសៀវភៅ «ជីវិតម៉ែ»

រៀបរៀងដោយព្រះតេជព្រះគុណ ចាំង - ឲាត់

លោក អាំង - ម្ហួង អតីតភ្នាក់ងារក្រុមអប់រំសុខភាព និង អនាម័យទីលំនៅ សៀមរាប ក្រុង បានផ្ញើមកឲ្យយើងចុះផ្សាយ ដើម្បីជាប្រយោជន៍របស់គុណបំណាច់នៃកតញ្ញូកតវេទិតាធម៌ ។ សូមមិត្តអញ្ជើញយកជាឯកសារដើម្បីជាមេគំនិតក្នុងការបង្រៀនសុភាវធម៌ខ្លះ ។

## ជំពូកទីមួយ

### មាតាបិតាជាព្រះព្រហ្ម " តាមពុទ្ធភាសិត ,,

### ឬថា ម៉ែឪជាព្រះរបស់កូន

ក្នុងទីនេះយើងនិយាយស្រាយៗទៅតាមមើលឃើញ ទៅតាមឮ ទៅតាមដំណតៗមក មិនមែននិយាយទៅតាមដើមគម្ពីរសុទ្ធតែទេ ។

សត្វមានមេវាបង្កើត មនុស្សមានម៉ែឪបង្កើត មិនមែនទេពតាណាជាអ្នកបង្កើតទេ ។ ដូច្នេះកូន ពិតជាម៉ែបង្កើត ដូចពុទ្ធភាសិតមួយបទថា " មិនដែលឃើញព្រាហ្មណ៍ណាកើតមកពីមាត់ព្រហ្មទេ ឃើញតែកើតមកពីម៉ែឪ,,។ បុរសស្ត្រីគ្រប់រូប មុននឹងមានកូនក៏មិនឈ្មោះថាម៉ែឪ

ឬហៅថាម៉ែឪពុំទាន់បានទេ លុះត្រាតែមានកូនហើយទើបបានតាមបញ្ញត្តិថា « ម៉ែឪ » ។

ម៉ែឪជាឯកភាពមួយ កើតឡើងដោយការសម្ពន្ធ ជាធម៌ធម្មតាប្រក្រតី ធម៌សក្តិសិទ្ធិរបស់កូន មានតម្លៃប៉ុនគ្នា មានទម្ងន់ប៉ុនគ្នា មានន័យដូចគ្នា តែអ្នកផងទាំងពួងច្រើនតែកំបាំងកែក មើលមិនសូវឃើញថាមានគុណភាព ឬមានតម្លៃអ្វីប៉ុន្មានទេ គេច្រើនទុកដាក់ថាជារបស់ធម្មតាទៅវិញ អើ អ្វីមួយដែលសក្តិសិទ្ធិ ដែលមានតម្លៃ តែកាលណាត្រឡប់ទៅជាធម្មតាប្រក្រតីហើយ ច្រើនតែកំបាំងកែកមើលមិនសូវឃើញទេ តែយើងត្រូវចូលចិត្តថា ការដែលពិត បើអាក្រក់នៅតែអាក្រក់ បើល្អនៅតែល្អ ឥតប្រែប្រួលសភាពពិតទៅជាប្រការដទៃឡើយ ។

មួយទៀត ម៉ែឪតែងតែបង្កើតកូន មានកូនហើយតែងតែស្រឡាញ់កូន មានភារៈចិញ្ចឹម បីបមថ្នាក់ថ្នម ថែរក្សា ទំនុកបំរុងអប់រំសង្គ្រោះកូនដែលខ្នងកសាងឲ្យកើតឡើងទុកតពូជពង្សឲ្យបានឋិតថេរបីកាលតរៀងទៅ មិនមែនតែប៉ុណ្ណោះទេ ម៉ែឪមានចិត្តប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ជាធម៌សំរាប់ជ្រោមជ្រែងកូនជានិច្ចនិរន្តរ៍ឲ្យបានសុខសប្បាយទៀត ។ ការចិញ្ចឹមកូនឲ្យរស់ ឲ្យសុខសប្បាយ . ហើយឲ្យបានទៅជាមនុស្សល្អ នេះជា

ការៈធ្ងន់ណាស់ គម្រក់ក្រៃលែង ម៉ែឪត្រូវព្យាយាមធំបំផុត ដោយកាយ ដោយវាចា ដោយចិត្ត ដោយវិធីគ្រប់យ៉ាងតាមដែលអាចធ្វើបាន ដើម្បីឲ្យកូនបានរស់ហើយឲ្យកូនបានទៅជាមនុស្សល្អ ។ បើយើងសួរថា កូនគឺអ្វី? កូនគឺមនុស្ស មនុស្សគឺមនុស្សលោក បើកូនគឺមនុស្សលោកហើយ ម៉ែឪមិនមែនត្រឹមតែម៉ែឪរបស់កូនទេ គឺម៉ែឪរបស់លោក ព្រោះលោកមិនគឺអ្វីដទៃក្រៅពីមនុស្សនេះទេ ។ ការធ្វើឲ្យមនុស្សល្អ គឺការធ្វើលោកឲ្យល្អ ឲ្យសុខចំរើន ក្សេមក្សាន្ត ជាធម៌ប្រសើរក្រៃលែង ។ ហេតុនេះហើយបានជាលោកពោលថាមាតាបិតាជាបុព្វការីបុគ្គល មានគុណធ្ងន់ក្រៃលែងធ្ងន់ពន់គណនារាប់ពុំបានឡើយ ។

បំណែកកូនដែលបានទទួលទុកការៈពីម៉ែឪ ដែលបានជ្រកកោនក្រោមម្លប់ម៉ែឪ ហើយបានរស់រានមានជីវិតបានសុខសប្បាយត្រជាក់ត្រជុំក្សេមក្សាន្ត តែងបានឃើញច្បាស់នូវសុភមង្គលទាំងនេះនៅក្នុងចិត្តនៃខ្លួន គួរតែបង្អោនចិត្តឲ្យទៅរកម៉ែឪ គោរពម៉ែឪ ទុកម៉ែឪជាទេវតា ឬជាព្រះរបស់ខ្លួន ។ ពេលមានអាសន្នកូនតែងនឹកដល់ម៉ែឪ សំបូងសង្រួង សូមឲ្យគុណម៉ែឪជួយខ្លួន រីឯអំណាចព្រហ្មវិហារធម៌គឺសក្ដិសិទ្ធិណាស់ អាចជ្រាបចូលទៅមុតដល់ថ្លើមប្រមាត់ ធ្វើចិត្តកូនឲ្យធូរស្រាលឲ្យកក់ក្ដៅ ឲ្យដកដង្ហើមធូរស្រួល ហើយឲ្យរីកកាយសប្បាយចិត្ត ហៅពេលណា

ស្រាយទុក្ខពេលនោះ ក្នុងពេលមានទុក្ខធំ គ្រាន់តែហៅឬនឹកក្នុងចិត្តថា ម៉ែឪប៉ុណ្ណោះក៏ក្សាន្តចិត្តបានខ្លះដែរ ។ ដូច្នេះ ពាក្យថា ម៉ែឪ នេះ ឃើញថាជានាមមានគុណានុភាពធំណាស់ ហាក់ដូចជានាមទេព្ដា ដ៏សក្ដិសិទ្ធិមួយដែរ ។ រីឯពាក្យនេះ ដោយគោរព កូនហៅថា មាតាបិតា ជនក ជននី ដោយស្និទ្ធស្នាល កូនតែងហៅថា ម៉ែឪ ម្ដាយឪពុក ប៉ា ពុក ប៉ះ ម៉ះ ។ល។ បណ្ដាពាក្យទាំងនេះ ពាក្យដែលកូនចូលចិត្តហៅជានិច្ចកាល ច្រើនហៅថា ម៉ែឪ ។ ពាក្យនេះកូនហៅពល់ពេលយប់ថ្ងៃហៅស្និទ្ធមាត់អស់ពីពោះពុង អស់ពីដួងចិត្ត ហៅឥតគោតញញើត ឥតធុញទ្រាន់ មិនបេះជិនណាយ ឮហើយពីពេះគ្របៀក មិនសង្កៀរគ្របៀកទេ ។ មានតែពាក្យម៉ែឪនេះមួយទេ ដែលកូនពេញចិត្តហៅ ហៅដដែលៗ ហៅពល់ថ្ងៃហៅហើយហៅទៀត ហៅមិនមានពេលវេលាជិនណាយ ហៅរហូតទៅទល់រលត់ខ្យល់ចេញចូល ។ ចំណែកម៉ែឪ ឮកូនហៅ ហើយក៏រីករាយសប្បាយចិត្តណាស់ ។

ទីបំផុត ជីវិតកូនជាជីវិតម៉ែឪ កូនរស់នៅដោយសារម៉ែឪ ម៉ែឪក៏រស់នៅដោយសារកូន ជីវិតម៉ែឪនឹងជីវិតកូនមានការសម្ពន្ធគ្នាជិតជិតណាស់ សូម្បីតែកូនកំព្រាឥតម៉ែឪ ម៉ែឪស្លាប់ចោលទៅតាំងពីតូច មិន

បានឃើញមុខម៉ែឪ ក៏ដឹងខ្លួនថាមានម៉ែឪ ហើយគិតថា ម៉ែឪគន់ស្រឡាញ់ខ្លួនបីបមថ្នាក់ថ្នម ចិញ្ចឹមថែរក្សា អប់រំសង្គ្រោះ យកចិត្តទុកដាក់ទំនុកខ្លួនដូចម៉ែឪគេផងទាំងឡាយ ដោយហោចណាស់ គិតថាពេលកើតទុក្ខ បានម៉ែគ្រាន់ជួយសម្រាលលំហែទុក្ខ ពេលយំហៀរហូរទឹកភ្នែក បានម៉ែយកសំពត់ជូតទឹកភ្នែកឲ្យ បបោសអង្អែលលួងលោមឲ្យកូនដកដង្ហើមស្រួល ឲ្យកូនរីករាយសប្បាយចិត្តដែរ ។ គ្រាន់តែឮពាក្យថា ម៉ែឪក៏ធ្វើកូនឲ្យក្សាន្តចិត្តបានដែរ នេះបានជា « ព្រះរបស់កូន » ។



# សេចក្ដីណែនាំសម្រាប់ថ្នាក់បឋមភូមិ

១– ធ្វើឲ្យចាប់ចិត្ត នឹង លេខ ហើយប្រើលេខដោយការពន្យល់នឹងដោយឲ្យអនុវត្តលេខនោះទូទៅគ្រប់ស្ថានភាពដោយខ្លួនឯង ។

២ – នៅឱកាសបង្រៀនមេរៀនឯទៀត ៗ យើងត្រូវច្នៀតបង្រៀនលេខខ្លះផង ។

ក. ក្នុងការបង្រៀនភូមិសាស្ត្រ យើងអាចច្នៀតនិយាយអំពីម៉ែត្រ - គីឡូម៉ែត្រ ឬ គីឡូម៉ែត្រក្រឡា ជាដើមក៏បានដែរ កុំឲ្យតែការបង្រៀនភូមិសាស្ត្រនោះក្លាយទៅជាមានលក្ខណៈ រៀនលេខហួសហេតុពេក ។

៣ – ធ្វើគ្រោងការមួយនៃសកម្មភាពទាំងនោះ ដែលនាំឲ្យសិស្សអាចរៀនលេខបាន ៗ ដរាបណា យើងប្រើវិធីច្រើនឡើង ៗ ដរាបនោះ សិស្សក៏បានយល់ច្បាស់ឡើង ៗ ដែរ ។

៤ – បញ្ជាប់សកម្មភាព ដើម្បីពន្យល់ភ្លាម ឬកែភ្លាម បើសិស្ស មិនយល់ ឬ ធ្វើខុស ។

៥ – ជួយពន្យល់សិស្សម្នាក់ៗ ដែលមានការលំបាកនឹងយល់ ឬ នឹងធ្វើសកម្មភាពអ្វីមួយ ។

៦ – ធ្វើឲ្យសិស្សយល់ច្បាស់ថា តើអ្វីជា « កាតរូម » នៃចំនួននីមួយៗរបស់លេខ ដោយប្រើវត្ថុរៀងកាយជាគំរូ : ។

( ○ ○ ○ ○ ○ | ○ ○ ○ ○ ○ | ○ ○ ○ ○ ○ | ○ ○ ○ ○ ○ )

៧ – ឲ្យសិស្សរាប់វត្ថុជារូបជាជាងឲ្យរាប់មាត់ទទេ ដោយស្វ័យប្រវត្ត ។

៨ – ធ្វើឲ្យគេយល់ច្បាស់នូវ ចម្ងាយ-ទំហំ ទម្ងន់-ពេល ។ល។

៩ – ពាក្យសព្ទដែលបានប្រើហើយ ត្រូវតែពន្យល់ឲ្យបានយល់ច្បាស់ ។ គេអាចធ្វើឲ្យយល់ពាក្យនីមួយៗបានដោយការប្រើប្រាស់វត្ថុច្រើនបែបច្រើនយ៉ាង ។

១០ – ជាពិសេស ជួយសិស្សណាដែលមិនទាន់យល់ច្បាស់ក្នុងពាក្យសព្ទ ។

១១ – ពន្យល់ន័យនៃ " លេខបូក - លេខសង - លេខគុណ លេខចែក " ដោយប្រើសម្ភារៈហើយជួយសិស្សឲ្យពន្យល់ខ្លួនឯងវិញ កាលណាក៏បានយល់ខ្លះហើយ ។

១២ – មិនគ្រាន់តែពន្យល់សិស្សឲ្យបេះចម្លើយត្រូវប៉ុណ្ណោះទេ គឺថែមទាំងធ្វើឲ្យគេបេះពន្យល់វិធីដែលនាំឲ្យរកចម្លើយបាននោះថែមទៀតផង ។

១៣– ជ្រើសតែការយកមកណាដែលសិស្សអាចធ្វើកើត ហើយដែលសិស្សធ្លាប់បានពិសោធធ្វើរួចមកហើយ ។

១៤ – មុននឹងឲ្យសិស្សរៀនលេខជាអរូបី យើងត្រូវបង្រៀនដោយបង្ហាញជាបឋមសិនទូវ ៖

១ – មនុស្ស - សត្វ - វត្ថុពិតៗ; ២ - រូប; ៣ - លេខ ។ ប៉ុន្តែជួនកាលរបៀបរៀបរយនេះអាចផ្លាស់ប្តូរបានដែរ បើយើងរកមនុស្ស ឬ សត្វ វត្ថុពិតៗពុំបាន ។

១៥ – យកល្បែងជាសកម្មភាព ដើម្បីបង្រៀនលេខ ។

១៦– រៀបចំគ្រោងការមួយសម្រាប់ការពិសោធន៍ ។ ការពិសោធន៍ជាគ្រឹះនៃការប៉ុនប្រសប់របស់សិស្សនៅថ្ងៃក្រោយ ។

៩ – ការរៀនលេខដោយប្រើដុំឈើ ៨ ។ ក្នុងការរៀននេះ សិស្សអាចរកឃើញថា ៨ គឺជា បួន ២ ជង ( ○○ ○○ ○○ ○○ ) ឬ ពីរ ៤ ជង ( ○○○○ ○○○○ ) ។ ការរកឃើញនេះ អាចបានជាចំណេះថ្មីមួយទៀត ក្នុងការធ្វើលេខចែក ។ ។. ក្នុង ៨ មាន បួន ប៉ុន្មានជង ឬ ក្នុង ៨ មានពីរប៉ុន្មានជង ។ សិស្សអាចរកឃើញនូវ មេលេខបូកពួក ៨ (១+៧, ២+៦, ៣+៥, ៤+៤) ។

១៧ – ធ្វើឲ្យសិស្សឈប់មានទំលាប់ពឹងផ្អែកលើវត្ថុ ហើយ អាចបង្ហាញន័យដែលបានយល់ហើយនោះ ដោយគិត ។

១៨ – រៀបចំកម្មវិធីយ៉ាងណា ដើម្បីឲ្យសិស្សអាចចាប់យកគំនិត ដោយការរកឃើញ ។

១៩ – នៅថ្នាក់ទី ១២ និង ១១ ការបង្រៀនមិនត្រូវមានលក្ខណៈ អធិកអធមទេ ។

២០ – ឲ្យមានការអនុវត្តន៍យ៉ាងច្រើន ក្នុងការប្រើចំនួន ហើយត្រូវ ឲ្យការហាត់ធ្វើលេខជាអរូបី មានភាពតិចបំផុត នៅថ្នាក់បឋមភូមិនេះ ។

២១ – ពិនិត្យលទ្ធផលដែលបានមកអំពីការធ្វើសាកល្បង (Tests) ដើម្បីរៀបចំមេរៀនណាដែលត្រូវបង្រៀនសាឡើងវិញ ហើយនឹងឲ្យស្គាល់ថា តើសិស្សណាខ្លះត្រូវរៀនសាជាថ្មីម្ដងទៀត ។

៦២ – ធ្វើឲ្យសិស្សមានទំលាប់នឹងនឹកឃើញភ្លាមៗ នូវមេលេខ ហើយនឹងវិធីធ្វើលេខដែលបានរៀនរួចហើយ ។

មួយ ពីរ បី

មួយ ពីរ បី

ខ្ញុំដើរទៅស្ទូចត្រី



បួន ប្រាំ ប្រាំមួយ

ស្ទូចបានត្រីបង្កួយ



ប្រាំពីរ ប្រាំបី ប្រាំបួន
បានត្រីគ្រប់ចំនួន
ដប់ ដប់មួយ ដប់ពីរ
ខ្ញុំយកទៅអាំងស៊ី ។



អ្នកស្រី ពាន់-អ៊ុម

• តាមបទបារាំងមួយឈ្មោះ អង ឌឺ ត្រ្វា

# Un, deux, trois



# សេចក្ដីណែនាំក្នុងការធ្វើនិងប្រើប្រាស់សម្ភារសិក្សា

### សំរាប់មេរៀនទព្វន្ត :

បញ្ជាក់ទូទៅ :

១ – មុននឹងផ្ដល់សេចក្ដីណែនាំដល់លោកគ្រូ អ្នកគ្រូ ដើម្បីធ្វើសម្ភារសិក្សាសំរាប់មេរៀនទព្វន្ត នៅថ្នាក់ទី ១២ - ១១ យើងសូមបញ្ជាក់ថា សម្ភារៈទាំងនោះត្រូវមានលក្ខណៈសំខាន់ខ្លះដូចតទៅ :–

ក– ស្រាល

ខ– ជាប់ ស្អិត

គ– ទំហំធំអាចឲ្យមើលឃើញច្បាស់គ្រប់ៗគ្នា

ឃ– ពណ៌ដិត (កុំឲ្យមានរន្ទះពន្លឺចាំង)

ង– លាបពណ៌ ដែលក្មេងស្គាល់គ្រប់គ្នា

(ក្រហម លឿង បៃតង)

២– បំណែកវត្ថុដើមសម្រាប់យកមកធ្វើជាប្រដាប់អ្វីនីមួយៗ សូមរកតែរបស់ណា ដែលរកបានដោយងាយ ឬ ដែលមានស្រាប់នៅមជ្ឈដ្ឋានរបស់លោកគ្រូ - អ្នកគ្រូ ។

ឧទាហរណ៍ : កង់សេចក្ដីណែនាំរបស់យើងអំពីការធ្វើកង់ យើងបានពន្យល់ថា ឲ្យយកក្ដារកម្រាស់ ១ ស-ម មកវៀលឲ្យមូល ដោយមានកាំ ១៥ ស-ម តែបើនៅមជ្ឈដ្ឋានលោក - អ្នកគ្មានក្ដារ សោះ តើលោកគ្រូ-អ្នកគ្រូបានក្ដារពីណាមកធ្វើកង់ទាំងនេះ ? ។ យើងពុំបាច់កង្វល់នឹងរកក្ដារទេ យើងអាចយករបស់ខាងក្រោម ទាំងនេះ មកកាត់ចោះវន្ធ បានយ៉ាងស្រួលផងហើយស្រោលល្អ ទៀតផង :–

១ – ពីងពង់ ( មានវន្ធស្រាប់សម្រាប់កង់តូច-ធំ )

២ – គម្របដបទឹកក្រូច ( កង់តូច )

៣ - ដើមឫស្សីគាន់តូចល្មម ( សម្រាប់កង់តូច-ធំ )

៤ – ផ្ដៅដំបង ( សម្រាប់កង់តូច-ធំ )

៥ – គ្រាប់អង្គញ់ (១) ( សម្រាប់កង់ធំ )

៦ – គ្រាប់ឈើខ្លះដែលវាំងសម្រាប់កង់តូច ។ ល ។

៧ – គ្រសាល់អម្បោះ (ក្បាលសម្រាប់កង់ធំ-ខ្លួនសម្រាប់កង់តូច)

(១) កុំស្សរថា កង់ប៉ុន្មាន ? ត្រូវស្សរថា អង្គញ់ប៉ុន្មាន ?

# ទសបក្រ ឬ កង់ជិប



សម្ភារៈសម្រាប់ធ្វើ :

- បន្ទះក្ដារទំហំ ១៨ស.ម × ៤១ស.ម × ១,៥ស.ម: ១ កំណាត់
- ដែកគោល ៥ ម ម : ១០ ដើម
- កង់ដែលមានកាំ ១ ស.ម : ១០ ដើម
- ថ្នាំលាបពណ៌សនិងខៀវ ឬ បៃតង - - - - -

របៀបធ្វើ :

១ - យកបន្ទះក្ដារខាងលើមកឈូសឲ្យរលីង ។ ជំបូងត្រូវឈូសគោលឲ្យត្រង់ស្អាតម្ខាងសិន រួចយកប្រដាយមកគូសបន្ទាត់តាមទំហំទទឹងក្ដារ ដោយបើកមុខប្រដាយ ១៨ ស.ម ។ ក្រោយពីបានតាំងឬប្រៀកនឹងគូសតម្រង់គោលទីពីរហើយ យើងត្រូវចាប់ឈូសបន្ទាត់ម្ខាងឲ្យរលីងរាបស្អាត ។ បើធ្វើដោយផ្ចិតផ្ចង់ យើង

ត្រូវគូសប្រលាយយកកម្រាស់ក្ដារឲ្យបានត្រឹមត្រូវទៀត ដោយបើកមុខ ១ស.ម ។ ឯចុងក្ដារតាំងសងខាង ត្រូវតម្រឹមឲ្យត្រង់ ដោយយកកៃនមកតម្រូវ ។

២ – យកដែកគោលដូចមានទំហំខាងលើមកកាត់ក្បាលចេញ រួចបោះលើក្ដារដូចគំរូខាងក្រោម :–



សំគាល់ :– ដើម្បីរកកន្លែងបោះដែកគោលកណ្ដាល យើងត្រូវទាញបន្ទាត់ពីកន្លែងដែកគោលជាចតុរង្ស កាលណាបន្ទាត់តាំងពីរនេះទៅខ្វែងគ្នាត្រង់ណា ត្រង់ចំណុចខ្វែងនោះជាកន្លែងសម្រាប់បោះដែកគោលកណ្ដាល ។



៣ – កង់  ដូចយើងបាននិយាយរួចមកហើយថា  ដើម្បីងាយស្រួលក្នុងការធ្វើ  គប្បីយើងរកដើមពងពងមករើសយកសាច់ណាដែលប៉ុនៗគ្នា  មកកាត់ជាកង់ៗកម្រាស់ប្រមាណជា ១ ស-ម ឬ ២ ស-ម ឲ្យបានចំនួន ១០ ។



៤ – ពណ៌ - មេក្តាត្រូវលាបពណ៌ស . ចំណែកកង់វិញ ត្រូវលាបពណ៌ផ្សេងទៅវិញ តែត្រូវលាបតែមួយពណ៌ ដូចជាខៀវ ឬ បៃតងជាដើម ។

របៀបប្រើ :

សម្ភារៈនេះសំរាប់ប្រើក្នុងការបង្រៀនលេខ ជាដំបូងគឺពី ១ ដល់ ១០ រាប់តាំងវិធីផ្សំនិងបំបែកនៃចំនួនតាំងនេះផង ។

ឧទាហរណ៍ : ដំបូងលោកគ្រូ - អ្នកគ្រូ ត្រូវបង្រៀនលេខពី១ដល់ ២ ។ ដំបូងយើងឲ្យក្មេងរាប់កង់ តើវាស្គាល់ចំនួន ២ ប្រាកដដែរឬទេ ? ។ យើងពុំចាំបាច់និយាយពីក្មេងចេះរាប់ទេ  យើងនិយាយតែពីក្មេង

ដែលមិនទាន់ចេះរាប់ (ពុំស្គាល់ពីរ) យើងត្រូវហៅទាំងអស់គ្នាឲ្យឡើងមកមុខក្ដារខៀន ហើយឲ្យក្មេងម្នាក់រាប់កន់ឲ្យបានត្រឹមត្រូវ ឲ្យមិត្តភក្ដិឯទៀតមើល ៗ លុះឃើញថាក្មេងយល់ទាំងអស់គ្នាហើយ ទើបសរសេរជាលេខនៅក្ដារខៀន ៗ

បញ្ជាក់ :

លោកគ្រូ • អ្នកគ្រូ សួរក្មេងឲ្យរកគ្រឿងអវយវៈយើងអ្វីខ្លះដែលមានពីរៗ (ត្រចៀក ភ្នែក ដៃ ជើង ៗលៗ)

តមកយើងដោះកន់ចេញឲ្យអស់ រួចឲ្យក្មេងណាម្នាក់ឡើងទៅដាក់កន់ ២ ទៅវិញ ៗ ឲ្យក្មេងម្នាក់ទៀតតំរៀបកន់ទាំងអស់ឡើងវិញ ហើយឲ្យគេហូតកន់ ២ ចេញ ៗ ឲ្យក្មេងម្នាក់ទៀតទៅដកកន់ ១ ចេញ រួចសួរថា នៅសល់កន់ប៉ុន្មាន ? បើថែមកន់ ១ មកវិញ ត្រូវជាកន់ប៉ុន្មាន ? ៗ កន់ ២ បើហូតចេញ ១ ត្រូវនៅសល់ប៉ុន្មាន ? ៗ កន់ ២ តើត្រូវហូតប៉ុន្មាន ឲ្យនៅសល់១ ៗ ចំពោះលេខជាបន្ដបន្ទាប់ សូមបង្រៀនរបៀបនេះជាដរាបរៀងទៅ ៗ សម្ភារៈនេះអាចប្រើបានក្នុងការបង្រៀនខ្ទង់លេខ ១០ និងរាយបានខ្លះ មិនតែប៉ុណ្ណោះ អាចប្រើបានក្នុងការបង្រៀនលេខគុណ និងលេខចែកដូចជា :

| | |
|---|---|
| ២ × ២ = . . . . | |
| ២ × ៣ = . . . . | ៣ × ២ = |
| ២ × ៤ = . . . | ៤ × ២ = |
| ២ × ៥ = . . . . | ៥ × ២ = |
| ៤ : ២ = . . . . | |
| ៦ : ២ = . . . . | ៦ : ៣ = |
| ៨ : ២ = . . . . | ៨ : ៤ = |
| ១០: ២ = . . . . | ១០: ៥ = |

ក្នុងការលើកសម្ភារៈនេះបង្ហាញក្មេងគប្បីបញ្ឈរផង ផ្តេកផង ហើយ របៀបរៀបកង់ក៏សុំឲ្យចេះរៀបច្រើនរបៀបផង :






# បាឋកថា

## ព្រះរាជបេសកកម្មទាមទារ
## ឯករាជ្យជាតិ
## នៃ
## មហាក្សត្រកម្ពុជា

សុខ ដារិន

យើងទាំងអស់គ្នាសុទ្ធតែដឹងច្បាស់ ហើយនៅចាំមិនភ្លេចទេថាឯករាជ្យប្រទេសយើងបានមកដោយស្នាព្រះហស្តនៃ សម្តេចព្រះប្រមុខរដ្ឋ ជាហេតុនាំឲ្យប្រជារាស្ត្រទាំងមូលលើកព្រះអង្គជាព្រះបិតាឯករាជ្យជាតិ ។

តែនៅមានជនប្រភេទខ្លះបានឃោសនាមួលបង្កាច់ ថាឯករាជ្យប្រទេសយើងបានមកដោយសន្និសីទក្រុងហ្សឺណែវ ឬថាបានមកពី

សឹង-ឡុក-ឋាន់ រត់ចូលព្រៃ ថែមទាំងប្រមាថមើលងាយមហាក្សត្រខ្លួន ថាគ្មានបានធ្វើអ្វីជាប្រយោជន៍ដល់រាស្ត្រ ។

ហេតុនេះដើម្បីបំបាត់ការសង្ស័យ លោកអគ្គស្នងការយុវជនរាជសង្គមនិយមខ្មែរបានបញ្ជាឲ្យកងការសាស្ត្រគ្រូរយើងមើលឡើងវិញ នូវព្រះរាជបេសកកម្មតាមទារឯករាជ្យជាតិ នឹងសកម្មភាពព្រះមហាក្សត្រកម្ពុជា ។ ការនេះ មានការលំបាកបន្តិចដោយយើងមានសៀវភៅជាឯកសារជាភាសាបារាំង ។ ហេតុនេះខ្ញុំមានការកិច្ច នឹងធ្វើបាឋកថាជូនសហជីវិនជាទីស្ដាប់តាមសមត្ថភាពទន់ខ្សោយ ដែលខ្ញុំសូមអភ័យទោសទុកជាមុន ។ ខ្ញុំបានដកស្រង់ទីនប្រែ :-

១ ១ – ពីសៀវភៅបង្ក្រងអត្ថបទដែល សម្ដេចព្រះនរោត្តម សីហនុ ទ្រង់ព្រះរាជនិពន្ធចុះផ្សាយក្នុងកាសែតព័ត៌មានរ៉េអាលិតេកាមបូស៊ីយែន ពីថ្ងៃទី ១៣ កញ្ញា ១៩៥៨ ដល់ថ្ងៃទី ៣ មករា ១៩៥៩ ។

១ ២ – ដកស្រង់ពីសៀវភៅ Rois de Kampuchéa « មហាក្សត្រកម្ពុជា ព្រះបាទអង្គឌួង ព្រះបាទនរោត្តម នឹង ព្រះបាទនរោត្តមសីហនុ » ។

តទៅនេះ ខ្ញុំនឹងអធិប្បាយអំពីព្រះរាជបេសកកម្មតាមទារឯករាជ្យជាតិ :

យើងទាំងអស់គ្នាដឹងហើយថាហេតុការណ៍នេះ កើតឡើងសម័យអសន្តិសុខក្នុងភូមិភាគ ឥណ្ឌូចិន ដើមឡើយប្រទេស កម្ពុជា នៅក្រោមអាណាព្យាបាលបារាំងលុះកងទ័ពជប៉ុនចាប់ បារាំង ថ្ងៃទី៩ មីនា ១៩៤៥ កងទ័ពនេះបានឲ្យប្រគល់ឯករាជ្យមកប្រទេសយើង តែរដ្ឋាភិ-បាលជប៉ុនពុំទទួលស្គាល់តាមផ្លូវច្បាប់ផងទេ ។ ហេតុនេះដល់ ជប៉ុន បរាជ័យទៅ បារាំង ក៏ត្រឡប់មកកាន់កាប់ប្រទេសយើងវិញ ។ ចាប់តាំងពីពេលនោះហើយ គឺឆ្នាំ ១៩៤៥ ដែល សម្តេច ព្រះនរោត្តម សីហនុ ទ្រង់ធ្វើសកម្មភាពទាមទារឯករាជ្យដោយមានការលំបាកជាអនេក ដែលខ្ញុំនឹងរៀបរាប់ដូចតទៅ :—

ថ្ងៃដែលសម្ពន្ធមិត្របារាំងនឹងអង់គ្លេស ចូលមកទឹកដីខ្មែរ ទៅហើយ ពួកនេះបានធ្វើលិខិតបន្តបន្ទាប់គ្នាថ្វាយព្រះមហាក្សត្រ សុំឲ្យព្រះអង្គបញ្ជូនប្រតិភូខ្មែរទៅធ្វើកិច្ចចរចាជាមួយខុមស្នងការបារាំង ស្តីអំពីលក្ខន្តិកៈប្រទេស កម្ពុជា ព្រះអង្គទ្រង់ឆ្លើយតបទៅវិញថា ព្រះអង្គមិនយល់ទាស់ទេ នឹងបញ្ជូនប្រតិភូខ្មែរទៅធ្វើកិច្ចចរចាជាមួយតំណាងរដ្ឋា-ភិបាលបារាំង ឯក្រុង កាល់គុត្តា នឹងក្រុងសង់ឡែរណាត់ៈ ទៀត តែទ្រង់សួរបញ្ជាក់ថាតើ បារាំង នឹងទុកប្រតិភូខ្មែរជាតំណាងប្រទេសឯករាជ្យឬទេ ព្រោះខ្មែរបានឯករាជ្យ តាមព្រះរាជក្រម ចុះថ្ងៃទី ១៣ មីនា

១៩៤៥ ។ ព្រះអង្គទ្រង់បញ្ជាក់ទៀតថា " យើងស្រុះស្រួលនឹងទាក់ទងជាមិត្តភាពជាមួយនឹងបារាំង ក្នុងផ្លូវនយោបាយ សេដ្ឋកិច្ច និងវប្បធម៌កុំឲ្យតែការទាក់ទងនេះ ធ្វើឲ្យខូចប្រយោជន៍ដល់ឯករាជ្យនៃមាតុភូមិយើង " ។

បារាំង គ្មានបានឆ្លើយនឹងព្រះរាជលិខិតនេះសោះ ស្រាប់តែល្ងាចមួយ ពួកសម្ពន្ធមិត្របារាំងអង់គ្លេសចាប់លោករដ្ឋមន្ត្រីទី ១ សឺង - ង៉ុក - ថាន់ ហើយបង្ខំឲ្យគណៈរដ្ឋមន្ត្រីក្រោយទទួលកិច្ចសន្យាបណ្ដោះអាសន្ន (Modus-Vivendi) ឲ្យប្រទេសកម្ពុជាមានស្វ័យភាពខាងផ្ទៃក្នុង (autonomie interne) តែការប្រស្រ័យជាមួយនឹងប្រទេសបារាំងត្រូវយោលទៅតាមសន្ធិសញ្ញាឆ្នាំ ១៨៦៣ និងអនុសញ្ញាឆ្នាំ ១៨៨៤ ។

ព្រះអង្គទ្រង់ព្រះតម្រិះដោយគតិបណ្ឌិតថា : ឯករាជ្យខ្មែរដែលកងទ័ពជប៉ុនឲ្យគ្មានអ្វីជាមូលដ្ឋានសោះ ព្រោះរដ្ឋាភិបាលប្រទេសនេះមិនបានទទួលស្គាល់ផង ថែមទាំងរដ្ឋាភិបាលជប៉ុនក្នុងគ្រាបរាជ័យត្រូវដាក់ជារដ្ឋាភិបាលឧក្រិដ្ឋ ។ ដូចនេះព្រះអង្គត្រូវតែកសាងឯករាជ្យចាប់ពីដើមទីឡើងវិញដោយ :

១.– រំលាយសន្ធិសញ្ញា និងអនុសញ្ញា ជាបំណងប្រទេស កម្ពុជា ក្នុងអាណាព្យាបាលបារាំង

២.– ធ្វើសន្ធិសញ្ញាថ្មីទៀត ដោយឲ្យប្រទេសបារាំង ទទួលស្គាល់ឯករាជ្យខ្មែរ ។

នៅពេលនោះហើយដែលពួកបរបក្ស នាំយុវជនខ្មែរស្រែកជេរព្រះអង្គ ជាក្បត់ជាតិ ដោយព្រោះអង្គមិនបណ្ដោយឲ្យមានអសន្តិសុខបង្ហូរឈាមគឺថា មិនព្រមចូលដៃធ្វើចៅហ្វាយពួកឥស្សរៈ និងបើកឲ្យយៀកមិញចូលរាយរំដោះ ។ ព្រះអង្គទ្រង់ឈ្វេងយល់ថា ពួកនេះមកធ្វើបាបតែរាស្ត្រតូចតាច ដុតបំផ្លាញស្ពានគេហដ្ឋានសាធារណៈ និងព្រះវិហារ ឯពួកយៀកមិញក៏រឹតមកបំរុងនឹងធ្វើចៅហ្វាយខ្មែរជំនួសបារាំង ។ ឧទាហរណ៍ ដ៏ជាក់ស្ដែងគឺដល់ពេលខ្មែរបានឯករាជ្យបរិបូណ៌ហើយ ពួកនេះមិនព្រមដកទ័ពថយចេញពីប្រទេសយើង ថែមទាំងចូលមកកាត់ក្បាល ខែត្រស្ទឹងត្រែង ក្រចេះ កំពង់ធំ ទៀត ។

ផលនៃការប្រើសន្តិវិធី គឺប្រទេសបារាំង បានទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យ កម្ពុជា តាមសន្ធិសញ្ញាថ្ងៃទី ៨ កក្កដា ១៩៤៩ ប្រទេសដទៃទៀត ក៏បានទទួលស្គាល់ឯករាជ្យកម្ពុជាតាមផ្លូវច្បាប់ មានសហរដ្ឋអាមេរិក ប្រទេសអង់គ្លេស អ៊ីតាលី ថៃឡង់ដ៍

ទួរគី កាណាដា អូស្ត្រាលីជាដើម ។ យើងបានដាក់អគ្គទូតនៅប្រទេសខ្លះ " សហរដ្ឋអាមេរិក ថៃឡង់ដ៍ " ដែលអាចឲ្យយើងទាក់ទងខាងផ្លូវនយោបាយជាមួយប្រទេសដទៃជាច្រើន តាមអគ្គទូតនានាដែលមាននៅប្រទេស ដែលមានទូកជទូតយើង ។

អំពីសន្ធិសញ្ញាជាដំបូងទី ១ នេះ ប្រទេសកម្ពុជាមិនទាន់បានឯករាជ្យបរិបូណ៌ទេ គឺនៅខ្វះអធិបតេយ្យខាងតុលាការខាងប៉ូលិស ខាងមេបញ្ជាការសឹក ខាងទូត ខាងមន្ត្រីប្តូរប្រាក់ នឹងខាងការបោះប្រាក់ ។ តែសន្ធិសញ្ញានេះ មានសារៈសំខាន់ដោយអាចឲ្យយើងទាមទារអធិបតេយ្យគ្រប់ផ្នែក ។ ហេតុនេះហើយបានជានៅឆ្នាំ ១៩៤៩ ព្រះមហាក្សត្រទ្រង់ទាមទារអធិបតេយ្យខាងបញ្ជាការសឹក ដើម្បីបង្ក្រាបអសន្តិសុខ ។ តាមសំបុត្រឆ្លើយចុះថ្ងៃទី ២៦ ឧសភា ឆ្នាំ ១៩៤៩ លោកស្នងការសាធារណរដ្ឋបារាំងបានផ្ទេរផ្នែកសឹកខេត្ត [សៀមរាប] និងកំពង់ធំ មកឲ្យខ្មែរដើម្បីសាកល្បងមើល ។ លុះដល់ឆ្នាំ ១៩៥១ បារាំងបានផ្ទេរតំបន់សឹកខេត្តបាត់ដំបងមកទៀត ។

នៅពេលនោះ លោក សឺង-ង៉ុក-ថាន់ ដែលត្រូវនិរទេសទៅប្រទេស បារាំង មិនទាន់វិលមកកាន់មាតុភូមិវិញទេ នេះសឲ្យឃើញ

ថាសម្ដេចព្រះឧត្ដមសីហនុទ្រង់ទាមទារឯករាជ្យដោយគ្មានជំនួយ សឹង-ង៉ុក-ថាន់ តាមអ្នកខ្លះអះអាងនោះទេ ។

ខ្ញុំសុំបើកវង់ក្រចកត្រង់នេះ ដើម្បីបញ្ជាក់ពីរឿង សឹង-ង៉ុក-ថាន់ ។ សឹង-ង៉ុក-ថាន់ នេះ ព្រះមហាក្សត្របានជួយរំដោះទុក្ខទោសគ្រប់បែបយ៉ាង សឹងមានលិខិតឈ្មោះនេះជាច្រើនផ្ញើមកថ្វាយព្រះអង្គជាករុណា ។ សឹង-ង៉ុក-ថាន់ បានរួចទោសហើយត្រឡប់មកប្រទេសខ្មែរវិញនៅថ្ងៃទី ៣០ តុលា ១៩៥១ ។

ព្រះអង្គបានឲ្យសួរចិត្ត សឹង-ង៉ុក-ថាន់ តើព្រមចូលធ្វើសមាជិករដ្ឋាភិបាលដែលមានឯកឧត្ដម ហ៊ុយ-កន្ធុល ជាប្រធានឬទេ ។ សឹង-ង៉ុក-ថាន់ មិនព្រមគឺរត់ចូលព្រៃ ដើម្បីប្រឆាំងនឹងបារាំង តែទ័ពខ្លួននៅសម្ងំតែក្នុងទឹកដីស្វ័យត្រាណសឹក សៀមរាប កំពង់ធំ បាត់ដំបង ដែលគ្មានទ័ពបារាំងមួយសោះ ហើយតាំងរបជាន់តែអ្នកស្រុកគ្នាឯង ។ លោក ឈួន-ម្ហុលពេជ្រ បានទទួលព្រះរាជបញ្ជា ពីព្រះអង្គទៅនិយាយនឹង សឹង-ង៉ុក-ថាន់ ឲ្យចូលរួបរួមជាមួយសម្ដេច ដើម្បីទាមទារឯករាជ្យឲ្យបានបរិបូណ៌ តែ សឹង-ង៉ុក-ថាន់ មិនព្រម ថាគេកសាងឯករាជ្យរៀងខ្លួន ។ ក្រោយមកគេដេរតាមវិទ្យុប្រមាថសម្ដេចទៀត ។ បើខ្លួនបង់រំដោះជាតិ

គួរណាស់តែ សឺង - ង៉ុក - ថាន់ តាំងទ័ពនៅក្រោមមណ្ឌលស្វ័យត្រាណ ដើម្បីនឹងតទល់នឹងទ័ព បារាំង ។ ខ្ញុំសុំស្ទះរឿង សឺង - ង៉ុក - ថាន់ តែប៉ុណ្ណោះ ។

ការស្វែងរកឯករាជ្យជាតិបរិបូណ៌ សម្ដេចមិនភ្លេចសោះឡើយ ទ្រង់ខិតខំឲ្យបានជូនជាតិឆាប់រហ័ស ហេតុនេះព្រះអង្គទ្រង់បានប្រកាស នៅថ្ងៃទី ១៥ មីនា ១៩៥២ ចំពោះបណ្ដារាស្ដ្រថាព្រះអង្គនឹងតាមទារ ឯករាជ្យជូនជាតិឲ្យបានបរិបូណ៌ក្នុងរយៈពេលបីឆ្នាំ ។

-តទៅនេះជាកំណត់ផ្សេងៗនៃព្រះរាជបូជនីយកិច្ច ៖-

ទី ១.- នៅថ្ងៃទី ៩ កុម្ភៈ ១៩៥៣ ព្រះអង្គទ្រង់យាងទៅប្រទេស បារាំងដើម្បីតាមទារឯករាជ្យជាតិ ។

- នៅក្រុងណាពូល "ប្រទេសបារាំង" ព្រះអង្គផ្ញើសារលិខិតចុះថ្ងៃទី១៨ មីនា ១៩៥៣ ទៅលោក វ៉ាំងសង់ - អូរីអុល ប្រធានាធិបតីប្រទេស បារាំង សុំឲ្យប្រទេសនេះពង្រីកឯករាជ្យខ្មែរព្រមតាំងស្មើរបៀបផ្ទេរអំណាចផ្សេងៗ ។

-ព្រះរាជសារពីរមួយចុះថ្ងៃទី១៨ មីនា ១៩៥៣ នាក្រុងណាពូល មួយទៀតចុះថ្ងៃទី ៣ មេសា ១៩៥៣ ហ្វុងតែនណាប៊្លូ សុំឲ្យរដ្ឋា-ភិបាលបារាំងប្រញាប់ដោះស្រាយរឿងឯករាជ្យនេះ ។

បរិបូណ៌ ១០០

ទី២-- ដោយចារាំង នៅតែព្រងើយ ឃើញថា កិច្ចព្រះអង្គទ្រង់យាង

ចេញដំណើរទៅប្រទេសកាណាដា ពេញលេញ សហរដ្ឋអាមេរិកនៅនោះ

ព្រះអង្គបានធ្វើសេចក្ដីថ្លែងការណ៍ចុះក្នុងសា ថៃឡង់ដ៍ ... យ៉ក តែម

ធ្វើឲ្យមហាជនចាប់អារម្មណ៍ជាពន្លឹក ។ ចារាំង ពិតគួរលោក អគា

ជាមួយព្រាកដតំណាងគឺសម្ដេច ប៉ែន - នុត ដែលបានឲ្យសម្បទាន

យាងធំដុំមកខ្មែរ ។ សម្ដេចប៉ែន - នុត យកសេចក្ដីនេះ មក

ទូលថ្វាយព្រះអង្គដោយបានត្រឡប់មកប្រទេសខ្មែរវិញថ្ងៃទី ១៦ ឧសភា

១៩៥៣ ។ ព្រះមហាក្សត្រខ្មែរទ្រង់យាងពីសហរដ្ឋអាមេរិកមក

គង់នៅប្រទេស ជប៉ុន ហើយវិលមកប្រទេសខ្មែរ ថ្ងៃទី ១៤ ឧសភា

១៩៥៣ ។ ប្រជាកស្ត្រខ្មែរបានទទួលព្រះអង្គជាទឡ្ហិក នឹងថ្វាយ

កត្តិយសមហាជោគជ័យ ។ ព្រះអង្គទ្រង់ថ្លែងនៅលើបន្ទាយាសន្យាថា

ព្រះអង្គទ្រង់បូជាជីវិតដើម្បីឲ្យបានឯករាជ្យបរិបូណ៌ ១០០ ភាគ ១០០ ។

ទី៣-- ដោយពិនិត្យឃើញថា កិច្ចព្រមព្រៀងនៅចារ៉ីសមិនដាច់

ស្រេចថាបានឯករាជ្យពេញលេញ សម្ដេចព្រះសីហនុទ្រង់និរទេស

ព្រះអង្គឯងទៅប្រទេស ថៃឡង់ដ៍ នៅថ្ងៃទី ១៣ មិថុនា ១៩៥៣

នៅនោះព្រះអង្គធ្វើសេចក្ដីថ្លែងបំភ្លឺមតិពិភពលោក អំពីការមិនពេញចិត្តនៃ

ប្រជាជាតិខ្មែរ នឹងអំពីមហាទុក្ខបំពោះលោកសេរី ។

ទី៤.-- ព្រះអង្គទ្រង់យាងមកមាតុប្រទេសវិញ ហើយទ្រង់តាំងទីបញ្ជាការនៅផ្នែកស្វ័យត្រាណសៀមរាប បាត់ដំបង កំពង់ធំ ។ ព្រះអង្គប្រកាសថាទ្រង់នឹងយាងត្រឡប់មករាជធានីវិញលុះណាតែបានឯករាជ្យពេញលក្ខណៈ ។

ទី៥.-- នៅពេលនោះហើយព្រះអង្គទ្រង់បង្កើតកងជីវពល និងនារីក្លាហានដែលនឹងមានមុខងារដាក់ស្នែងទៅថ្ងៃមុខ ។

នៅឯរាជធានី ភ្នំពេញ ក្រោមព្រះរាជបញ្ជាព្រះមហាក្សត្រ សម្តេច ប៉ែន - នុត ធ្វើកិច្ចចរចាបានសម្រេចទាំងអស់គឺ :

– នៅថ្ងៃទី ២៩ សីហា ១៩៥៣ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ទេរអំណាចតុលាការនិងសមត្ថកិច្ចប៉ូលិស ។

– ថ្ងៃទី ១៧ តុលា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើអធិបតេយ្យសឹកនៅក្នុងផ្ទៃប្រទេសទាំងមូលមកឲ្យខ្មែរ ។

– នៅពេលនោះអធិបតេយ្យខាងទូតក៏បានធ្វើឡើង ដោយលិខិតឆ្លើយឆ្លងរវាងប្រទេសខ្មែរនិងប្រទេសបារាំង ។

ទី៦.– នៅថ្ងៃទី ៨ កក្កដា ១៩៥៣ ព្រះបាទ នរោត្តម សីហនុ ទ្រង់យាងត្រឡប់មកកាន់ព្រះរាជធានីវិញ ។ នៅតាមផ្លូវចម្ងាយ ៣០០គ.ម. ប្រជាពលរដ្ឋចាំទទួលព្រះអង្គដោយអបអរសាទរជាពន្លឹក ។

ទី ៧.– នៅថ្ងៃទី៩កក្កដា ១៩៥៣ គឺ៨ខែមុនសន្និសីទហ្សឺណែវ ពិធីដកអំណាចទាំងអស់ពីបារាំងក៏មានធ្វើឡើងនៅមុខព្រះបរមរាជវាំង ។ ឯករាជ្យបរិបូណ៌ក៏មានតាំងពីថ្ងៃនោះមក ។

កាលបរិច្ឆេទដែលបានឯករាជ្យពេញទីនេះ ឃើញច្បាស់ណាស់ថា មុនសន្និសីទ ហ្សឺណែវ គ្មានការអ្វីឲ្យសង្ស័យសោះថាជាសន្និសីទនាក្រុងហ្សឺណែវ ផ្ដល់ឯករាជ្យឲ្យប្រទេស កម្ពុជា ដូចពាក្យមួលបង្កាច់ដោយអសុទ្ធចិត្តនៃបរបក្សទេ ។ សន្និសីទនេះគ្រាន់តែបានបង្ខំឲ្យពួកវៀតមិញដកទ័ពចេញពីប្រទេស កម្ពុជា ។

អំពីព្រះរាជសកម្មភាពនៃព្រះមហាក្សត្រកម្ពុជា

យើងបានឃើញនូវព្រះរាជបូជនីយកិច្ចនៃព្រះបាទ ព្រះនរោត្តម សីហនុ ចំពោះជាតិ ឯមហាក្សត្រខ្មែរមុនៗ ក៏តែងយកព្រះទ័យទុកដាក់ចំពោះផលប្រយោជន៍ប្រទេសជាតិនិងប្រជារាស្ត្រដែរ តទៅនេះខ្ញុំនឹងស្រង់ព្រះរាជសកម្មភាពនៃ ព្រះបាទអង្គឌួង និង ព្រះបាទនរោត្តម ។

អំពីព្រះបាទអង្គឌួង : មហាក្សត្រអង្គនេះពិតមែនតែព្រះអង្គទ្រង់កាន់ព្រះពុទ្ធសាសនាហើយរក្សាសន្តិភាព ព្រះអង្គតែងគិតដល់ទឹកដីខ្មែរ និងប្រជាពលរដ្ឋខ្មែរខាងត្បូងដែលយួនធ្វើទុក្ខបុកម្នេញ ហេតុនេះហើយព្រះអង្គចាត់ឲ្យសង់បន្ទាយតូចៗ នៅមុខខែត្រ ច្រូវ - ជុំកា

ហាទៀង ដើម្បីឲ្យទ័ពខ្មែរងាយវាយប្រហារយួន ដែលពេលនោះត្រូវទ័ពថៃបាញ់ពីក្រោយដែរ ។ ជាឱកាសល្អព្រះអង្គទ្រង់ទាក់ទងចងសម្ពន្ធ-មិត្តនឹងបារាំង ហើយព្រះអង្គទាមទារទឹកដីខាងត្បូង ដែលយួនរំលោភយកដោយឥតហេតុផល ។

នៅឆ្នាំ១៨៥៦ ព្រះបាទអង្គឌួងទ្រង់ផ្ញើព្រះរាជសារមួយទៀតទៅព្រះចៅណាប៉ូលេអុងទី ៣ ដើម្បីតវ៉ាយកទឹកដី កូសាំងស៊ីន ។

អំពីព្រះបាទនរោត្តម : ព្រះមហាក្សត្រអង្គនេះបានទ្រង់យាងទៅជួបលោកឧត្តមសេនីយនាវីឡាគ្រង់ឌីយែរ ឯក្រុងព្រៃនគរនៅឆ្នាំ ១៨៦៤ ហើយទ្រង់បានតវ៉ាឲ្យប្រទេសបារាំងប្រគល់ខេត្តបីមកខ្មែរវិញ គឺខេត្ត វិញឡុង សាដែក ត្រាវិញ ខេត្ត ចូវ-ដុក ឡុងសៀង កាំងចឺ ស្រុកត្រាំង នឹងខេត្ត ហាទៀង ក៏ឌីយ៉ែ ចាកលីវ ពីព្រោះសន្ធិសញ្ញាឆ្នាំ ១៨៦២ រវាង យួននឹងបារាំងដែលយួនឲ្យខេត្តទាំងនេះទៅ បារាំង ត្រូវអសារបង់ព្រោះជាទឹកដីខ្មែរ ។ បារាំង ក៏បានសន្យានឹងព្រះអង្គថានឹងគិតគូររឿងនេះ ព្រះអង្គយាងត្រឡប់មកនគរវិញនៅខែតុលា ១៨៦៤ ដោយសង្ឃឹមថានឹងបានទឹកដីខាងត្បូងមកមាតុភូមិវិញ ។

តែនៅឆ្នាំ ១៨៦៧ ព្រះចៅក្រុងវេ បានសមគំនិតឲ្យខ្មែរ ស្រុកយួនឆបះបោរទៀតដើម្បីឯករាជ្យ ក្នុងសាំងសុីន បារាំងក៏យកខេត្តតាំងបីខាងលើនេះដាក់ជាចំណុះ ហើយលែងរវល់នឹងកិច្ចសន្យាឲ្យដីនេះមកខ្មែរ ។ ព្រះបាទនរោត្តមនៅតែតាមតារ ដោយឈឺចាប់ តែឥតបានផល ។

ចំណែកឯប្រទេសខ្មែរវិញ រដ្ឋការសាណាព្យាបាលបារាំងបានធ្វើបាបព្រះអង្គ នរោត្តម ដកអំណាចពីព្រះអង្គអស់ ថែមទាំងកំហែងបន្ទ យកព្រះអង្គនិរទេសទៅកោះគ្រេឡាបទៀត ។ ព្រះអង្គទ្រង់បានបញ្ជូនព្រះរាជបុត្រព្រះនាម យុគន្ធរ ទៅតវ៉ាឯប្រទេសបារាំងទៀតតែឥតបានលទ្ធផល ។ នៅចុងក្រោយបង្អស់ដោយការឈ្លាសវៃ ព្រះអង្គទ្រង់ដឹកនាំដោយផ្លូវស្ងាត់ឲ្យរាស្ត្រប្រឆាំងនឹងបារាំង ដើម្បីដណ្តើមយកឯករាជ្យវិញ ។ គ្មានអ្នកណាអាចយល់ថា ព្រះអង្គជាមេប្រឆាំងឡើយ ។ តែមួយឆ្នាំក្រោយមក បារាំង បានប្តូរនយោបាយ បានល្បួងមេបះបោរឲ្យមកប្រជុំនៅកំពង់ធ្លួល ហើយឲ្យទទួលព្រមដាក់អាវុធដោយសំដែងភក្តីភាពចំពោះមហាក្សត្រ ។



ភ្នំភ្លើង

ភូមិសាស្ត្រថ្នាក់ទី ៩

ដោយ ឡុង - ជេង

# ប - អង្គការសង្គមកិច្ច

១ - អំពីវត្ត :

នៅក្នុងឃុំស្រុកមានវត្តបួន វត្តសំរោង - វត្តចំចាំ - វត្តត្រពាំងក្រូច - និង វត្តកំភ្លូច ។

វត្តមានមុខការច្រើនយ៉ាង :

- ជាទីតាំងនៃពុទ្ធសាសនា
- ជាសាលារៀនរបស់បព្វជិតខាងសាសនា
- ជាទីរក្សាទុកនិងផ្សាយនូវកេរ្តិ៍មរតកខាងវប្បធម៌ - ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ
- ជាសាលារៀនរបស់កុមារ - កុមារីខាងអក្សរសាស្ត្រ
- ជាទីទទួលផ្សាយនូវពត៌មានថ្មីៗ ហើយបែកជូនទៅអ្នកភូមិ
-

– ជាទីពិភាក្សាគេងគភាព សាមគ្គីភាព និងសេចក្ដីទុកចិត្តគ្នា ។ ដើម្បីដោះស្រាយនូវបញ្ហាការរស់នៅក្នុងឃុំ ។

២ – អំពីការជួយមនុស្សចាស់ ឬមនុស្សពិការ :

ពុទ្ធមាមិកជនយើងតែងជួយឈឺឆ្អាលគ្នាណាស់នឹងមនុស្សចាស់ ឬមនុស្សពិការ ។ គេជួយមនុស្សទាំងនេះដោយដាក់ទានជាលុយកាក់ ឬជាអង្ករ ។ វិធីជួយនេះ មិនអាចធ្វើឲ្យអ្នករងទុក្ខបានធូរស្រាលជួបនឹងសុភមង្គលបានគ្រប់ពេលវេលាឡើយ ។ វិធីជួយនេះ មិនទាន់ប្រពៃទេ ។ ឧទាហរណ៍ :– បង្កើតជាសួនសង់កេង - ប្រមូលមនុស្សចាស់ ឬពិការឲ្យមកនៅជួយថែរក្សាបង្រៀនកូនអ្នកភូមិតូចៗពេលអ្នកនោះទៅប្រកបរបរ ។ ឪពុក-ម្ដាយកុមារត្រូវផ្ដល់ឲ្យចាស់ ឬមនុស្សពិការវិញនូវបច្ច័យ - អង្ករ ។ល។ វិធីជួយរបៀបថ្មីនេះ ទាន់សម័យល្អណាស់ ។

៣ – អំពីពិធីបុណ្យផ្សេងៗ :

នៅរដូវប្រាំងពេលទំនេរ គេនាំគ្នាធ្វើបុណ្យជាច្រើនដង និងច្រើនកន្លែងក្នុងភូមិនីមួយៗ ។ មានបុណ្យដារ ឬបុណ្យកំសាន្តដារលាន បុណ្យកគញ្ញ បុណ្យរស្មីជាតិសម្រាប់ពង្រីកការសិក្សា បុណ្យបួងសួងសុំទឹកភ្លៀង ។ល។

ក – បុណ្យកំសាន្តផារលាន :- កាលណាផលស្រូវដាក់ផល់ផ្លែកហើយ អ្នកភូមិទាំងនោះគេសាមគ្គីគ្នាធ្វើបុណ្យផារ ឬបុណ្យកំសាន្ត ដោយសង់រោងនៅកាលស្រែជិតភូមិ គេនិមន្តលោកមកសូត្រមន្ត - សំដែងធម៌ទេសនា ប្រគេនគេសង្ឃ: ហើយព្រឹកឡើងប្រគេនចង្ហាន់ ។ ចំណែកអ្នកភូមិវិញ គេធ្វើនំបញ្ចុកទទួលភ្ញៀវ ។ គេអង្គាសអង្ករប្រគេនលោកសង្ឃ ។ នៅភូមិណាដែលបានផលស្រូវបរិបូណ៌ គេបង្កើតពិធីសមោសរគគ្រឹកគគ្រេងទៅដោយរបាំល្ខោន យីកេ ឬចម្រៀងចាប៉ីដែលគេជួលមកដើម្បីមហាជនទស្សនាកំសាន្ត ។

ខ – បុណ្យកតញ្ញូ : – ចំពោះឯកជន គេធ្វើរំឭកគុណមាតាបិតាដែលអនិច្ចកម្មទៅ ឬមួយធ្វើជូនរបស់ក្នុងពេលដែលគាត់រស់នៅដើម្បីឲ្យគាត់ប្រើប្រាស់ ឬដើម្បីឲ្យប្រគេនរបស់ដែលកូន - ចៅជូនដល់ព្រះសង្ឃដោយដៃគាត់ ។ បុណ្យនេះគគ្រឹកគគ្រេងណាស់ដែរ ។

គ – បុណ្យរស្មីជាតិ : – សម្រាប់ពង្រីកការសិក្សា អ្នកភូមិទូទៅនិយមធ្វើដើម្បីប្រមូលប្រាក់ ឬស្រូវយកមកប្រគល់ឲ្យគណៈកម្មការ ពង្រីកការសិក្សា ។

ឃ – បុណ្យបួងសួងសុំទឹកភ្លៀង : - បុណ្យនេះគេច្រើនធ្វើនៅទីទួលដើមពោធិ ឬ ទីទួលមានអ្នកតា ។ បុណ្យបួងសួងសុំទឹកភ្លៀងធ្វើប្លែកៗគ្នា

នៅពេលពំនីរងស្មូតអស់កាលជាយូរ ៗ ពេលបុណ្យគេលែងគ្រី លែងអណ្ដើកទៅក្នុងទឹក ជានិមិត្តរូបនៃសេចក្ដីសម្បូណ៌សប្បាយកើតអំពីទឹកភ្លៀង ៗ គេនិមន្តលោកសង្ឃទាំងអស់ដែលគង់នៅក្នុងវត្តមកសូត្រធម៌កណ្ដាលថ្ងៃ ៗ ព្រះសង្ឃសូត្រធម៌ "សុគោន្ដោ", គឺធម៌ប្រកាសប្ដឹងដល់ទេវតា ហើយសូត្រធម៌សុំទឹកភ្លៀង ១០០ បច់ ដោយកាច់ធូប បំណាំ មួយបច់កាច់មួង ៗ

ពិធីបុណ្យម្តង ៗ អ្នកស្រុករឹតចំណងសាមគ្គី ដោយឆ្លៀតឱកាសពិភាក្សា និងប្តូរយោបល់គ្នាពីបញ្ហាផ្សេងៗ ៗ

៤ – អំពីមរណភាព:

ពេលមានមរណភាពក្នុងភូមិ គ្រួសារនីមួយៗយកអង្ករ ១ ផ្ដិល និងប្រាក់ ៤ ឬ ៥រៀលទៅជួយសម្រាលទុក្ខគ្រួសារអភ័ព្វ ៗ

៥ – បញ្ហាសាលារៀន:

ពលរដ្ឋប្រជុំគ្នាបង្កើតគណៈកម្មការពង្រីកការសិក្សាតាមភូមិ ៗ យើងសង្កេតឃើញមានសាលាបឋមសិក្សាបំពេញវិជ្ជា ៣ កន្លែង:

១ – សាលាត្រាំខ្នារមានគ្រូ ១២ នាក់ និងសិស្ស ៤៨០ នាក់ ៗ

២ – សាលាវត្តចំចា – ៦ នាក់ – ២៦០ នាក់ ៗ

៣– សាលាវត្តត្រពាំងដក្រូចមានគ្រូ ៦ នាក់ និងសិស្ស

២៨០ នាក់ ។ ក្រោយពីពេលច្រូតកាត់ គេប្រជុំគ្នាតាមភូមិធ្វើបុណ្យកំសាន្ត ហៅថា បុណ្យដារលាន ។

៦ – មេរៀនសង្ខេប:

នៅក្នុងឃុំស្រុកមានវត្ត ៤ : វត្តសិរោង - វត្តចំប៉ា - វត្តត្រពាំងក្រោច និងវត្តកកោច ។ គេចេះជួយគ្នាពេលមានទុក្ខធុរៈ និងគ្រាមានអាសន្ន ។ គេយល់ច្បាស់អំពីបញ្ហាសិក្សា ។ គេនាំគ្នាសង់សាលារៀន នៅតាមភូមិសំរាប់កុមារ-កុមារីរៀនសូត្រ ។ គេសាមគ្គីគ្នាធ្វើបុណ្យកំសាន្តផ្សេងៗនៅតាមភូមិ ។

៧ – ការសិក្សាមជ្ឈដ្ឋាន:

យើងដើរសាកសួរ តើនៅក្នុងឃុំយើងមានវត្តប៉ុន្មាន ? វត្តនោះតាំងនៅភូមិណាខ្លះ ? ក្នុងវត្តនីមួយៗមានមនុស្សចំណុះវត្តប៉ុន្មាននាក់ ? តើគេមានបង្កើតកន្លែងសម្រាប់ប្រជុំគ្នា ជជែកគ្នា ពិភាក្សារកសេចក្ដីចំរើនឬទេ ? គេជំនុំគ្នាម្ដងម្កាលនៅទីណា ? តើគេជួយគ្នាដូចម្ដេចពេលមានធុរៈ គ្រាមានអាសន្ន ឬពេលធ្វើបុណ្យទាន ? ។

# ង - គ្រឿងការពារសុខភាពពលរដ្ឋ

កម្លាំងកាយក្ដី កម្លាំងបញ្ញាក្ដី រមែងដុះដាលបានដោយសារតែបុគ្គលមានសុខភាពគ្រប់គ្រាន់ ។ ដូច្នេះមនុស្សត្រូវតែសាងសុខភាពរបស់ខ្លួនជាមុនសិន ។

គ្រឿងការពារដល់សុខភាពពលរដ្ឋ មានមន្ទីរពេទ្យ កីឡា អាហារ និងទីលំនៅប្រកបដោយអនាម័យ ។

១ - មន្ទីរពេទ្យ:

នៅដំបន់ត្រាំខ្នារមានគិលានដ្ឋានមួយ សម្រាប់ពលរដ្ឋក្នុងឃុំ ។ តាំងពីមានគិលានដ្ឋានមក អ្នកភូមិភាគច្រើនលែងជឿគ្រូមេមត់ អារក្សអ្នកតា ។ នៅពេលយប់គេលែងឮស្គរស្គរលៀងអារក្សតាល់តែសោះ ។ ដោយមានជំនឿហើយទុកចិត្តលើវេជ្ជវិជ្ជា ពលរដ្ឋច្រើននាំអ្នកជម្ងឺទៅព្យាបាលនៅគិលានដ្ឋានត្រាំខ្នារ ។

២ - កីឡា:

កីឡាផ្ដល់ប្រយោជន៍ឲ្យអ្នកប្រព្រឹត្តបានច្រើនយ៉ាង គឺវាធ្វើឲ្យអ្នកប្រព្រឹត្ត មានពងកាយរឹងប៉ឹងមាំមួន មានបញ្ញាដុះដាល មានចិត្តស្មោះត្រង់មានមាឌស្វាហាប់ មានវីរិយភាពនិងសេចក្ដីក្លាហានក្នុងការ

សម្រេចចិត្ត ។ គេនិយមលេងល្បែងបុរាណ: ស៊ី - អង្គញ់ - ឈូង នៅពេលចូលឆ្នាំ ។ យុវជនភូមិយើងនិយមតែ កីឡាសម័យ ដូច បាល់ទាត់ បាល់ទះ បាល់បោះ ។ យើងឃើញកីឡាដ្ឋាន ៣ : នៅដំបន់ត្រាំខ្នារ នៅភូមិវត្តចំប៉ា និងនៅភូមិត្រពាំងក្រញូង ។ ក្រោយពីពេលប្រកបលៀងជីវិត យុវជននាំគ្នាលេងដោយរីករាយ ។ មានក្រុមខ្លះទៀតលេងបាល់ទាត់កណ្ដាលវាលស្រែ ។

៣ – អាហារ:

អាហារមិនគ្រាន់តែជួយទ្រទ្រង់ជីវិតឲ្យគង់វង់នោះទេ វាជួយផ្ដល់សុខភាព ផ្ដល់កម្លាំងពលំ និងឲ្យបញ្ញាប៉ិនប៉ីដុះដាលទៀត ។ កសិករយើងទទួលទានឲ្យបានតែឆ្អែតប៉ុណ្ណោះ ។ មុខអាហារគ្មានអ្វីឲ្យប្លែកពីគ្នាទេ ។ តែខ្វះត្រីសាច់ បន្លែនិងផ្លែឈើដែលមានគុណភាពល្អ ។ នៅរដូវប្រាំងក្រទឹក ម្ល៉ោះហើយក្មេងខ្វះការស្អាត ។

៤ – ទីលំនៅ:

លំនៅឋានអ្នកស្រុកគ្មានការសំអាតគ្រប់គ្រាន់សោះ ។ នៅក្រោមផ្ទះគេចងគោ គេតាំងទ្រុងមាន់ទ្រុងទា ។ គេគរលាមកសត្វទុកក្រោមផ្ទះ ។ ភូមិនីមួយៗគ្មានបង្គន់ គេនិយមបន្ទោបង់តាមគម្ពោតព្រៃ ។ អនាម័យក្នុងឃុំនៅអន់ថយណាស់ ។

លំនៅឋានរបស់មនុស្ស ត្រូវមានរមណីយភាពបរិបូណ៌ទើបសិរីសួស្តី កើតមានឡើងដល់អ្នកអាស្រ័យនៅ ។

៥– មេរៀនសង្ខេប :

ដើម្បីការពារសុខភាពរៀងខ្លួន ពលរដ្ឋម្នាក់ៗត្រូវតាក់តែងនឹងមន្ទីរពេទ្យ ត្រូវបរិភោគអាហារឲ្យបានគ្រប់គ្រាន់ ថែលំនៅឋានឲ្យមានរមណីយភាពហើយប្រព្រឹត្តកីឡាខ្លះផង ។ ការកំសាន្តនៅឆ្ងាយផ្ទះ នៅមាត់សមុទ្រ នឹងការអានទស្សនាវដ្ដីនាំឲ្យមានសេចក្ដីរីករាយ នឹងឲ្យអាយុយើងយឺនយូរផង ។

៦– ការសិក្សាមជ្ឈដ្ឋាន :

យើងនាំសិស្សធ្វើការអង្កេតតាមភូមិកុងឃុំ : មានមន្ទីរពេទ្យឬទេ ? តាំងនៅកន្លែងណា ? ហេតុអ្វីបានជាអ្នកជម្ងឺចូលចិត្តនាំគ្នាទៅព្យាបាលពេគនៅមន្ទីរពេទ្យ ? ហេតុអ្វីបានជា គេលែងលេងក្បួនការក្រដួបពីដើម ? ចូរអ្នកពិនិត្យមើលអ្នកលេងកីឡា មានមាឌដូចម្ដេច ? គេនិយមលេងល្បែងអ្វី ? ចូរពិនិត្យតាមភូមិ តើកសិករទទួលបានអ្វីខ្លះជាអាហារ ? ចូររកគុណសម្បត្តិ នឹងគុណវិបត្តិនៃអាហារ ចូរពិនិត្យមើលលំនៅឋានអ្នកភូមិ : ស្អាត ឬមមូម ? គេនិយមបន្ទោបង់នៅទីណា ? អនាម័យក្នុងឃុំមានល្បឿនដល់ណាហើយ ?

# ជ. អង្គការរដ្ឋបាល

នៅក្នុងឃុំស្រុក មានដំបន់រដ្ឋបាល គិលានដ្ឋាន បសុពេទ្យ សហករណ៍សាខា សាលារៀន ។

១– មុខងារមេឃុំ :

មេឃុំជានាយកលើឃុំ ហើយជាអ្នកដំណាងអំណាចរដ្ឋបាលនៅតាមឃុំ ។ ជាអ្នកកាន់សំបុត្រអត្រានុកូលដ្ឋាន (មរណភាព-កំណើត-អាពាហ៍ពិពាហ៍) ជាអ្នកផ្សះផ្សារឿងវិវាទ ។ មេឃុំទទួលបញ្ជាពីចៅហ្វាយស្រុកទៅចាត់ការផ្សាយដំណឹងដល់ពលរដ្ឋ ហើយនាំពត៌មានសំខាន់ៗ ក្នុងឃុំទៅជំរាបចៅហ្វាយស្រុក ។ ឃុំស្រុកីបែកជា ៨ ភូមិ ។ នៅតាមភូមិមានមេភូមិនឹងជំទប់ ដែលជាអ្នកយកពត៌មានពីមេឃុំទៅចាត់ការផ្ទាល់នឹងពលរដ្ឋ ។ មេឃុំតាំងការិយាល័យនៅដំបន់ត្រាំខ្នារមានស្មៀនម្នាក់នៅធ្វើការផ្ទាល់ មានជំទប់ ៤ នាក់ នឹងមេភូមិ ២ នាក់ ។

២ – អំពីសន្តិសុខក្នុងឃុំ :

សព្វថ្ងៃ បណ្ដាពលរដ្ឋក្នុងឃុំបានសុខសាន្តគ្រាណហើយគ្មានចោរខ្ញញ ។ គេលែងចាត់ការយាមល្បាតទៀតហើយ ។

មេឃុំត្រូវដឹកនាំអ្នកភូមិឲ្យធ្វើកាំជ្រួចបាញ់ទឹក ទុកការពារពេលមានអគ្គិភ័យ ។

៣– សេចក្ដីស្នើយោបល់ :

ពលរដ្ឋឯករាជ្យ មិនត្រូវរស់នៅក្នុងភាពងងឹតងងល់ទេ គប្បីអង្គាសប្រាក់គ្នាសង់សាលាប្រជុំ ដើម្បីពិភាក្សារកការចំរើនក្នុងភូមិ-ក្នុងឃុំ ។

– គួរបង្កើតបណ្ណាល័យមួយនៅតាមភូមិ ដោយទិញសៀវភៅ-កាសែត-ទស្សនាវដ្តីមកដំកល់ទុក ។

– សៀវភៅល្អទាក់មនុស្សឲ្យចូលចិត្តអាន ឲ្យស្រឡាញ់អក្សរសាស្ត្រ ។ កាសែតនាំដំណឹងផ្សេងៗ ព្រមទាំងធ្វើឲ្យមនុស្សយកចិត្តទុកដាក់ នឹងតាមដានស្ថានការណ៍ក្នុងស្រុកនិងក្រៅស្រុក ។

–ទស្សនាវដ្តីនាំវិជ្ជាផ្សេងៗ ឲ្យកសិករមានសង្គមកិច្ច-សេដ្ឋកិច្ចនិងវប្បធម៌ ។ សរុបទៅ បណ្ណាល័យជាឃ្លាំងឯកសារនៃវិជ្ជាជីវៈរបស់អ្នកស្រុក ។

៤ – មេរៀនសង្ខេប :

ក្នុងឃុំស្រកីមានដំបន់វេជ្ជបាល គិលានដ្ឋាន បសុពេទ្យ សហករណ៍សាខា និងសាលារៀន ៗ ឃុំស្រកីបែកជា ៨ ភូមិ ៗ នៅតាមភូមិ មានជំទប់ ៤ នាក់ និងមេភូមិ ២ នាក់ជួយមេឃុំ ដើម្បីចាត់ចែងការរដ្ឋការ ៗ មេឃុំតាំងការិយាល័យនៅដំបន់ត្រាំខ្នារ មានស្មៀនម្នាក់ជួយធ្វើការផ្ទាល់ ៗ

៥ – ការសិក្សាមជ្ឈដ្ឋាន:

យើងទៅស៊ើបសួរដល់ឃុំ: តើមានផ្នែករដ្ឋការអ្វីខ្លះតាំងនៅក្នុងឃុំ? ឃុំស្រកីបែកជាប៉ុន្មានភូមិ? ឃុំនោះមានជំទប់ប៉ុន្មាននាក់? មេភូមិមានប៉ុន្មាននាក់ជួយធ្វើការ មេឃុំផ្ទាល់និងពលរដ្ឋ? ការិយាល័យឃុំតាំងនៅទីណា? មេឃុំមានមុខងារដូចម្ដេចខ្លះ? ហេតុអ្វីបានជាគេលែងចាត់ឲ្យមានការយាមល្បាត? តើនៅតាមភូមិមានសង់សាលាជំនុំឬទេ? មានបណ្ណាល័យឬទេ? រកផលពីសាលាជំនុំ-បណ្ណាល័យ ៗ


ឃុំតាំងដូង
ភូមិឃុនពេង
ភូមិត្រពាំងក្រូច
ឃុំលំចង់
ភ្នំតូច
ឃុំជើងកេ
ភូមិសូភី
វត្តបំប៉ា
ភូមិត្រពាំងឫស្សី
ភូមិសំពេង
ភូមិយោលពោង
វត្តសំពេង
ឃុំជើងកេ
ភូមិជើងកូត
កុមារពេជា




# ការសិក្សាសិល្បៈ ក្នុងរង្វង់សាលារៀន (៣)

ដោយ ហាង់ - ជួន

អ្នកសំដែងសិល្បៈល្ខោន ខុសពីសិល្បករដទៃទៀតត្រង់ខ្លួនជាអ្នកប្រើឧបករណ៍ ហើយយកខ្លួនឯងធ្វើជាឧបករណ៍ថែមទៀត ។

យើងបានឃើញមកហើយថា ដើម្បីនឹងសំដែងសិល្បៈល្ខោនបានទាល់តែឧបករណ៍នោះមានលក្ខណៈល្អត្រឹមត្រូវសិន ។ តើឧបករណ៍ដែលយើងដាក់បង្កើតឡើងលើកមុនមានលក្ខណៈពេញលេញ ឬក៏យកទៅប្រើការបានហើយឬនៅ សូមអស់លោកគ្រូ-អ្នកគ្រូមេត្តាយកសិល្បករម្នាក់មកប្រៀបធៀបជាមុនសិនដើម្បីឲ្យងាយយល់ ។

អ្នកគូតន្ត្រីម្នាក់ទើបនឹងបានទ្រមួយថ្មី ទ្រនោះមានខ្សែ មានយ៉ង នឹងតាកត្រឹមត្រូវដូចទ្រផងទាំងពួងទៀតដែរ ... តែដើម្បីឲ្យអ្នកម្ចាស់អាចយកទ្រនោះទៅប្រើបាន តើអ្នកម្ចាស់ត្រូវដឹងអ្វីទៀតជាពិសេសដែរឬទេ គឺត្រូវដឹងពីសម្លេងទ្រនោះទៀត តើទ្រនោះមានសំឡេងយ៉ាងណា សំឡេងល្ហើយ ឬក៏មិនល្ហើយ បើគ្រាន់តែទ្រនោះមានរូបរាង

ក្រៅល្អ តែសំឡេងវាមិនពីរោះ ក៏យើងចាត់ទុកថាទ្រនោះពុំមែនជាឧបករណ៍ដែលអាចយកទៅប្រើបានឡើយ ។ ដូច្នេះ ក្នុងការបង្ហាត់សិស្សឲ្យមានដំណើរល្អ មានកាយវិការសមសួន ក៏ចាត់ទុកថា មិនទាន់គ្រប់គ្រាន់នៅឡើយទេ តោងយើងបង្រៀនអំពីរបៀបនិយាយ (diction) ទៀតទើបគ្រប់គ្រាន់ - - - ពិតមែនតែក្នុងពេលខ្លះយើងឲ្យសិស្សសំដែងតែកាយវិការទទេ តែទោះជាយ៉ាងណាក៏យើងត្រូវបង្រៀនសិស្សឲ្យចេះពីរបៀបនិយាយនេះទៀតដែរ បើនិយាយសរុបទៅគឺ ដំបូងបង្រៀនសិស្សឲ្យចេះប្រើកាយវិការ ក្រោយទៀតចេះនិយាយទៅតាមមនោសញ្ចេតនា នឹងកាយវិការទៀត ទើបចាត់ទុកថាជាឧបករណ៍មួយមានលក្ខណៈគ្រប់សម្រាប់យកទៅប្រើបាន ។






ការបង្ហាត់សិស្សឲ្យរៀននិយាយឲ្យបានត្រឹមត្រូវ ឲ្យចេះអានពាក្យឲ្យច្បាស់ ឲ្យចេះបញ្ចេញសំឡេងទៅតាមមនោសញ្ចេតនានេះជាមធ្យោបាយមួយសំខាន់ជួយសិស្សខ្មែរយើង ដែលមានភាគច្រើនមានគុណវិបត្តិក្នុងការនិយាយ ឬក៏ការអានជាដើម សិស្សខ្លះនិយាយញាប់ ខ្លះទៀតនិយាយដាច់ៗ ខ្លះទៀតអានពាក្យឬតួអក្សរមិនច្បាស់ ខ្លះនិយាយមិនឮ ខ្លះទៀតឮដែរតែទៅជាគំហក ។

## របៀបបង្រៀននិយាយ

ក្នុងថ្នាក់នីមួយៗ គ្រូគប្បីស្គាល់ច្បាស់ពីសិស្សរបស់ខ្លួន ដឹងថាសិស្សនេះនិយាយដូច្នេះ សិស្សមួយពួកនោះនិយាយដូច្នោះ ហេតុនេះគ្រូគប្បីជួយសិស្សបានដោយស្រួលក្នុងការបំបាត់គុណវិបត្តិទាំងនោះ ។

ដំបូងគ្រូគោងចែកសិស្សជាក្រុមតាមគុណវិបត្តិរបស់វាសិន រួចដាក់របៀបកែឲ្យសិស្សទម្លាប់ធ្វើនៅផ្ទះវាពេលព្រលឹមក្ដី ឬនៅសាលាមុនពេលចូលរៀនក្ដី - ។

យើងសូមជូនរបៀបកែគុណវិបត្តិខ្លះដូចតទៅ :

### សិស្សនិយាយញាប់

គ្រូគោងចាប់ឲ្យសិស្សនោះរៀនជាឃ្លាមួយ ខ្ញុំទៅសាលារៀន ឃ្លានេះគ្រូប្រាប់សិស្សឲ្យមកសូត្រឲ្យគ្រូស្ដាប់ រាល់ពេលព្រឹកមុនពេលចូលរៀន

ខ្ញុំ . . ទៅ . . សាលា . . រៀន -

## សិស្សដែលនិយាយដាច់ ៗ

ប្រើឲ្យរៀនឃ្លាដូចគ្នាដែរ តែបើអាចឲ្យបៀមដុំក្រួសមួយបានផងក្នុងពេលនិយាយទើបស្រួលជាង ។

## សិស្សនិយាយតែសំឡេងបែក

ឲ្យសិស្សរៀនឃ្លា ឬពាក្យពិបាក ឲ្យសូត្រឬនិយាយដោយខាំឈើតាក់ឆ្មេញ " ឈើស្ទង់ ,, ។ របៀបកែគុណវិបត្តិនេះ មិនធ្វើភ្លាមហើយបាត់ភ្លាមទេ បើអាចកែបានលុះត្រាតែសិស្សនោះខំដោយខ្លួនឯងធ្វើឲ្យទៀងទាត់នៅផ្ទះពេលក្រោកពីដំណេក . . .

— ក្នុងការបង្រៀនសិស្សរបៀបនេះ យើងមិនកំណត់ថា ថ្នាក់ណា ឬថ្នាក់ណាទេ គឺអាចបង្រៀននៅពេលដែលគ្រូបង្រៀនសិស្សគានធម្មតាក្នុងថ្នាក់រៀន ឬក៏ដាក់ឲ្យសិស្សធ្វើជាពិសេស ដូចបានដកបទាងលើនេះក៏បាន . . .

— ក្រោយពីគ្រូដឹងថា សិស្សចេះគានពាក្យច្បាស់ហើយ ចេះនិយាយមិនស្ទាក់ស្ទើរហើយ ទើបគ្រូត្រូវពន្យល់ឲ្យសិស្សចាប់អារម្មណ៍ពីការគាន ការសូត្រ ការពោល ការនិយាយដោយពឹងផ្អែកបច្ចេកទេសពីរយ៉ាងដូចតទៅនេះ

១ – សម្លេង

២ – ចង្វាក់

១ – សម្លេង៖ ពាក្យថាសម្លេងនេះ យើងគោលចាប់អារម្មណ៍ទៅលើសំឡេងមនុស្សទាំងអស់គឺមនុស្សម្នាក់មានសំឡេងមួយ សំឡេងនោះខុសពីគ្នាជានិច្ច ទៅតាមអាយុ ទៅតាមវណ្ណៈ ទៅតាមដំបន់ឬស្រុកដែលកើត ទៅតាមមុខរបរ ទៅតាមមនោសញ្ចេតនារបស់អ្នកនិយាយ ដូច្នេះ ការហាត់សំឡេងរបស់មនុស្សម្នាក់ឲ្យបានធ្វើសំឡេងគ្រប់របៀបដែលយើងបានដំរាបនេះជាការពិបាកណាស់ តែទោះជាយើងថាពិបាកក៏ដោយ បើយើងគ្រាន់តែបានណែនាំសិស្សឲ្យបាននិយាយបានច្បាស់ បានគានពាក្យឲ្យត្រូវតាមឃោសៈអឃោសៈ បាននិយាយឲ្យបានឮមិនគឹមគៀមនោះ ក៏ចាត់ថាយើងបានឈានមួយជំហានទៅក្នុងការសិក្សាសិល្បៈទៅហើយ –

អំពីកំពស់និងទំហំរបស់សំឡេង

កំពស់ ៖ សិស្សខ្លះនិយាយសំឡេងស្មារ គឺសំឡេងនៅទីក្បាល មួយជំពូកទៀតមានសំឡេងធំ គឺសំឡេងនៅដើមក សំឡេងទាំងពីរនេះ យកទៅប្រើក្នុងល្ខោនមិនល្អទេ សំឡេងល្អដែលត្រូវបង្ហាត់សិស្សឲ្យរៀននោះ គឺសំឡេងនៅក្នុងក្រអូមមាត់ព្រោះសំឡេងនេះនិយាយយូរ

បានមិនហត់ . . . យើងតែងឮអ្នកផងពោលថា និយាយច្រើនណាស់ ទាល់តែស្អកក

ឯសម្លេងនោះវិញ ក្រៅពីអ្នកស្តាប់ ស្តាប់មិនឮ ធ្វើឲ្យហត់ហួស នៅពេលដែលនិយាយ

២ – ចង្វាក់ : មុននឹងសិស្សដឹងថា អ្វីដែលធ្វើឲ្យមនុស្សយើងនិយាយទៅមានចង្វាក់ គេនឹងត្រូវឲ្យសិក្សារៀនពីដង្ហើមសិន ព្រោះដង្ហើមជាអ្នកធ្វើឲ្យមនុស្សនិយាយទៅមានចង្វាក់ ជាពិសេសក្នុងល្ខោនគេត្រូវតាមចង្វាក់នេះណាស់ –

បង្ហាត់ឲ្យសិស្សត្រួតដង្ហើម ហាត់បញ្ចេញបញ្ចូលខ្យល់ឲ្យបានវែង ហាត់អត់ដង្ហើម ហាត់ទប់ខ្យល់ឲ្យនៅនឹងក្បាល ឲ្យខ្យល់នៅដើមទ្រូង.. របៀបហាត់នេះ ធ្វើទាល់តែសិស្សហត់ហើយធ្វើរៀងរាល់ពេល រហូតដល់ទំលាប់ធ្វើដោយមិនដឹងខ្លួន –

ចេះប្រើដង្ហើមស្រួលបួលហើយទើបបង្ហាត់ឲ្យអានពាក្យឲ្យច្បាស់មួយម៉ាត់ ឲ្យបានវែង . . ឲ្យខ្លី . . ឲ្យញាប់ តាមចិត្តគ្រូបញ្ជាឲ្យធ្វើ រួចឲ្យចេះមើលអត្ថបទធម្មតា ដោយយកដង្ហើមទៅប្រើជាមួយផង ។

( នៅមានត )

# ផ្នែកផ្សាយបរិវត្តកម្ម





## ការរៀបចំដីឥដ្ឋ

យើងតែងសង្កេតឃើញថា វត្ថុផ្សេងៗដែលកើតឡើងពីដីឥដ្ឋ ដែលសិស្សតែងអនុវត្តឡើងនៅក្នុងសាលារៀន រមែងមានសភាពប្រេះឆា ឬបាក់ក៏សឹងមាននៅពេលហាលស្ងួត ដែលនាំឲ្យសិស្សអស់សង្ឃឹម ក្នុងការសិក្សាមុខវិជ្ជានេះ ។

យើងសូមបញ្ជាក់ថា : ការប្រេះឆាទាំងនេះបណ្ដាលមកអំពីហេតុផលច្រើនយ៉ាងដូចតទៅ :

១– ដីឥដ្ឋមិនស្អាត មានកំទេចកំទី ស្លឹកឈើ មែកឈើ ល្អិតៗក្រួស សំបកខ្យងខ្ចៅ ។ ល ។

២– ដីឥដ្ឋមានពពុះខ្យល់នៅខាងក្នុង បិទមិនសព្វ

៣– ហាលនៅពេលក្ដៅពេក

វិធីចៀសវាងវិបត្តិអាក្រក់បែបនេះ

១– ត្រូវប្រមូលដីឥដ្ឋមកហាលឲ្យស្ងួត

២– រាយបំបែក  រើសយកកំទេចកំទីមិនស្អាតចោលចេញ

៣– កិនឲ្យល្អិត  ឬបុកឲ្យផង់ដូចម្សៅ

៤– ទុកក្នុងពាង  ឬបាវក្រដាស  ដាក់នៅកន្លែងស្ងួត

ពេលអនុវត្ត

១– យកម្សៅដីឥដ្ឋមកលាយនឹងទឹកប្រមាណឲ្យល្មម

២– ច្របាច់  ប៉ន់ដីឥដ្ឋឲ្យបានលាយសព្វ



កាត់នឹងខ្សែលួសបំបែកជាពីរ



៤ – បើឃើញមានកន្លែងខ្មួង១ គឺបានសេចក្ដីថា នៅមានពពុះខ្យល់នៅ



ឡើយ ។ ចូរបន្ថែមទៀតឲ្យបានច្រើនជាងហើយកាត់ដូចរបៀបខាងលើនេះ លុះត្រាតែលែងមានខ្ទង់ៗ ទៀត ទើបសន្មតថាដីរបស់យើងរលាយសព្វ ។



៥ – ដល់កើតបានជារូបរាងហើយ ត្រូវហាលក្រោមកំដៅតិចៗឬទុកសំដិលក្នុងម្លប់ឲ្យស្ងួតនោះរឹងរឹតតែល្អទៅទៀត ។

៦ – បើចង់ឲ្យស្ងួតឆាប់ ត្រូវហាលពីព្រលឹមរហូតទៅក៏បាន ។

៧ – បើចង់ដុតឲ្យរឹតតែរឹងថែមទៀតក៏បាន តែត្រូវឲ្យបានស្ងួតសព្វល្អជាមុនសិន « ដំបូងត្រូវកុំឲ្យក្តៅខ្លាំងពេក » ។

យើងសូមជូនគំរូមួយ អំពីការបោះដីឥដ្ឋមានផ្ទៃរាបស្មើ សម្ភារៈ បំពង់ឫស្សី ឬដុំឈើមូលទ្រវែង កាំបិតតូចមួយ ៗ

ប្រអប់ដាក់កំទេចបារី

១ – យកដីឥដ្ឋមកកិនឲ្យរាបស្មើ :



២– កាត់កងបាត

៣– កាត់កងផ្ទៃខាងលើ

៤– កាត់កងផ្ទៃជុំវិញ



របៀបធ្វើ

១– ត្រូវយកបុនកាំបិត ឬវត្ថុស្រួចមកឆូតត្រង់កន្លែងដែលត្រូវកាប់ ឬប៉ះឲ្យមានសភាពប្រាញៗ ទាំងសងខាង ។

២– បន្តក់ទឹកឡេស៊ើមរួចយកមុខទាំងពីរមកភ្ជាប់

៣– យកបុនកាំបិត ឬឈើសំប៉ែតមកបៀកភ្ជិតមុខជាការស្រេច ។





# កសិកម្ម

—៦

ស្រង់ចេញពីទស្សនាវដ្ដីកសិកម្ម

## របៀបដាំបន្លែ

### ១ – ផលប្រយោជន៍នៃបន្លែ :

បន្លែជាមូលដ្ឋាននៃអាហាររបស់មនុស្សយើង ហើយជាប្រភពនៃជីវជាតិគ្រប់ឈ្មោះដែលហៅថា (Vitamine) ។ ដូច្នេះ ការបរិភោគបន្លែជាការចាំបាច់ណាស់ គឺអាចធ្វើឲ្យយើងមានសុខភាពល្អនិងកម្លាំងពលំពេញបរិបូណ៌ ដែលអាចឲ្យយើងប្រកបការហត្ថកម្មបានគ្រប់ជំពូក ។

កសិករ អាចយកផលបន្លែទៅលក់ឯផ្សារបានទៀត បើកាលណាបានផលលើសពីសេចក្ដីត្រូវការក្នុងគ្រួសារ ។ ម្យ៉ាងទៀតការប្រើប្រាស់បន្លែក្នុងចំណីអាហាររាល់ ១ ថ្ងៃ អាចប្រព្រឹត្តទៅបានដោយមិនបាច់ទិញដូរឡើយ ជាហេតុនាំឲ្យសល់នឹងចំរើនថវិកាក្នុងគ្រួសារទៀតផង ។

### ២ – ការជ្រើសរើសដី ដើម្បីដាំបន្លែ :

ត្រូវជ្រើសដីដែលខូវល្អ ហើយនៅជិតមេទឹកដូចជាត្រពាំង បឹងបួ ព្រែក ស្ទឹង អូរ ឬ អណ្ដូង ព្រោះបន្លែត្រូវការទឹកជាទីបំផុត ឬរកដីដែលនៅជិតផ្ទះ ដើម្បីស្រួលដល់ការថែទាំបន្លែស្រោចទឹក បោចស្មៅ ហើយ

ទីដែរគេដីមិនជាំទឹក មិនលិចទឹក ហើយគប្បីឲ្យស្រឡះផុតពីម្លប់ឈើផង ។ ដើមឈើធំដែលនៅកិតសួនបន្លែជារបាំងខា ខាំង មិនឲ្យទឹកសន្សើមធ្លាក់ចុះបាន ។ ទឹកសន្សើមនេះជាធាតុមួយសំខាន់ណាស់ក្នុងការធ្វើឲ្យបន្លែដុះលូតលាស់បានល្អ ។



៣ – របង :

ត្រូវធ្វើរបងព័ទ្ធជុំវិញសួនបន្លែ ដើម្បីកុំឲ្យសត្វមាន ឆ្កែ ឆ្មា មាន់ ទា ជ្រូក គោ ក្របី ជាដើម ចូលបំផ្លាញផលដំណាំបាន ។

៤– ការរៀបចំដី :

កាប់ដីជំរៅពីរបីចកាប់ ឬភ្ជួរដីឲ្យបានជ្រៅ រួចរាយបំបែកដីឲ្យបានម៉ដ្ឋល្អ ដែលជាហេតុអាចហុចលទ្ធផលល្អ ដូចតទៅនេះ–

ក– អាចធ្វើឲ្យធាតុអាកាសនិងទឹក ចូលទៅក្នុងដីដោយងាយ –

ខ– អាចធ្វើឲ្យដីផុយជាហេតុនាំឲ្យឫសរុក្ខជាតិចាក់ដុះបែកខ្នែងបានស្រួល –

គ– អាចធ្វើឲ្យរុក្ខជាតិស្រូបយកជាតិសើម ដែលមាននៅក្នុងដីនៅពេលរាំងស្ងួត–

ឃ– អាចធ្វើឲ្យទឹកជ្រាបចូលទៅក្នុងដីជ្រៅបានបរិបូណ៌ នៅពេលភ្លៀង –

ង– អាចធ្វើឲ្យដីសើមបានយូរ ឬអាចបង្កាំងទឹកទុកបានយូរ ៗ



## ៥– របៀបធ្វើថ្នាលព្រោះគ្រាប់ពូជ :

ថ្នាលមានទទឹងពី ០,៩០ម ទៅ ១,០០ម បណ្ដោយតាមស្រេចតែចិត្ត បង់ធ្វើកំពស់ ០,១០ម ឬ ០,១៥ម ។ បើនៅរដូវភ្លៀង គេត្រូវបណ្ដុះគ្រាប់បន្លែនៅក្នុងឡាំងធ្វើអំពីឈើ ដែលមានទទឹង ០,៥០ម ឬ ១ម៉ែត្រ បណ្ដោយ ០,៥០ម ឬ ១ម៉ែត្រ ជំរៅ ០,៥០ម ហើយមានជើងទ្រឲ្យផុតពីដី ។ នៅក្នុងឡាំង យើងដាក់ដីស្អុតផុស ហើយមានជីជាតិល្អ ។ របៀបព្រោះក្នុងឡាំងអាចសម្រួលដល់ការលើកចុះលើកឡើង និងការថែទាំ ។



២– របៀបដាក់ដីមុនពេលព្រោះគ្រាប់ :

កាលណាយើងលើកថ្នាលបានត្រឹមត្រូវហើយ យើងត្រូវយកដីមក
ាយឲ្យស្មើ រួចកាប់គ្រឡប់ឲ្យដីគ្រឡប់ទៅក្នុងដី ។ របៀបដាក់ដី
ត្រូវដាក់ :




– ដីលាមកគោ : ៣ គ.ក ក្នុងដី ១ ម៉ែត្របួនជ្រុង

– ដីជាតិគីមី : ១៣-១៣-១៣-៣០ ក. ក្នុង១ម២

– ដីលាមកមាន់ : ៣០០ក. ក្នុងដី ១ ម៉ែត្របួនជ្រុង

៣ – ការជ្រើសរើសពូជបន្លែ :

ត្រូវរើសយកពូជបន្លែណា ដែលមានគុណភាពល្អយកទៅដាំព្រោះ
ជល្អតែងឲ្យផលល្អជានិច្ច ទោះបីជារុក្ខជាតិ សត្វ ឬ មនុស្សក៏ដោយ ។
ករដែលកសិករនិយមរកពូជបន្លែល្អៗ ដែលបានមកពីក្រុមកសិកម្ម យក
ៅដាំយូរៗ ទៅអាចបំបាត់ពូជមិនល្អចេញអស់ ហើយដាំតែពូជល្អៗ វិញ ។

៨ – រដូវធ្វើបន្លែពីខែកញ្ញាទៅកុម្ភៈ

លើកលែងតែ រ៉ាឌីស (Radis) ការ៉ុត (Carotte) បែតរ៉ាវ និង ឆៃថាវចេញ គេអាចដាំបន្លែបានគ្រប់ពេល ប៉ុន្តែ ពេលល្អបំផុត គឺពីខែកញ្ញាទៅកុម្ភៈ ។ ដំណាំដែលដាំនៅក្នុងកំឡុងខែនេះច្រើនតែឲ្យពូជច្រើន ហើយគ្រាប់ក៏មានគុណភាពល្អទៀតផង ។

៩ – របៀបព្រោះឬសាបគ្រាប់បន្លែ :

គ្រាប់បន្លែល្អិតៗ គេត្រូវយកទៅលាយនឹងផេះ ឬដីខ្សាច់ល្អិត ។ គ្រាប់មួយភាគត្រូវលាយជាមួយនឹងដីខ្សាច់ ឬ ផេះមួយភាគ ការលាយរបៀបនេះប្រយោជន៍ដើម្បីងាយពាយគ្រាប់ឲ្យបានស្មើល្អ កុំឲ្យក្រាស់ពេក « នាំឲ្យខាតគ្រាប់ច្រើន នាំឲ្យកូនបន្លែដុះឆ្មារៗពេក និងនាំឲ្យកើតជម្ងឺម្យ៉ាងហៅថាជម្ងឺផ្សិត » ។ លាយគ្រាប់នឹងខ្សាច់ ឬ ផេះ ហើយយកទៅបាចឲ្យស្តើងៗ លើថ្នាល ឬ ឡាំងឈើដែលបានរៀបចំដីត្រឹមត្រូវសំរាប់ព្រោះគ្រាប់ ។ រួចត្រូវពាយដីម៉ដ្តពីលើស្តើងៗថែមទៀត ។ បន្ទាប់មកទៀតត្រូវយកចំបើងកាត់ជាកំណាត់ខ្លីៗ ១,០៥ម ទៅពាយពីលើដើម្បីជួយឲ្យជប់ទឹកទុកបានយូរនៅលើរង និងដើម្បីកុំឲ្យគ្រាប់រត់ទៅនៅផ្តុំគ្នាកាលណាស្រោចទឹក ។ ត្រូវស្រោចទឹកឲ្យថ្នមដោយប្រើធុងសម្រាប់ស្រោចមានចំពួយផ្កាឈូក ។ ស្រោចរួចត្រូវយកថ្នាំ ដេ ដេ តេ ទៅពាយ

ជុំវិញថ្នាល ដើម្បីការពារសត្វស្រមោចកុំឲ្យចូលបាន រួចត្រូវគ្របវាំង ឬ ឡាំងឈើចំនួនពីរថ្ងៃ ។

សេចក្ដីបញ្ជាក់: ចន្លៃណាដែលដាំយកដើម គេមិនដកស្ទូងឡើយ គឺ គេព្រោះជាជួរយកតែម្ដង ដូចជា ក៏ឆីស ការ៉ុត ឆៃថាវ នឹង បៃតិក៉ាវ ។ល។

១០ – របៀបធ្វើថ្នាលសម្រាប់ស្ទូងក្ដូចបន្លែ

ក – ធ្វើថ្នាល

– ទទឹង : ១,០០ម. ទៅ ១,២០ម -

– បណ្ដោយ: តាមទំហំដីដែលធ្វើទៅបាន -

– កំពស់: ០,១០ម ទៅ ០,២០ម -

១ – ដាក់ជី

– ជីលាមកគោ ឬ ជី ផ្សំ ៩ គ.ក. ក្នុងដីមួយម៉ែត្របួនជ្រុង

– ជីលាមកមាន់ ៤០០ ក.

– ជីគីមី ១៣-១៣-១៣.៤០ ក.

១១ – របៀបដាំ ឬ ស្ទូងក្ដូចបន្លែ:

គេត្រូវស្ទូងនៅពេលរសៀល ដើម្បីកុំឲ្យស្រពោកកូនចន្លៃ ដោយ កំដៅថ្ងៃនៅពេលស្ទូងដំបូង ។ ត្រូវយកតែកូនណាដែលមានដើម ថ្លោសមាំហើយមានសភាពល្អយកទៅដាំ មុននឹងដកស្រោចទឹកឲ្យច្រើន ។

ដកយកទៅស្ទូងបានតែកូនបន្លែណាដែលមានអាយុដូចខាងក្រោមនេះ ៗ

- សាលាដ : ពី ២១ ទៅ ២៥ ថ្ងៃ
- ស្ពៃ : – ២៥ – ៣០ –
- ប៉េងប៉ោះ ត្រប់ : ១ខែ

ជាការងាយសំគាល់ គួរដកយកទៅស្ទូងតែកូនបន្លែណាដែលមានស្លឹកពី ៤ ទៅ ៥ សន្លឹក ៗ

ក – ចម្ងាយជួរ «ចន្លោះ»

- សាលាដ : ០,២០ម. ពីជួរមួយទៅជួរមួយ
  ០,៣៥ម. ពីគុម្ពមួយទៅគុម្ពមួយ
- ស្ពៃ : ០,៣៥ម. ពីជួរមួយទៅជួរមួយ
  ០,៤០ម. ពីគុម្ពមួយទៅគុម្ពមួយ
- ប៉េងប៉ោះ ឬ ត្រប់ : ១ ម៉ែត្រ ពីជួរមួយទៅជួរមួយ
  ០,៧០ម ពីគុម្ពមួយទៅគុម្ពមួយ

១ – ត្រូវគ្របក្ដួលបន្លែចំនួន ៤ ថ្ងៃក្រោយពេលស្ទូង

១២ – ការថែទាំសួន

ត្រូវស្រោចទឹកព្រឹកល្ងាច ហ៊ុបស្មៅ ជ្រួយដី ពូនគល់ ស្រោចដី ៗ បាញ់ថ្នាំ កាលណាមានសត្វល្អិតមកយាយីបន្លែ ៗ



សេចក្ដីបញ្ជាក់

បន្លែណាដែលបាញ់ថ្នាំរួច មិនអាចយកមកបរិភោគបានភ្លាមទេ ព្រោះអាចពុលដល់មនុស្សយើង គេអាចយកទៅបរិភោគបានក្នុងរវាង ១៥ ថ្ងៃក្រោយមក ។ ត្រូវលាងនឹងទឹកស្អាតសិនមុនបរិភោគ ពីព្រោះជាតិថ្នាំពុលដែលនៅជាប់នឹងស្លឹក ឬ ផ្លែនៅមានជាតិពុលនៅឡើយ ។ ហើយអាចឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ផង ។

## ១៣ – ការទុកពូជបន្លែ

បើចង់បានពូជ ត្រូវរើសទុកដើមបន្លែណាដែលមានសភាពទ្រង់ទ្រាយល្អ ហើយថែរក្សាទុកឲ្យរីកផ្កា កាលណាទុំមែនទែនហើយ ត្រូវបេះយកគ្រាប់ទៅហាលសំដិលក្នុងម្លប់ឲ្យស្ងួត រួចយកទៅដាក់ក្នុងកែវបិទឲ្យជិត ទុកសម្រាប់ដាំទៅពេលក្រោយទៀត ។ ឯចំណែកកូនប៉េង-ប៉ោះ ត្រប់វិញ យើងត្រូវរើសផ្លែទុំធំល្អៗ តាំងពីដំបូងដែរ ។ ត្រូវយកចានដែកដាក់ទឹកល្មម ហើយវះប៉េងប៉ោះ ឬ ត្រប់ដាក់ចូលទៅក្នុងចាននោះ រួចច្របាច់យកតែគ្រាប់ ។ ត្រូវលាងទឹក ៣ ឬ ៤ សាឲ្យអស់រអិល ហើយស្រង់យកតែគ្រាប់មកហាលថ្ងៃ ។ ការហាលថ្ងៃ ត្រូវហាលឲ្យក្ដៅល្មម មិនត្រូវហាលថ្ងៃកំពុងក្ដៅពេកទេ ។ បើក្ដៅខ្លាំង ត្រូវហាលកន្លែងណាដែលមានពន្លឺថ្ងៃចូលល្មម ។ ត្រូវហាលគ្រាប់ឲ្យស្ងួតមែនទែន ទើបយកមកដាក់ក្នុងកែវបិទឲ្យជិតទុកដាំនៅពេលក្រោយ ។



# អនាគតនៃមាតា (ត)

ប្រែសម្រួលពីសៀវភៅ : Eamily Nursing And Thildcare by C. Luise Riehl R.N.

ដោយអ្នកស្រី ខែម - សំអុល

ចំណីអាហារ — អនាគតនៃមាតា មិនគ្រាន់តែត្រូវថែរក្សាខ្លួនឲ្យបានត្រឹមត្រូវតាមលក្ខណៈដោយមិនហ៊ានធ្វើការធ្ងន់ៗ ឬទៅមន្ទីរព្យាបាលពេលឲ្យញឹកញយប៉ុណ្ណោះទេ ពិសេសទៅទៀតយើងគប្បីបរិភោគតែចំណីអាហារណាដែលអាចផ្ដល់សុខភាពល្អ ដល់ខ្លួនយើងនិងទារក ព្រោះថាទារកដែលស្ថិតនៅក្នុងផ្ទៃម្ដាយ អាចរីកចំរើនឡើងបានដោយសារចំណីអាហារ ដែលម្ដាយបរិភោគ ។

យើងត្រូវដឹងថា ទារកត្រូវការអាហារចិញ្ចឹមជីវិតតាមចំណង់ម្ដាយទាំងអស់ បើម្ដាយបរិភោគអាហារបានគ្រប់គ្រាន់ហើយមានជីវជាតិល្អ ទារកក៏បានធាត់ធំល្អទៅតាមនោះដែរ ។ ផ្ទុយទៅវិញ បើម្ដាយបរិភោគអាហារមិនគ្រប់គ្រាន់ ហើយពុំសូវមានជីវជាតិទៀត ដូចជាការ

មិនបានញុំាទឹកដោះគោដែលមានជាតិ ( calcium ) និង (phosphore) នោះដល់ទារកកើតមកតែងមានធ្មេញពុំសូវល្អ រេចរ ដង្កូវស៊ី-ធាប់ធាក់ ៗ គុណវិបត្តិរបស់ទារកខាងលើនេះ ជាចំណុចមួយដ៏យ៉ាងច្បាស់ឲ្យយើងដឹងថា ទារកនៅក្នុងទេមា្តយ ត្រូវផ្ដេកផ្ដួលរស់នាល្អអាស្រ័យនៅលើម្ដាយទាំងស្រុង ៗ



ហេតុនេះ សុខភាពដ៏គ្រប់គ្រាន់របស់ទារកនោះគឺ :

១– ត្រូវបរិភោគទឹកដោះគោ បន្លែស្រស់ៗខ្ចីៗ សាច់-ស៊ុត-ត្រីព្រោះអាហារទាំងនេះអាចធ្វើឲ្យម្ដាយមានសាច់ឈាមល្អ ៗ

២– ត្រូវបរិភោគអាហារដែលមានជាតិលោហធាតុ ( minéraux )

ដើម្បីធ្វើឲ្យឆ្អឹងរឹងមាំ ធ្មេញដុះល្អ ហើយមិនងាយពុកទៀតផង ដូចជា ទឹកដោះគោ គ្រាប់រុក្ខជាតិ ផ្លែឈើនិងបន្លែ ។

៣– ជីវជាតិនានា អាចធ្វើឲ្យបានកម្លាំងល្អដូចជាផ្លែឈើ សាច់ដែល មានឈាមស្រស់ៗ ដូចជាសាច់គោ ខ្លាញ់ទឹកដោះគោ ( beurre ) គ្រាប់រុក្ខជាតិខ្ចីៗដូចជាសណ្ដែកបាយ-សណ្ដែកដី-ល្ង ។ល។ រីឯកាហ្វេ នឹងតែវិញបើយើងញ៉ាំបន្តិចបន្តួចឬយូរម្ដង ឬក៏បេះលៃឲ្យល្មមនោះ គ្មាន គុណវិបត្តិអ្វីទេ ។ ផ្ទុយទៅវិញបើយើងទទួលទានច្រើនតាមចំណង់នោះ នឹងនាំឲ្យខានដល់ដំណេក កាលណាដំណេកមិនបានហើយ កម្លាំង ទន់ខ្សោយរហូតរហៃ ។ ចំណែកតែវិញ បើញ៉ាំច្រើននឹងនាំឲ្យ ទល់លាមក ។

អនាម័យទូទៅ : ស្ត្រីមានគភ៌ មិនត្រឹមតែបរិភោគអាហារ ឲ្យបានគ្រប់គ្រាន់ប៉ុណ្ណោះទេ គឺត្រូវស្ថិតនៅក្នុងភាពសប្បាយរីករាយ ក្សេមក្សាន្តជានិច្ច ។ ត្រូវទទួលនូវពត៌មានណា ដែលអាចផ្ដល់នូវ ការសប្បាយរីករាយ នឹងសុភមង្គលដល់គ្រួសារ ។ បើមានពេល ទំនេរ យើងត្រូវបោះតុបតែងខ្លួន ស្លៀកពាក់ឲ្យស្អាតបាត ដើម្បី ចំអសម្រស់ នឹងបំបាត់ការភៀនខ្មាស ព្រោះនៅពេលនោះ ស្ត្រីមាន គភ៌កាន់តែមិនសមរម្យដូចពីដើមទេ ។

ចាប់ពី ៨ ខែទៅស្ត្រីមានគភ៌ កុំអង្គុយបញ្ឈរជង្គង់ ឬប្រហោងឡើយ ព្រោះនាំឲ្យត្បៀតឬគាបទារកនៅក្នុងផ្ទៃ ។

ក - ទស្សាហ៍ទៅមន្ទីរពេទ្យបាលពេត ដើម្បីមើលផ្ទៃ-មើលធ្មេញ ។

ខ– ត្រូវដុសលាងខ្លួន - សុដននឹងទឹកក្ដៅឧណ្ហៗ ឲ្យបានស្អាតដើម្បីឲ្យជ្រះក្អែល កុំឲ្យក្អែលនៅរាំងរន្ធសុដន ដែលអាចឲ្យមានគ្រោះថ្នាក់ដល់ពេលទារកបៅ ។

គ– បរិភោគតែអាហារណា ដែលឆាប់រលាយបៀសវាងចំណីដែលហឹរ ។

ឃ– សម្រាកកម្លាំង កុំធ្វើការច្រើនពេក-កុំដើរឆ្ងាយពេក កុំអង្គុយច្រើនពេក កុំលើករបស់ធ្ងន់ៗ ត្រូវទទួលទានដំណេកយ៉ាងហោចណាស់ឲ្យបាន ៨ ម៉ោងក្នុង ១ ថ្ងៃ ។

សេចក្ដីសង្ខេប ៖– អនាគតនៃមាតា កាលណាបើបានដឹងថាខ្លួនមានគភ៌ហើយ គប្បីថែទាំខ្លួនឲ្យបានមធ្យ័ត កុំធ្វើការឲ្យនឿយហត់ហួសប្រមាណ ត្រូវបរិភោគអាហារឲ្យបានគ្រប់គ្រាន់ ដូចបានពោលមកខាងដើម ដើម្បីឲ្យសុខភាពនឹងអនាគតដ៏រុងរឿងបានគាប់ប្រសើរ របស់ទារកដែលចូលមកផ្ញើវសនាលើខ្លួនយើង ។



# អនាម័យ សិក្សា

## ការបំរើសុខភាពនៃកុមារ (ត)

តើហេតុអ្វី បានជាត្រូវយកចិត្តទុកដាក់ជាប់ដោយឡែកពីគេចំពោះ
សុខភាពនៃពលរដ្ឋក្នុងបឋមវ័យ ?

តើអនាម័យសិក្សាដែលជាអង្គការ សំរាប់ទទួលពិនិត្យសិស្សពីអាយុ ៣ ដល់ ១៨ ឆ្នាំ មានប្រយោជន៍យ៉ាងណាខ្លះ?

ម្តេចក៏ចាំបាច់ឲ្យមានផ្នែកអនាម័យពិសេសនេះ ?

—ព្រោះថា យុវជនទាំងឡាយ សុទ្ធតែស្ថិតនៅក្រោមអំណាច ច្បាប់ទូទៅរួមគ្នាតែមួយ គឺជាធម្មភាពដែលទ្រទ្រង់ការលូតលាស់ចំរើន ខាងរូបកាយ ខាងបញ្ញា និងខាងសង្គម ។

អាយុបាន ៣ ឆ្នាំ កុមារទាំងឡាយមានទម្ងន់ប្រហែល ១៤ គ.ក ហើយមានកំពស់ប្រមាណ ០,៩០ម ។ ផ្លូវកាមគណ្ហាពុំទាន់កើតមាននៅឡើយទេ ឯខាងបញ្ញាវិញ គេសង្កេតឃើញមានដុះដាលខ្លះហើយ

គ្រាន់តែមិនទាន់មានសម្បទាខាងការវិភាគរកសំយោគដើម្បីសន្និដ្ឋាន នូវហេតុការណ៍ណាមួយឲ្យច្បាស់លាស់បាន ។ ក្នុងវ័យនេះ ក្មេងមិនទាន់ស្គាល់សង្គមណាដាក់លាក់ក្រៅពីសង្គមគ្រួសារឡើយ ហើយវាយល់ថាជាការធម្មតា របស់ណាដែលវាត្រូវការចង់បានតាមចិត្តបើវាយំសោក៏របស់វា វាត្រូវតែទាមទារយកឲ្យបានទាំងអស់ ។ លុះអាយុចំរើនដល់ ១៨ ឆ្នាំហើយ ក្មេងជំទង់នេះទម្ងន់ដល់ ៥០គ-ក ឬលើសពីនេះក៏មាន កំពស់ក៏លូតដល់ប្រហែល ១,៦០ម ។ កាមតណ្ហាក៏បានកកើត ហើយរីកចំរើនឡើងជាមួយផងដែរ ។ គំនិតបញ្ញាក៏បានលូតលាស់ពេញលេញ វាមិនគ្រាន់តែអាចអានសៀវភៅ ឬគិតគូរធ្វើលេខនព្វន្តបានប៉ុណ្ណោះទេ ថែមទាំងមានសមត្ថភាពក្នុងការគិតពិចារណារកហេតុផល ហើយអាចសន្និដ្ឋានលើបញ្ហាច្បាប់ទូទៅបាន ។ល។ ---- ខាងផ្លូវសង្គមវិញ វាត្រូវតែបានចូលជាសមាជិកណាមួយ ហើយវាអាចគិតដល់ផលប្រយោជន៍ទូទៅនៃសង្គមមុនគិតដល់ប្រយោជន៍ផ្ទាល់ខ្លួនវា ពិសេសជាងនេះទៅទៀត វាអាចហ៊ានធ្វើពលិកម្មបូជាជីវិត ដើម្បីការពារប្រយោជន៍រួម ។

ក្នុងចន្លោះវ័យទាំងពីរនេះ ក្មេងកំពុងលូតលាស់ដុះដាលទៅកាន់ដំណាក់នៃមនុស្សជំទង់ពេញលក្ខណៈ ។ ដូចនេះ ការលូតលាស់ទាំងអស់ សុទ្ធសឹងជាការរីកចំរើនបន្ទាប់បន្តគ្នានៃបុគ្គលិកលក្ខណៈទាំងបីផ្នែក

គោលគឺការប្រែប្រួលម្យ៉ាងដែលពុំអាចសន្មតឲ្យទៀងទាត់ ថាជាភាពណាមួយជាក់លាក់បានឡើយ ។ កិច្ចសំខាន់បំផុត គឺត្រូវធ្វើយ៉ាងណាឲ្យដំណើរនៃការរីកចំរើនលូតលាស់នេះ អាចប្រព្រឹត្តទៅបានតាមគន្លងត្រឹមត្រូវ និងឲ្យមានរបៀបរៀបរយល្អ ។ គឺពិតជាការលូតលាស់ខាងបុគ្គលិកលក្ខណៈនេះហើយដែលបណ្ដាលឲ្យមនុស្សម្នាក់ៗ រស់នៅបានដោយសុខុមាលភាពពេញលេញខាងរូបកាយ ខាងចំណេះបញ្ញា និងខាងសង្គម ។ ប្រសិនជាដំណើរលូតលាស់ពុំបានរៀបរយ ក្នុងដំណាក់នៃបន្ទោះវ័យនោះទេ ពិតជាដំណើរជីវិតទៅនឹងត្រូវរង្គោះរង្គើមិនខានៗ

នេះជាឧទាហរណ៍មួយដើម្បីបញ្ជាក់ជូនទៅ :

ក្នុងរយៈវ័យដែលឆ្អឹងកំពុងលូតលាស់ ក្មេងម្នាក់ៗ ពុំអាចបរិភោគអាហារដែលមានជាតិកំបោរគ្រប់គ្រាន់ ហើយពុំបានប្រយ័ត្នប្រយែងថែទាំទំរង់ឆ្អឹងឲ្យដុះដាលបានត្រឹមត្រូវផង លុះបន្តិចទៅឆ្អឹងខ្នងក៏ត្រូវវៀច ។ ទុព្វលភាពនេះ នាំរាំគ្រាំគ្រាចិត្តអស់មួយជីវិត ហើយបុព្វហេតុដែលបណ្ដាលឲ្យអាប់ឱនបញ្ញា ហើយឱនថយខាងផ្លូវសង្គមថែមទៀតផង ។

គោលដៅធំបំផុត នៃអនាម័យសិក្សា គឺការថែរក្សាការរីកចំរើននៃបុគ្គលិកលក្ខណៈ ក្មេងទាំងអស់ឲ្យបានពេញលេញត្រឹមត្រូវ ។ ចុះ

ហេតុអ្វីបានជាត្រូវអញ្ជើញអស់លោកជាគ្រូបង្រៀនទាំងឡាយ ឲ្យចូលរួមមេត្រីជួយទំនុកបំរុងកម្មវិធីនេះផងដែរ ។

ព្រោះថា ដំណើរលូតលាស់ពីកុមារភាព ទៅទល់យុវភាព ហើយដែលនឹងត្រូវឆ្ពោះទៅកាន់មជ្ឈិមវ័យនោះ ស្ថិតនៅក្រោមកិច្ចដឹកនាំរបស់គ្រូបង្រៀនស្ទើរតែទាំងស្រុង ។ គ្រូអាចស្គាល់សភាពចិត្តគំនិតសិស្សបានអាចជាសំភៀនប្រដៅប្រដៅ ជួយណែនាំទំនុកបំរុងឬលើកទឹកចិត្តវាពេលតើធ្វើយ៉ាងណាឲ្យបុគ្គលិកលក្ខណៈ ទាំងមូលរបស់វាបានរីកចំរើនសមស្របតាមគន្លងបង្អាក់រៀបរយ ។

ប្រសិនជាការលូតលាស់នេះមានការខកខាន ឬ អាក់អួលនោះ គ្រូអាចយល់បានហើយអាចជួយសង្គ្រោះវាទាន់ពេលវេលា នឹងអាចជួយទំនុកបំរុងថែទាំរហូតដល់វាបានសម្រេចនូវបុគ្គលិកលក្ខណៈ ជាកំពូលរបស់វា ។

តាមធម្មតា មាតាបិតាទាំងឡាយច្រើនតែពុំបានយកចិត្តទុកដាក់ ឬពុំបេះពិនិត្យការចំរើនលូតលាស់នេះទេ ឬ ប្រសិនជាបានពិនិត្យឃើញហើយ ក៏ពុំបានយល់នូវអត្ថប្រយោជន៍យ៉ាងណាៗនោះដែរ ។ ឯគ្រូវិញអាចដឹងហើយយល់ច្បាស់ថា : ហេតុដែលបណ្ដាលឲ្យអាក់អួលកង្វះការលូតលាស់នេះ ដូចជាការឲ្យអាហារបរិភោគពុំបានគ្រប់គ្រាន់

ឬការធ្វេសប្រហែសក្នុងកិច្ចថែទាំជាដើម អាចបណ្ដាលឲ្យមានឥទ្ធិពលអាក្រក់ដល់អនាគតក្មេងយ៉ាងណាខ្លះ ។

គេបានសង្កេតឃើញជាញឹកញាប់មកហើយថា មាតាបិតាច្រើនធ្វេសប្រហែសក្នុងការថែទាំបុគ្គលិកលក្ខណៈបុត្រធីតា ឯការចំរើនលូតលាស់ក៏មានចំណើតទន់ខ្សោយខ្ជីខ្ជាទៅតាមនោះដែរ ។

អាស្រ័យហេតុហ្នឹងហើយ ទើបប្រជាពលរដ្ឋភាគច្រើនបានរស់នៅក្នុងទុនភាពខាងរូបកាយ ខាងបញ្ញា និងខាងសង្គម ។




# វិជ្ជាអប់រំកាយ

## ផ្នែកដើរ

ដោយ ទីចាត់ការអប់រំកាយនិងកីឡានិស្សិត

១ – ការហាត់មានលក្ខណៈជាការអប់រំកាយ

ក – ដើរជារង្វង់មូល សំរាប់ក្មេងតូចៗ ដើរលោត ។

ខ – ដើរទៅមុខធម្មតា តាមចង្វាក់ប្លែកៗគ្នា ។

គ – ដើរទៅមុខញាប់ បោះជំហានខ្លីៗ ។

ឃ – ដើរទៅមុខលើកជង្គង់ខ្ពស់ៗ បង់បោយដៃៗ ។

ង – ដើរទៅមុខបោះជំហានឲ្យវែង ជង្គង់ខ្ទុនទៅមុខ ។

« មើលរូបភាពទី ១ » ។

ច – ដើរទៅមុខទម្លាក់ជើងស្រាលៗ ដើរនឹងចុងជើង ដៃតាមធម្មតា ។

ឆ – ដើរទៅមុខបោះជំហានឲ្យវែងៗ បង់ហោយទៅមុខទៅក្រោយ ដៃផ្ទុយនឹងជើង ។

ជ – ដើរទៅមុខជង្គង់ត្រង់ ពើងដើមទ្រូង ជើងត្រង់ ដៃបង់ហោយតិចៗ « រូបភាពទី ២ » ។

ឈ – ដើរចុនជង្គង់ទៅមុខ ចុងដៃឆ្វេងប៉ះដីទៅមុខចុងជើងស្ដាំ ចុងដៃស្ដាំប៉ះដីទៅមុខចុងជើងឆ្វេង « រូបភាពទី ៣ » ។

ញ – ដើរទា ដៃច្រត់ចង្កេះ ជើងចំអើត អង្គុយចុះ ជង្គង់កន្ទួត ដើរទៅមុខ « រូបភាពទី ៤ » ។



ទី ១ ទី ២ ទី ៣ ទី ៤

២ – ការហាត់អនុវត្តន៍នៅក្រៅថ្នាសាលា :

សូមមើលកម្មវិធីនៃមេរៀនខាងការអប់រំកាយ នៅសាលាបឋមសិក្សា

« ទស្សនាវដ្ដី ខែ មករា ១៩៦៣ ឆ្នាំទី ១៦ លេខ ៧ គ្រង់ទំព័រ ១៣៧ » ។

## ផ្នែក : តុល្យភាព

តុល្យភាព គឺជាការហាត់មួយផ្នែកដ៏សំខាន់ណាស់ អាចធ្វើឲ្យរាងកាយយើងទន់ភ្លន់ ហើយប្រព្រឹត្តទៅស្របគ្នា ។

ក – ឈរត្រង់ខ្លួន : ប្រុង ដោយធ្វើបលនាដៃ ឬនៅស្មៀម ។
ឈរជើងម្ខាងត្រង់ខ្លួន: លើកជង្គង់ម្ខាងឡើង ដៃនៅស្មៀម ។
ឈរជើងម្ខាងត្រង់ខ្លួន : ដៃតាំងពីរលើកជង្គង់ឡើង « រូបភាពទី ១ » ។

ខ – ឈរជើងម្ខាងត្រង់ខ្លួន : ដៃប្រត់បង្កើះលើកំណល់ដែលមានកំពស់ទាប ដូចដុំឈើ សសរមួយកំណាត់តូច ។ ល ។ « រូបភាពទី ២ » ។

គ – ឈរជើងម្ខាងលើកំណល់ លើកជើងម្ខាង ហើយបំអើតជើង « រូបភាពទី ៣ » ។

ឃ– ឈរជើងម្ខាងលើផ្តុកប ទុនជង់ខ្លួនទៅមុខ លើកជង្គង់ម្ខាងឡើងឲ្យដល់ថ្ងាស ។

ង – ឈរជើងម្ខាងលើ ផ្ដៃកប ដៃច្រត់ចង្កេះ បន្ទន់ជង្គង់ទៅមុខ ជើងម្ខាងសណ្ដូកត្រង់តាមជង្គង់ « រូបភាពទី ៤ » ។

ច – ឈរជើងម្ខាងត្រង់ លើផ្ដៃកប ពត់ជង្គង់ទៅមុខ ជើងម្ខាងសណ្ដូកត្រង់តាមជង្គង់ ដៃទាំងពីរដាក់លើកញ្ចឹងក ដាក់លើស្មា ដៃសន្ធឹងទៅក្រោយ « រូបភាពទី ៥ » ។

ការហាត់តាមឲ្យលោតទៅមុខ ៤ ជំហាន ថយក្រោយ ៤ ជំហាន រួចប្ដូរជើងម្ដង ។

សម្ភារៈ:



កំពស់: ៧០ស.ម. ៩០ស.ម. ១០៥ស.ម.

ឆ – ដើរទៅមុខ ថយក្រោយ ចំហៀង លើសសរផ្ដេក ។

ជ – ដើរលើកជង្គង់ខ្ពស់ លើសសរផ្ដេក ។

ឈ ដើរលើសសរដោយឡើបលនាដៃ ដៃសន្ធឹងរវៃជារង្វង់មូល « រូបភាពទី ៦ » ។

ញ – ដើរចំហៀងលើសសរ ។

ជ – ដើរចំហៀងលើសសរ ដោយគ្រវីដៃខ្វែងគ្នាពីមុខ ។ (រូបភាពទី ៧) ។



# ទាវរកអ្វី ?




* ការឈ្ងោកក្រោមគ្រែគេដេកនោះ ធ្វើឲ្យឪពុកទាវឆ្ងល់យ៉ាងខ្លាំង: "ទាវរកអ្វី ?"

– ដើម្បីបំបាត់ការឆ្ងល់នោះ សូមយកខ្មៅដៃគូសឲ្យខ្មៅពេញផ្ទៃទាំងឡាយណា ដែលមានចំនួនចែកនឹង ៣ ដាច់ ហើយលោករកចម្លើយឃើញ ។




## អភិលាភ និងប្រាក់បំណេញ (Plus value et Profit)

ដើម្បីងាយយល់តទៅទៀត ខ្ញុំសូមលើកយកសញ្ញាណពីរមកវែកញែកបញ្ជាក់ន័យថែមទៀត ដើម្បីចៀសវាងនូវការភាន់ច្រឡំទាំងឡាយដែលអាចនឹងមានកើតឡើង ។

សញ្ញាណទាំងពីរនោះ គឺអភិលាភមួយ (Plus-value) និងប្រាក់បំណេញមួយ (Profit) ។

អ្នកណាជាអ្នកបង្កើតអភិលាភ សូមយកឧទាហរណ៍មួយមកបង្ហាញ ។ ថៅកែម្នាក់បានចេញប្រាក់ឈ្នួល ឲ្យកម្មករម្នាក់ថ្ងៃ ១០០៛ ក្នុងមួយថ្ងៃ ដើម្បីជួលឲ្យធ្វើស្បែកជើង ។ ថៅកែបានទិញគ្រប់គ្រឿងវត្ថុធាតុដើម មានស្បែក-កៅស៊ូ-ដែកគោល ។ល។ ដែលមានតម្លៃទាំងអស់ ២០០៛ ។ តែក្នុង ៤ ម៉ោង កម្មករធ្វើហើយជាស្រេចបានស្បែកជើងមួយគូ ។ យើងយល់ហើយថា ការងាររបស់កម្មករបានបង្កើតនូវតម្លៃមួយ ដែលគេបញ្ចូលទៅក្នុងតម្លៃស្បែក-

ជើងមួយគូ ។ ដូច្នេះស្បែកជើងមួយសម្រាប់ខាងលើមានតម្លៃ ៥០០៛ ។ បើថៅកែលក់ស្បែកជើងនេះ តែថ្លៃ ៥០០៛ គាត់គ្មានខាត ឬក៏គ្មានបំណេញដែរ ។

តាមធម្មតា ថៅកែមិនមែនឲ្យកម្មករធ្វើការតែ ៤ ម៉ោងក្នុងមួយថ្ងៃប៉ុណ្ណោះទេ ។ ឧបមាថា គាត់ប្រើឲ្យកម្មករធ្វើការដល់ទៅ ៨ ម៉ោង ។ ក្នុងករណីនេះ កម្មករបានបង្កើតបានស្បែកជើងមួយសម្រាប់ទៀត ។ តែសូមជ្រាបថា ថៅកែចាយអស់តែ ៤០០៛ ទេ ក្នុងធ្វើស្បែកជើងមួយគូលើកក្រោយនេះ ព្រោះកម្មករទទួលបៀវត្សរបស់ខ្លួនក្នុងមួយថ្ងៃ ។ ដើម្បីកុំឲ្យភាន់ច្រឡំ យើងសូមបញ្ជាក់ថា កម្មករបានចំណាយកម្លាំងកាយ កម្លាំងបញ្ញា ការប៉ិនប្រសប់ និងថាមពលរបស់ខ្លួន តែក្នុង ៤ ម៉ោង ស្មើនឹងប្រាក់ ១០០៛ ពោលគឺបើគេយកប្រាក់ខាងលើនេះទៅចាយវិញ គឺបានគ្រាន់តែថែរក្សាកម្លាំងកាយ - កម្លាំងបញ្ញា - ថាមពលរបស់ខ្លួនឲ្យនៅដដែលប៉ុណ្ណោះ ព្រមទាំងជួយផ្គត់ផ្គង់ដល់គ្រួសាររបស់គេ ។

ស្បែកជើងមួយសម្រាប់លើកក្រោយ គេត្រូវលក់ ៥០០៛ ដែរ ។ តែក្នុង ៥០០៛ ក្រោយ ថៅកែបានបំណេញ ១០០៛ ដែលកម្មករបានបង្កើត ឯតម្លៃ ១០០៛ នេះ យើងឲ្យឈ្មោះហៅថា អតិលាភ (Plus-value)

គឺលាភបានមកដោយសារការងាររបស់កម្មករ (សូមអានទស្សនាវដ្ដីលេខ ១ កក្កដា ១៩៦២)

សមភាគរវាងពេលការងារបន្ថែមនិងការងារជាចាំបាច់ ធ្វើឲ្យយើងដឹងនូវអត្រានៃអតិលាភ ។ ក្នុងឧទាហរណ៍ខាងលើសមភាគនោះគឺ ៤/៤ ពោលគឺ ១០០ % ។ ប្រសិនជាមួយថ្ងៃ កម្មករធ្វើការ ១០ ម៉ោង អត្រានៃអតិលាភមាន ៦/៤ គឺ ១៥៦ % ។ ផ្ទុយទៅវិញ ប្រសិនជាក្នុងមួយថ្ងៃ ពេលការងារជាចាំបាច់មានតែ ៣ ម៉ោង អត្រានៃអតិលាភមាន ៥/៣ គឺ ១៦៦ % ។

សូមជ្រាបថា មូលធនិកមិនគិតដូចយើងវែកញែកខាងលើនេះឡើយ ។ គេគិតថាអាត្មាអញចេញប្រាក់ ៨០០៛ សម្រាប់ទិញសម្ភារៈផ្សេង ៗ និង ១០០៛ សម្រាប់ឈ្នួលកម្មករ ។ អាត្មាអញបានទទួលមកវិញនូវទំនិញមួយមានតម្លៃ ១ ០០០៛ ។ ដូច្នេះ អញត្រូវចំណេញបាន ១០០៛ ។

គប្បីយល់ថា ការគិតដូច្នេះមិនអាចឲ្យយើងមើលឃើញយ៉ាងច្បាស់អំពីបញ្ហាបង្កើតតម្លៃទេ ។ គេអាចនឹងច្រឡំបាននូវបញ្ហាពីរខុសគ្នា គឺការបញ្ចូលតម្លៃ ទៅក្នុងវត្ថុដែលគេបង្កើត (តម្លៃនៃមធ្យោបាយសម្រាប់បង្កើតផល ដែលត្រូវបានស្រូបចូលទៅក្នុងទំនិញតាមរយៈការបង្កើតផល) និងការបង្កើតតម្លៃ ដោយការចំណាយថាមពលរបស់កម្មករ ។

# អំពីប្រាក់បំណោញ

## ក – ថ្លៃដើមនិងថ្លៃបង្កើតផល :

យើងបានដឹងហើយថា មូលធនិកដែលមានគ្រប់វត្ថុធាតុ ដើម្បីស្គាល់ទីងដើម្បីដឹងយ៉ាងច្បាស់លាស់ នូវចលនាវិលចុះឡើងនៃផ្នែកផ្សេង ៗ នៃប្រាក់ទុនរបស់ខ្លួន អាចដឹងហើយគិតប៉ាន់ឃើញយ៉ាងងាយនូវថ្លៃដើមរបស់ខ្លួន ។ យើងឧបមាថា នាយទុនម្នាក់បានដំឡើងរោងចក្រធ្វើស្បែកជើងមួយ ។ គាត់ត្រូវចំណាយផ្សេង ៗ ដូចតទៅ :—

( សូមអានទស្សនាវដ្ដី លេខ ១ ខែ កញ្ញា ១៩៦៣ )

| មូលធនដើម | រយៈពេលនៃចលនា |
|---|---|
| ១០០ ០០០៛ សម្រាប់សង់អគារ | ២០ ឆ្នាំ |
| ២៥០ ០០០៛ សម្រាប់ទិញម៉ាស៊ីន | ១០ ឆ្នាំ |
| ១៤០ ០០០៛ សម្រាប់ទិញគ្រឿងប្រដាប់ផ្សេង ៗ | ២ ឆ្នាំ |
| ១០០ ០០០៛ សំរាប់ទិញវត្ថុធាតុដើមផ្សេង ៗ | ៦ ខែ |
| ៥០ ០០០៛ សម្រាប់ឈ្នួលកម្មករ | ៣ ខែ |

ករួម ៦៤០ ០០០៛

តម្លៃស្បែកជើងទាំងអស់ ដែលត្រូវទាញយកមកវិញក្នុង ១ ឆ្នាំ

| | | | |
|---|---|---|---|
| ១/២០ | នៃ ១០០ ០០០៛ | គឺ | ៥ ០០០៛ |
| ១/១០ | នៃ ២៥០ ០០០៛ | គឺ | ២៥ ០០០៛ |
| ១/២ | នៃ ២៤០ ០០០៛ | គឺ | ៧០ ០០០៛ |
| ២ជង | ១០០ ០០០៛ | គឺ | ២០០ ០០០៛ |
| ៤ជង | ៥០ ០០០៛ | គឺ | ២០០ ០០០៛ |
| | អតិលាភ . . . . | | ២០០ ០០០៛ |
| | បូករួម | | ៧០០ ០០០៛ |

ក្នុងឧទាហរណ៍ខាងលើនេះ ប្រាក់ដើមនៃមូលធនមានចំនួន : ៧០០ ០០០៛-២០០ ០០០៛ ៥០០ ០០០៛ ។ ក្នុងករណីនេះ គេមិនស្គាល់ ឬដឹងនូវតម្លៃបន្ថែម ដែលកម្មករបានបង្កើតឡើយ ។ គេគិតតែចំណែកមូលធន ដែលស្រូបចូលទៅក្នុងទំនិញដែលគេត្រូវបង្កើត ។ យើងឧបមាទៀតថាក្នុងឧទាហរណ៍ខាងលើ សហគ្រាសបង្កើតបានស្បែកជើង ១០ ០០០ សម្រាប់ជួបៗគ្នា ។ នាយទុនមិនមែនធ្វើការដើម្បីលក់ស្បែកជើងនេះតាមថ្លៃដើមឡើយ $\left(\frac{៥០០\ ០០០}{១០\ ០០០}\right) = ៥០៛$ : គាត់ចង់លក់ឲ្យបានចំណេញខ្លះ ។ ពេលគឺគាត់លក់បាន ៧០៛ ក្នុងមួយសម្រាប់ ។ គាត់ត្រូវចំណេញបាន ២០៛×១០០០០=

២០០ ០០០៛ គឺប្រាក់ចំណេញ ។ តើគេគិតអត្រានៃប្រាក់ចំណេញនេះដូចម្តេច ?

គាត់បានចេញប្រាក់ទុនអស់ ៦៤០ ០០០៛ ។ គាត់បានប្រមូលមកវិញនូវប្រាក់ចំណេញ ២០០ ០០០៛ សមភាគរវាងប្រាក់ចំណេញទាំងអស់នឹងប្រាក់ដើម $\frac{200\ 000}{640\ 000}$ បានឲ្យយើងដឹងនូវអត្រានៃប្រាក់ចំណេញ ។ ក្នុងករណីខាងលើអត្រានៃប្រាក់ចំណេញមានប្រហែលជា ៣១% ។ យើងអាចកត់សំគាល់ថា ក្នុងឧទាហរណ៍នេះ មូលធនិកបានប្រមូលយកទាំងអស់នូវអតិលាភ ដែលកម្មករជាអ្នកបង្កើត ។

ចំពោះមូលធនិក ប្រាក់ចំណេញគឺបានមកអំពីប្រាក់របស់ខ្លួនទាំងអស់ ទាំងមធ្យោបាយសម្រាប់បង្កើតផល ទាំងកម្មករ ពោលគឺប្រាក់ទុនទាំងមូលនេះហើយ ដែលជាអ្នកបង្កើតនូវលទ្ធផលដ៏អស្ចារ្យនេះ គឺប្រាក់ចំណេញ ។

តែតាមការវិភាគរបស់យើង ដែលបានឆ្លើរួចមកហើយ យើងបានឃើញយ៉ាងច្បាស់ថាប្រាក់ចំណេញទាំងនេះ គ្មានអ្វីក្រៅពីអតិលាភដែលមូលធនមិនស្ថិតស្ថេរ( capital variable ) តែមួយភាគប៉ុណ្ណោះជាអ្នកបង្កើត ពោលគឺផ្នែកមូលធនដែលគេប្រើប្រាស់ សម្រាប់ចេញឈ្នួលកម្មករនេះឯង ។

យើងអាចធ្វើការសំគាល់បានថា អត្រានៃអតិលាភតែងតែមានសម្មាមាត្រធំជាងអត្រានៃប្រាក់ចំណេញ ដោយអត្រានៃអតិលាភ គឺបានមកដោយធ្វើសមភាគរវាងអតិលាភនិងមូលធនមិនស្ថិតស្ថេរ ។ តែអត្រានៃប្រាក់ចំណេញវិញ គឺបានមកដោយសមភាគរវាងប្រាក់ចំណេញទាំងអស់និងប្រាក់ដើមទាំងអស់ ( Taux de la plus-value : $\frac{\text{plus-value}}{\text{Capitalvariété}}$ taux de profit = $\frac{\text{Profit total}}{\text{Capital total}}$ )

ដូចបានរៀបរាប់ខាងលើនេះ អត្រានៃប្រាក់ចំណេញតែងតែផ្លាស់ប្តូរប្រែប្រួលទៅតាមការបែងភាគនៃមូលធន ។ ដើម្បីងាយយល់នូវបញ្ហានេះ សូមលើកឧទាហរណ៍មកបង្ហាញជូនឧទាហរណ៍ដែលមានសមាសភាគ ( Composition organiqne ) ខុសៗគ្នា ។ ដើម្បីឲ្យងាយថែមទៀត យើងឧបមាថា តម្លៃនៃនិយតមូលធនបានស្របចូលទៅក្នុងទំនិញអស់ក្នុងរយៈមួយឆ្នាំហើយ អនិយតមូលធន មានចលនាតែមួយឆ្នាំដែរ ។ បានន័យថា ក្នុងមួយឆ្នាំថ្លៃដើមនៃទំនិញដែលគេបានបង្កើត ស្មើនឹងនិយតមូលធនបញ្ចូលគ្នា ។ គេចែកប្រាក់ដើមទាំងពីរនោះដូចតទៅនេះ

ក្នុងទី ១ : និយតមូលធនមាន ៩ ០០០៛

អនិយតមូលធនមាន ១ ០០០៛

អត្រានៃអតិលាភមាន ១០០ %

ការចាយរាយអនិយតមូលធន ១ ០០០៛ បានបង្កើតនូវអតិលាភ ១ ០០០៛ ប្រសិនបើគេលក់ទំនិញតាមតម្លៃរបស់វា គេគាប់បានអត្រានៃប្រាក់ចំណេញ : $\frac{\text{១ ០០០}}{\text{៩ ០០០+១០០០}}$ ១០ %

ក្នុងទី ២: និយតមូលធន ៤ ០០០៛

អនិយតមូលធន ១ ០០០៛

អត្រានៃអតិលាភ ១០០ %

ការលក់ទំនិញតាមថ្លៃរបស់វា បានផ្ដល់មកវិញនូវអត្រានៃប្រាក់ចំណេញ $\frac{\text{១ ០០០}}{\text{៤ ០០០+១០០០}}$ = ២០ % យើងបានដឹងរួចមកហើយថា សមភាគរវាងនិយត: នឹងអនិយតមូលធនហៅថា សមភាគនៃមូលធន ( Composition organique du capital ) ក្នុងឧទាហរណ៍ទាំងពីរខាងលើ មូលធនទី ១ មានសមាសភាគ $\frac{\text{៩០០០}}{\text{១០០០}}$ = ពោលគឺ ៩ ៗ ក្នុងឧទាហរណ៍ទី ២ មានសមាសភាគ $\frac{\text{៤០០០}}{\text{១០០០}}$ = ពោលគឺ ៤ ៗ ដូច្នេះ មូលធនទី ១ មានសមាសភាគធំជាងមូលធនទី ២ ៗ ដូច្នេះ យើងអាចសន្និដ្ឋានបានថា មូលធនណាមានសមាសភាគធំ នោះអត្រានៃប្រាក់ចំណេញនឹងមានតិចជាងពេក ៗ ឧទាហរណ៍ដូចជា ក្នុងសហគ្រាសដែលបានបញ្ចេញប្រាក់ ដើម្បីទិញនូវគ្រឿងប្រដាប់ដ៏ថ្លៃ ៗ ជាដើម ៗ តែការពិសោធន៍ បានបង្ហាញឲ្យឃើញច្បាស់ថា ការពិតវិញគឺមិនមែនដូច្នេះឡើយ ប្រសិនបើមានការប្រណាំងប្រជែងរវាងសហគ្រាសធំ ៗ ៗ

(នៅមានត)...




## ពាក្យខ្មែរប្រែពីបរទេស

### ដោយគណៈកម្មការជាតិនៃការសិក្សា

### ផ្នែកអក្សរ « ក »

កម្ពុជសុរិយា ឆ្នាំ ទី ៣៥ លេខ ២ ខែ កុម្ភៈ គ.ស. ១៩៦៣

**—F—**

**56 – Formule de promulgation** *រូបមន្តនៃការប្រកាសឲ្យប្រើច្បាប់ ។*

**des lois**

57 — **Frères et sœurs germins** បងប្អូនប្រុសស្រីសហមាតាបិតា: បងប្អូនប្រុសស្រី ដែលកើតពីឪពុកមួយម្ដាយមួយរួមគ្នា ។

58 — **Frères et sœurs consanguins** បងប្អូនប្រុសស្រីសហមាតា: បងប្អូនប្រុសស្រីដែលកើតពីឪពុកមួយម្ដាយទីទៃ ។

59 — **Frères et sœurs utérins** បងប្អូន បុសស្រីសហមាតា: បងប្អូនប្រុសស្រី ដែលកើតពីម្ដាយជាមួយឪពុកទីទៃ ។

— I —

60 — **Immeubles par destination** អសង្ហារិមដោយ១ទ្ទេស: សង្ហារិមដែលសន្មត ជាសង្ហារិមព្រោះជាប់នឹងអសង្ហារិមនេះ ។ ១. ផលដំណាំគ្រប់យ៉ាង ដែលមិនទាន់ប្រមូលកាត់ បេះ ដកគាស់ឬដើមឈើដែលដុះ លើអសង្ហារិម ។

61 — **Immeubles par détermi-** អសង្ហារិមដោយកំណត់ច្បាប់ ឬ

| | |
|---|---|
| nation de la loi | សង្ហារិមដែលច្បាប់ចារឹកថា ត្រូវទុកជា អសង្ហារិម ១ – នាវដែលមាន ចំណុះ ស្មើនឹង ៨០០ហាប ឬលើស ៗ ២ – ផ្ទះទឹកចំណុះដូចខាងលើ ៗ ៣ – សិទ្ធិលើវត្ថុជាអចលនៈ ៗ |
| 62 — Immeubles par nature | អសង្ហារិមដោយធម្មជាតិ ៗ ១ – ដី អគារដែលសង់លើគ្រឹះ ឬអគារដែល សង់ពីឥដ្ឋ ៗ ល ៗ |
| 63 — Influence des condamnations pénales sur la capacité des personnes | ឥទ្ធិពលនៃទណ្ឌកម្ម ខាងព្រហ្មទណ្ឌ លើសមត្ថភាពនៃបុគ្គល ៗ |
| 64 — Influencer ( v. int. ) | មានឥទ្ធិពលលើ ៗ |
| 65 — Inhumer un cadavre | បញ្ចុះសាកសព ៗ |
| 66 — Incinérer un cadavre | រំលាយសាកសព ៗ |
| 67 — Intermède (n.m.) | ឆាកលំហែ ព. សិល្បៈ |

— J —

68 — Jugement déclaratif d'absence — សាលក្រមប្រកាសអំពីអវត្តមាន ។

69 — Jouissance d'un droit — ការអាស្រ័យសិទ្ធិ ។

70 — Jouir d'un droit — អាស្រ័យសិទ្ធិ ។

71 — Juriste (n.m.) — នីតិវិទូ : អ្នកចេះនីតិសាស្ត្រ ។

72 — Jurisconsulte (n.m.) — អ្នកនីតិប្រឹក្សា : អ្នកជំនាញខាងច្បាប់ដែលមានការៈ ជូនយោបល់បំភ្លឺបញ្ហានីតិសាស្ត្រ ។

— M —

73 — Métier (nm.) — អម្រស់របរ : ការចិញ្ចឹមជីវិតដោយកម្លាំង ។ ឧ. របរកសិករ របរជាងកាត់សក់ របរជាងកាត់ដេរ ។

74 — Modalité (les) de la confection des lois — របៀបនៃការតែងច្បាប់ ។

— N —

75 — Nom de famille d'une — គោត្តនាមនៃបុគ្គលម្នាក់ នាមសំកប់

personne — ប្រើរួមគ្នាចំពោះសមាជិកទាំងអស់នៃគ្រួសារ ដែលជាដំណនៃជាតិកំណើត ពីបុរសទាំងឡាយ ដែលកើតពីជនករួមម្នាក់ ។

76 — Notifier les actes juridiques — វិញ្ញត្តិលិខិតតុលាការប្រាប់ឲ្យដឹងពីលិខិតតុលាការតាមផ្លូវច្បាប់ ។

77 — Notification des actes juridiques — វិញ្ញត្តិលិខិតនៃតុលាការ ។

78 — Notions sommaires sur les prévues — សញ្ញាសង្ខេបចំពោះភស្តុតាង ។

— o —

79 — Offcier de police judiciaire — មន្ត្រីក្រុមនគរបាលយុត្តិធម៌ ។

80 — Officier de l'état civil — មន្ត្រីអត្រានុកូលដ្ឋាន ។

81 — Origine des êtres humains — ដើមកំណើតនៃមនុស្សលោក ។

## — P —

82 — Palais de justice — សាលាយុត្តិធម៌ ។

83 — Parties — ភាគី ។

84 — Plaignant — អ្នកប្ដឹង ។

85 — Permis d'incinération d'un cadavre — លិខិតអនុញ្ញាតរំលាយសាកសព ។

86 — Permis d'inhumation d'un cadavre — លិខិតអនុញ្ញាតបញ្ចុះសាកសព ។

87 — Période de présomption d'absence d'une personne — សម័យនៃសន្មតការណ៍ចំពោះ អវត្តមាននៃបុគ្គលម្នាក់ ។

88 — Publier les lois — ផ្សាយច្បាប់ ។

89 — Publication des lois — ការផ្សាយច្បាប់ ។

90 — Publication d'un mariage — ការផ្សាយអាពាហ៍ពិពាហ៍ ។

91 — Publier un mariage — ផ្សាយអាពាហ៍ពិពាហ៍ ។

92 — Pupille (n.m.) — បាលិកៈ អនីតិជនកំព្រា នៅក្នុងការក្សានៃអ្នកព្យាបាល ។

93 — Perquisition domiciliaire ការឆែកឆេរលំនៅ ។

94 — Professionnellement (adv.) ដោយវិជ្ជាជីវៈ ។

95 — Prénom ou nom particulier បឋមនាម ឬនាមខ្លួន តាមច្បាប់ខ្មែរ គឺជាពាក្យមួយម៉ាត់ ដែលត្រូវដាក់បន្ទាប់ពីនាម ឬគោត្តនាម ដើម្បីសំគាល់ឈ្មោះផ្ទាល់ខ្លួន របស់សមាជិកនីមួយៗនៃគ្រួសារ ។

96 — Profession (n.f.) វិជ្ជាជីវៈ ការចិញ្ចឹមជីវិតដោយវិជ្ជា ។

ឧ – វិជ្ជាជីវៈពេទ្យ, វិជ្ជាជីវៈស្មាក្ដី ។

— Q —

97 — Qualité de citoyen ឋានៈជាពលរដ្ឋ ។

— R —

98 — Rang de femme mariée ទីនៃភរិយា ។

99 — Réapparaître ត្រឡប់វិញ ។

100 — Réapparition de l'absent ការត្រឡប់វិញនៃអវត្តមានបុគ្គល ។

101 – Régistre des publications de mariage — បញ្ជីនៃការផ្សាយការពារហ៍ពិពាហ៍ ។

102 – Résidence (n.f.) — និវាសនដ្ឋាន - ទីឋានដែលបុគ្គលម្នាក់ធ្លាប់អាស្រ័យនៅ ឬអាស្រ័យនៅមួយកាល ។ ១ – អ្នកកជការម្នាក់មានលំនៅនិត្យានុកូលនៅភ្នំពេញ ហើយមាននិវាសនដ្ឋាននៃផ្សារព្រែកលៅ នឹងក្រុងកែប ។

— S —

103 – Saynète (n.f.) — ឆាកកំប្លែង សិល្ប:

104 – Scène (n.f.) — ឆាកសិល្ប: ពនដែលលោនសំដែងរឿងភាគនៃឈុត ។

105 – Signification d'un jugement — ការប្រវេទនៃសាលក្រមមួយ ។

106 – Signifier un jugement — ប្រវេទសាលក្រមមួយ: ប្រាប់ឲ្យដឹងពីសាលក្រមតាមផ្លូវតុលាការ ។

107 – Sommiers judiciaires — ក្រាំងថ្កោលទោស ។

108 — Sujet d'examen ou de concours — ប្រធានវិញ្ញាសានៃការប្រឡង ឬការប្រឡងប្រជែង ។

109 — Sources du droit cambodgien — ប្រភពនៃនីតិសាស្ត្រខ្មែរ ។

110 — Sous - acquéreur — អ្នកជាវត អ្នកទិញត ។ អ្នកជាវតព្រះពុទ្ធរូប អ្នកទិញតបលនវត្ថុ ។

111 — Syndicat professionnel — សហជីពនៃវិជ្ជាជីវៈ ក្រុមជនដែលមានគោលបំណងតែម្យ៉ាង ក្នុងរឿងការពារប្រយោជន៍រួមនៃវិជ្ជាជីវៈ ។
១. សហជីពនៃវេជ្ជបណ្ឌិត សហជីពនៃស្មាក្ដី ។

112 — Système de publication des lois — បែបបទនៃការផ្សាយច្បាប់ ។

113 — Témoins — សាក្សី កសិណ ។

114 — Traité du droit civil — អភិប្រាយនៃនីតិសាស្ត្របវេណី ។

115 — Visite domiciliaire — ការពិនិត្យដល់លំនៅ ។

( នៅមានត )

# រុក្ខជាតិប្លែក

ដោយ ដួង-សៀង-ហៃ (សាលាខេត្តស្ទឹងត្រែង)

បង្ហើបចេញពីកម្ពុជសុរិយាដោយ ឈួង-យ៉ុម (ទីចាត់ការគរុកោសល្យ)

១– ដើមជ័រធ្នាក់: ដើមមូលរាងដើមចំប៉ាខ្ពស់ ៤ ឬ ៥ ម. ។ សំបកមានសម្បុរដូចសំបកដើមចំប៉ាដែរ ។ ឫសវាមានបីយ៉ាងគឺ ឫសរយោង ឫសចិញ្ចឹមជាត់ និងឫសតោង ។ ឫសតោងវែងជាងគេ វាដុះចាក់ត្រង់ជ្រៅទៅក្រោម ។ សំបកឫសមានសម្បុរដូចសំបកដើមត្របែក ។ ស្លឹកវាល្អិតៗដូចជាផ្កាចំប៉ា តែរាងមូលខ្លី ។ ផ្កាវាស្រដៀងនឹងផ្កាកុលាប ។ ផ្លែវាមូលដូចជាផ្លែត្របែក ដែលតូចៗ ហើយល្អិតផងនោះ ។ គ្រាប់ផ្លែវាខ្មៅរលោងដូចគ្រាប់សណ្ដែកបាយ ។

២– ដើមជ័រធ្នាក់ម្យ៉ាងទៀត: គឺជាវល្លិ មូលតូចវែងមានកំពស់ប្រវែងពី ១០ម ឡើងទៅលើស្លឹកវាវែងៗដូចស្លឹកចំប៉ី ដូចផ្កាទឹកដោះខ្លា ដើមវាដូចគ្នានឹងដើមចំប៉ីទាំងអស់ផ្លែវាវែងដូចគ្នា គ្រាប់វាដូចគ្នានឹងគ្រាប់ផ្លែក្លោក ។ រុក្ខជាតិនេះច្រើនដុះនៅព្រៃភ្នំតាមវាលធំ ដែលពុំសូវគេចូល ។

ស្រុកដែលមានដើមជ័រងក់នោះ គឺស្រុកសៀងចាំង ចាន់ទុះ សៀមបាង ណាអុង ព្រះអន្ដាល់ កោះកី ឈើទាល អូរស្វាយ កោះស្រឡាយ កាំងមេមាយ សៀមបូក ស្រែក្រសាំង កាំងដេសរ ខេះ កញ្ញាញគោក កាំកុង ជន្លាបបរិកត់ កែវដារ ប៊ូយ គិរីវង្ស បាង១សួង បាង១ចាន ប្រដុង ដើងប្រធាត បទាំ ។

របៀបប្រើប្រាស់: ស្ងោះសំបកមកកាត់ជាកង់ៗឲ្យល្អិត ។ ឯល្វី គេកាត់ឲ្យទ្វីចដំឲ្យទក់ ។ យកថ្នាំងដាក់ទឹកពេញ ស្ងោរចំនួន ១ ទឹក លុះត្រាតែទឹកនោះរីងហើយបេញជ័រ ខាប់ចាក់ទឹកម្ដងទៀត ហើយគេយកក្បាលពស់វែក ក្បាលពស់ថ្លាន់ និងផ្លែឈើមកដាក់ផ្សំឲ្យតាលតែបាន ខាប់ឡើងខ្មៅ ។ យកបន្ទះឫស្សីមកចូកដាក់ទៅក្នុងបំពង់ៗ តាប់ផ្កែមួយមកបង ។ យកចុងកាំបិតបន្ទោះលាបជ័រនោះ នៅចុងកាំបិត រួចចាក់បំភ្លៅផ្កែនោះ រួចលែងវាឲ្យរត់ៗ ផ្កែនោះរត់បានចំនួន ២ម.ក៏ដួលដេកស្លាប់មួយរំពេច ។

កំណត់សំគាល់ : *អត្ថបទនេះ យើងសន្មតថា ទុកជាពតិមានវិទ្យាសាស្រ្តបម្លែកមួយទៅចុះ សុំមិត្រអ្នកអានកុំស្មានថាយើងមានបំណងចង់ឲ្យសាកល្បងមើលការអនុវត្តន៍នេះ ។ យើងធ្លាប់ឮតែឈ្មោះឮរឿងគ្រោះថ្នាក់ផ្សេងៗ នៅព្រៃដែលមានគេប្រើអាវុធជីវឆក់នេះ ។*

ទស្សនាវដ្ដីគ្រូបង្រៀន

# របៀបប្រើពាក្យ

## បុត្រវង្ស - បុត្រវង្គ

ដោយ ហួត - ស៊ុខ

ពាក្យទាំងពីរនេះ មើតាមអក្ខរវេយ្យាករណ៍ឃើញថា លោកអ្នកប្រាជ្ញបានចែងថា មានន័យនឹងការគានដោយខ្សែគតិគ្នា ៗ តាមពិតក្នុងការប្រើច្រើនតែកាន់ច្រឡំចំពោះពាក្យ « បុត្រវង្គ » គឺសំដៅយកក្រឡា ៤ ជ្រុងស្មើទៅវិញ ៗ

ហេតុនេះ ដើម្បីចៀសវាងនូវការច្រឡំគប្បីចំណាំដូចតទៅ :

ក – បុត្រវង្ស ត្រូវអានថា « បៈ តុ វ៉ុង » កាលបើជានាមបានសេចក្ដីថា : ក្រឡា ៤ ជ្រុងស្មើគ្នា កាលបើជាគុណនាមបានសេចក្ដីថាដែលមានជ្រុង ៤ ឬ ៤ ជ្រុង ៗ

ពាក្យដែលជាវេវចនៈ មានន័យនឹងសេចក្ដីអធិប្បាយ ហើយអាចផ្លាស់ប្ដូរប្រើជាមួយនឹង បុត្រវង្ស បាន គឺ: ៗ

បុត្រវង្ស អានថា « បៈ តុ វ៉ស់ »

បតង្ស អានថា « ប័ត ត័ង »

តាមពិតចំពោះពាក្យ ក្រឡា៤ជ្រុងស្មើ ឬ៤ជ្រុង បើចង់ប្រើជាក់ជាពាក្យបាលីឬ សំស្ក្រឹតនោះ គួរប្រើថា ចតុរ័ស្រ ដូច្នេះវិញទើបត្រូវ ព្រោះ ចតុរស្ស នេះមកពីសព្ទដើមថា ( ចតុ + អំសះ ) ចតុ ប្រែថា ៤, អំសៈ ប្រែថាភាគ, ចំណែក, ភាគនៃមុមឬជ្រុង ចុះ ៗ ភាគមធ្យ ផ្លាស់និគ្គហិតរបស់ អំ ធ្វើន័រួមគ្នាទៅជា ចតុរ័ស្រ បានសេចក្ដីថា ដែលមានជ្រុង៤ ឬ៤ជ្រុង ។

១ – ចតុរង្គ « ត្រូវអានថា ចៈ តុ រ៉ង » សំរាប់ប្រើជាបទគុណ គឺបានសេចក្ដីថា ដែលមានអង្គ ៤ ឧទាហរណ៍ កងទ័ពមានអង្គ ៤គឺ:

ទ័ពសេះ ១

ទ័ពដំរី ១

ទ័ពរទេះ១

ទ័ពថ្មើរជើង ១ ត្រូវជា៤ ៗ ល ៗ

បើរែកញែកទៅតាមសព្ទដើមឃើញថា ចតុរង្គ មកពី ( ចតុ + អង្គ ) ផ្សំនឹង រ អាគម ។ ចតុ ប្រែថា៤, អង្គ ប្រែថា អវយវៈ, រូប, តួរូប, កាយ, ខ្លួន, ភាគ, លក្ខណៈ, ការបែកសេចក្ដីឲ្យដឹងចំនួន,

ហេតុ . . . . . ។ ( មិនមែនប្រែថាជ្រុងឡើយ ) ។ ផ្ទុំគ្នាទៅបានជា បត្តុរង្គ បានសេចក្ដីថាមានអង្គ ៤ គឺមានន័យផ្សេងពី បត្តុរង្ស្រេឡះ ។

ចុះហេតុអ្វីក៏ ក្រឡាបត្រង្គ មានជ្រុង៤ស្មើគ្នា ម្ដេចក៏សរសេរ ងដើង គ ដែរ ? ។

មិនមែនដូច្នោះទេ ពាក្យថា ក្រឡា បានសេចក្ដីថា លានឬថានពបមានជាខណ្ឌ ៗ ។ បត្រង្គ ដែល « អានថា ប័ត គ្រង់ » នេះ គឺក្លាយមកពីពាក្យថា បត្តុរង្គ មានអង្គ ៤ នេះឯង ។ ពាក្យថា បត្រង្គ នេះ មិនមែនសំដៅទៅក្រឡា ៤ ជ្រុងស្មើនោះទេ គឺសំដៅលើអង្គ ៤ ។ ដូចជាបត្រង្គ ដែលជាឈ្មោះល្បែងមួយយ៉ាង ជាល្បែងសំពប់លេងឲ្យឈ្នះសាវែកក្នុងកលឧបាយរបស់អ្នកចំបាំងក្នុងសម័យបុរាណ ដែលមានកូន ៣២ សំពប់ដើរលើក្ដារ ៤ ជ្រុង មានក្រឡា ៦៤ ដែលគេតែងតែនិយមលេងសព្វថ្ងៃនេះ ក្នុងបណ្ដាលកូនទាំង ៣២ នោះ

- មានកូន ២ ហៅថា ខុន ទុកជាស្ដេចទ្រង់រាជ្យ
- មានកូន ២ ហៅថា នាង ទុកជាព្រះអគ្គមហេសី
- មានកូន ៤ ហៅថា គោល ទុកជាសេនាបតីឬមន្ត្រី



www.camerounlibre.fr

- មានកូន ៤ ហៅថា ស្រេះ ទុកជាទ័ពជើងគោក
- មានកូន ៤ ហៅថា ទូក ទុកជាទ័ពជើងទឹក
- មានកូន១៦ ហៅថា ត្រី ទុកជាសេនាពាហន ហៅពលថ្មើរជើង ។

គឺគេតែងតែរៀបកូនបត្រង្គ ជារបៀបសេនាកងទ័ពមានអង្គ ៤ គឺត្រូវមាន គោល, ស្រេះ, ទូក, ត្រី សមការពារ ខុន នឹង នាង ។ ហេតុដូចនេះហើយ បានជាត្រូវសរសេរ ង ជើង គ ។

កំណត់ចំណាំ :

បត្រង្ស ត្.ន. ដែលមានជ្រុង ៤, បួនជ្រុង, ក្រឡា ៤ ជ្រុងស្មើគ្នា ។

បត្រង្គ ត្. ដែលមានអង្គ ៤ ។

# សេចក្ដីស្នើ

## អំពីពាក្យ ប្រយ៉ត និង ប្រយ័ត្ន

ដោយ ហ្វួត - សុខ

ពាក្យទាំងពីរនេះ បើតាមទម្លាប់និយមឃើញថា និយមប្រើ « ប្រយ័ត្ន » នេះ តែមួយដ៏ពិតប្រាកដ ។ ទោះបីពាក្យនេះជាបទគុណក្ដី ជាកិរិយាសព្ទក្ដី ក៏ប្រើនតែសរសេរ « ប្រយ័ត្ន » នេះដូច្នេះដែរ ។ តែបើគន់នុវត្តឲ្យស្របទៅតាមមូលសព្ទនៃសង្កេតនិយម និងតាមអក្ខរវិរុទ្ធយ្យាករណ៍ ឃើញថាពាក្យទាំងពីរនេះ គួរប្រើជាពីរសណ្ឋាន កាលបើជាកិរិយាសព្ទ ឬគុណនាម ត្រូវសរសេរ « ប្រយ៉ត » នេះ ។ កាលបើជានាមត្រូវសរសេរ « ប្រយ័ត្ន » ដូចនេះ ។

ព្រោះតាមការរែកញែកទៅឃើញថា :

ក – ប្រយ៉ត ដែលសរសេរដូច្នេះ សំពប់ប្រើជាបទគុណ (សំ - ប្រយត: ម - បយត: ) បានសេចក្ដីថា ដែលលាន់, ដែលជំរះ, ដែលសំអាត, ដែលព្យាយាម, ដែលថែទាំ, ដែលប្រុងដោយមិនធ្វេសប្រហែស, . . . . ។



www.angkorvat.fr

ឧទាហរណ៍ : មនុស្សប្រយ័ត, វេលាប្រយ័ត . . . ។

បើប្រើជាកិរិយាសព្ទ បានន័យថា លាង, ជ្រះ, សំអាត, ខំប្រឹង, ប្រុងដោយមិនធ្វេសប្រហែស . . . ។

ឧទាហរណ៍ : ប្រយ័តមិនឲ្យបាត់ ប្រយ័តមាត់ក . . . ។

១ – ប្រយ័ត្ន ដែលសរសេរដូច្នេះ សំរាប់ប្រើជាបទនាម (សំ. ប្រយត្នះ ម. បយតនះ) បានសេចក្ដីថា ការលាង, ការជ្រះ, ការសំអាត, ការព្យាយាម, ការខំប្រឹង, ការប្រុងដោយមិនធ្វេសប្រហែស . . . ។

ឧទាហរណ៍ : ការប្រយ័ត្ន ឬសេចក្ដីប្រយ័ត្ន . . . ។

តែសព្វថ្ងៃយើងនិយមប្រើ « ប្រយ័ត្ន » នេះ ទៅជាកិរិយាទៅវិញ:

ឧទាហរណ៍ : ប្រយ័ត្ន មិនឲ្យធ្លាក់, ប្រយ័ត្នខ្លួន . . . ។

ហេតុនេះ ខ្ញុំសូមស្នើដល់មិត្តទាំងឡាយ ដែលឈ្លាសវៃខាងភាសាសាស្ត្រ-អក្សរសាស្ត្រ និងអក្ខរវេយ្យាករណ៍ មេត្តាជួយធ្វើវិភាគ ចំពោះពាក្យទាំងពីរនេះ តើគួរប្រើរបៀបណា ដើម្បីឲ្យត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ឬមួយក៏ត្រូវប្រើតែ ប្រយ័ត្ន នេះមួយដដែល ទោះពាក្យនេះជានាមក្ដី គុណនាមក្ដី ឬកិរិយាសព្ទក្ដី ។ ហេតុបាន

ជាខ្ញុំស្មើចំពោះពាក្យនេះ ដោយខ្ញុំយល់ឃើញថា ពាក្យបាលីឬសំស្ក្រឹតទាំងឡាយខ្លះដែលមាននាមហើយ មាន ន៍ - ណ៍ - អិ - នៅខាងចុង កាលបើក្លាយទៅគុណនាម ឬកិរិយាសព្ទ រមែងតែងតែលុប ន៍ - ណ៍- អិ - ចេញ ។

| ឧទាហរណ៍ : | នាម : | កិរិយាសព្ទ : |
|---|---|---|
| | អនុវត្តន៍ | អនុវត្ត ....។ |
| | ចរាចរណ៍ | ចរាចរ ...។ |
| | បញ្ញត្តិ | បញ្ញត្ត ....។ |

ខ្ញុំនឹងចាំទទួលនូវការវិភាគ និងយោបល់ដ៏ប្រសើរអំពីសំណាក់អស់លោកដោយរីករាយ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ឆាំង - ទាត់ រៀបរៀង

កម្ពុជសុរិយាលេខ ៣ ខែ មីនា ៦៣

តមក

អត្យារូឍិ (អ័ត-ត្យា-រូ-ឍិ) ស្ត្រី-សេចក្ដីចំរើនក្រៃលែង ។

អត្យារោហ (អ័ត-ត្យា-រ៉ូ-ហៈ) បុំ-កិរិយាឡើងក្រៃលែងឬការដ្អើងខ្ពៃ
សេចក្ដីខ្ពង់ខ្ពស់ ។

អត្យាតិ៌ (អ័ត-ត្យា-ទិន) ស្ត្រី-សេចក្ដីទុក្ខក្រៃលែង ។

អត្យាយំ (អ័ត-ត្យា-យ៉ាំង) គុ-ដែលប្រសើរក្រៃលែង ។

អត្យាឝ (អ័ត-ត្យា-សៈ) បុំ-កិរិយាបរិភោគក្រៃលែង ។

អត្យាឝ្ចយំ (អ័ត-ត្យា-ស្ច-យ៉ាំង) គុ-ដែលអស្ចារ្យក្រៃលែង ។

អត្យាឝ្រមិន (អ័ត-ត្យា-ស្រៈ-ស៊ិន) គុ-ដែលមានអាស្រមក្រៃលែង ។

អត្យាសង្គ (អ័ត-ត្យា-សង់-គៈ) បុំ-កិរិយាជាប់ជំពាក់ក្រៃលែង ។

អត្យាសទ (អ័ត-ត្យា-សទ័) ជាគុ-នៅជិតក្រៃលែង ពោល ។
អត្យាសន្ន គុ- ដែលនៅជិតក្រៃលែង។

អត្យាហិត (អ័ត-ត្យា-ហិ-តៈ) គុ-សេចក្ដីទុក្ខ គ្រោះកាច អំពើមានភ័យ ។

អត្យុក្តិ (អ័ត-ត្យុក-ក្តិ) ស្ត្រី-កិរិយាពោលក្រៃលែង កិរិយាពោលអួតខ្លួន។

អត្យុគ្រ (អ័ត-ទ្យុក-គ្រៈ) គុ- ដែលក្លៀវក្លាដ៏ក្រៃលែង ។

អត្យុច្ច (អ័ត-ទ្យុច-ចៈ) គុ- ដែលខ្ពស់ក្រៃលែង ។

អត្យុច្ចយ (អ័ត-ទ្យុច-ច្ច-យៈ) បុ- កិរិយាឡើងក្រៃលែង កិរិយាកសាង ។

អត្យុច្ចិត (អ័ត-ទ្យុច-ច្ចិ-តៈ) គុ-ដែលខ្ពស់ឡើងក្រៃលែងដែលប្រាថ្នា ។

អត្យុក្កដ (អ័ត-ទ្យុក-ក្កៈ-ដៈ) គុ-ដែលអស្ចារ្យក្រៃលែង ។

អត្យុក្កម្បិន (អ័ត-ទ្យុក-ក្កម័-ប៉ិន) គុ-ដែលញាប់ញ័រក្រៃលែង ។

អត្យុត្ក្រម (អ័ត-ទ្យុត-ក្រ័ម) ធាតុ ទៅខាងក្រៃលែង ប្រសើរ ។

អត្យុត្ក្រាន្ត គុ-ដែលឋិតនៅឆ្ងាយ ។

អត្យុត្រេក (អ័ត-ទ្យុត-ត្រេ-កៈ) បុ-កិរិយាអួតក្រៃលែង ។

អត្យុទាត្ត (អ័ត-ទ្យុ-ទាត-តៈ) គុ-ដែលខ្ពង់ខ្ពស់ក្រៃលែង ដែលប្រសើរលើស ។

អត្យុទារ (អ័ត-ទ្យុ-ទា-រៈ) គុ-ដែលឧត្ដមក្រៃលែង ។ - តា ស្ត្រី ការដែលជនមានសេចក្ដីជ្រះថ្លាក្រៃលែង ។

អត្យុន្នត (អ័ត-ទ្យុន-ណៈ-តៈ) គុ-ដែលខ្ពង់ខ្ពស់ក្រៃលែង ។ - តិ ស្ត្រី - សេចក្ដីខ្ពង់ខ្ពស់ក្រៃលែង ។

នៅមានត



# ការប្រឡង

## ជោគជ័យនៃនិស្សិតរបស់យើង ក្នុងឆ្នាំសិក្សា ១៩៦២-៦៣

ជាពតិមានដល់អ្នកអានទាំងឡាយ ទស្សនាវដ្តី «គ្រូបង្រៀនខ្មែរ» សូមចុះជូននូវលទ្ធផលនៃការប្រឡងផ្សេងៗ ក្នុងមធ្យមសិក្សា ឧត្តមសិក្សា និងបច្ចេកទេសសិក្សា ឆ្នាំ ១៩៦២-៦៣ លទ្ធផលដែលបានមកដោយការប្រឹងប្រែងព្យាយាមនៃយុវជនសិក្សារបស់យើង ក្នុងឆ្នាំដែលទើបនឹងកន្លងផុតទៅនេះ ។

សំគាល់– និស្សិតនៃវិទ្យាស្ថានឧត្តមសិក្សានិងបច្ចេកទេសសិក្សាច្រើនសំរេចនូវជោគជ័យដ៏ជាទីគាប់ចិត្ត ។ ឯក្នុងមធ្យមសិក្សាភាគរយនៃនិស្សិតដែលប្រឡងជាប់ នៅទុនថយនៅឡើយ ហើយគិតសរុប គឺមិនបានលើសពី ២០% នៃនិស្សិតដែលចូលទៅប្រឡង ។

១- មធ្យមសិក្សាជាតិ

| សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ | ចំនួនសិស្សចុះឈ្មោះប្រឡង | ចំនួនសិស្សបានចូលទៅប្រឡង | សិស្សប្រឡងជាប់ | ភាគរយ |
|---|---|---|---|---|
| សម័យប្រឡងលើកទី ១ | ១៣ ៣៩១ | ១២ ៣៨៤ | ២ ៦៥៧ | ២១,៥២ |
| សម័យប្រឡងលើកទី ២ | ៥ ០៩១ | ៥ ០៩១ | ៧៧៩ | ៧៥ |
| បូករួម . . . . | | | ៣ ៤៣៧ | ១៥,២៤ |
| មធ្យមសិក្សាប័ត្រភាគទី ១ | | | | |
| សម័យប្រឡងលើក ទី ១ | ២ ៨៩៨ | ២ ១៤៧ | ៤០០ | ១៨,៦៣ |
| សម័យប្រឡងលើក ទី ២ | ១ ០៧៩ | ១ ០៧៩ | ១៥០ | ១៣,៩០ |
| បូករួម . - - | | | ៥៥០ | |
| មធ្យមសិក្សាប័ត្រភាគទី ២ | | | | |
| សម័យប្រឡងលើកទី ១ | ៥៦៤ | ៤២៥ | ១០១ | ២៣,៧៦ |
| សម័យប្រឡងលើកទី ២ | - - - - - - - - - - - - | - - - - - - - - - - - | ៧៦ | |
| បូករួម - - - - - - | - - - - - - - - - - - - | . . . - - - - - - - - - - - | ១៧៧ | |

## សាលាជាតិសិល្បៈ និងមុខរបរ

| | | | | |
|---|---|---|---|---|
| សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ផ្នែកឧស្សាហកម្ម | ១៣៧ | ១៣៧ | ៨៧ | ៦៣,៥០ |
| មធ្យមសិក្សាប័ត្រភាគទី ១ ផ្នែកបច្ចេកទេស | ៥០ | ៥០ | ២០ | ២០ |

## វិទ្យាស្ថានជាតិគរុកោសល្យ

| | | | | |
|---|---|---|---|---|
| ផ្នែកគ្រូបង្រៀន | ៥៩១ | ៥៨៧ | ៥៦២ | ៩៦,៩៣ |
| ផ្នែកសាស្ត្រាចារ្យ | ១២០ | ១២០ | ១១៤ | ៩៥,០០ |
| ផ្នែកគ្រូបង្រៀនចេញពីកំពង់កន្ទួត | ២៣៦ | ២៣០ | ១៦៣ | ៧០,៨៧ |

## ២ - ឧត្តមសិក្សា

### ១ – មហាវិទ្យាល័យអក្សរសាស្ត្រ

*ផ្នែកអក្សរសាស្ត្រខ្មែរ*

| | | | | |
|---|---|---|---|---|
| សម័យប្រឡងលើកទី ១ | ៣៩ | ២២ | ១៣ | ៥៩,០៩ |
| សម័យប្រឡងលើកទី ២ | ២៧ | ២៧ | ៩ | ៣៣,៣៣ |
| បូករួម | | | ២២ | |
| ផ្នែកអក្សរសាស្ត្របារាំង | | | | |
| សម័យប្រឡងលើកទី ១ | ២៥ | ១៩ | ១០ | ៥២,៦៣ |
| សម័យប្រឡងលើកទី ២ | ១៦ | ១៦ | ៦ | ៣៧,៥០ |
| បូករួម | | | ១៦ | ៣៧,៥០ |

## វិញ្ញាបនប័ត្រឧត្តមសិក្សាខាងអារ្យធម៌អាស៊ី

| | | | | |
|---|---|---|---|---|
| សម័យប្រឡងលើកទី ១ | ៩ | ៨ | ៣ | ៣៧,៥០ |
| សម័យប្រឡងលើកទី ២ | ៦ | ៦ | ២ | ៣៣,៣៣ |
| បូករួម | | | ៥ | |

## វិញ្ញាបនប័ត្រឧត្តមសិក្សា ខាងអក្សរសាស្ត្រខ្មែរ

| | | | | |
|---|---|---|---|---|
| សម័យប្រឡងលើកទី ១ | ៧ | ៧ | ៤ | ៤២,៨៥ |
| សម័យប្រឡងលើកទី ២ | ៤ | ៤ | ១ | ២៥,០០ |
| បូករួម - - - | - - - - - | - - - - - | ៥ | ៣០,?២ |

## វិញ្ញាបនប័ត្រឧត្តមសិក្សាខាងសិល្បៈនិងបុរាណវត្ថុវិជ្ជា

| | | | | |
|---|---|---|---|---|
| សម័យប្រឡងលើកទី ១ | ៥ | ៥ | ៣ | ៦០,០០ |
| សម័យប្រឡងលើកទី ២ | ៣ | ៣ | ១ | ៣៣,៣៣ |
| បូករួម . . . | . . , . - | - - - - | ៤ | ៥០, |

### ២– មហាវិទ្យាល័យច្បាប់

## ផ្នែកសមត្ថភាពច្បាប់

| | | | | |
|---|---|---|---|---|
| ឆ្នាំទី ១ | ៩៧ | ៨៨ | ២២ | ២៥,០០ |
| ឆ្នាំទី ២ | ៦៣ | ៦១ | ៣១ | ៥០,៨១ |
| បូករួម - - - | - - - - | - - - - | ៥៣ | |

## ផ្នែកថ្នាក់បណ្ឌិតខាងច្បាប់

| | | | | |
|---|---|---|---|---|
| ថ្នាក់ទី ១ | ៥៧ | ៥៤ | ៣៤ | ៦៦,៦៦ |
| ថ្នាក់ទី ២ | ៤៤ | ៤៤ | ២៧ | ៦១,៣១ |
| ថ្នាក់ទី ៣ | ១៩ | ១៩ | ១៨ | ៩៤,៧៣ |
| ថ្នាក់ទី ៤ | ២៧ | ២៧ | ២៧ | ១០០.០០ |
| វិញ្ញាបនប័ត្រឧត្តមសិក្សាខាងច្បាប់សាធារណៈ | ៩ | ៦ | ៥ | ៨៣,៣៣ |

## ៣- មហាវិទ្យាល័យវិទ្យាសាស្ត្រ

| | | | | |
|---|---|---|---|---|
| CES de PCB | ៤៤ | ៣៦ | ២២ | ៦១,១១ |
| CES de SPCN | ៥ | ៤ | ១ | ២៥,០០ |
| CES de MPC | ១ | ១ | ១ | ១០០,០០ |
| CES de électricité | ៣ | ២ | ១ | ៥០,០០ |
| CES de Chimie minérale | ៥ | ៤ | ៣ | ៧៥,០០ |

## ៤ – មហាវិទ្យាល័យវិជ្ជាពេទ្យ

## ផ្នែកខាងមន្ទីរសុខាភិបាល

| | | | | |
|---|---|---|---|---|
| ថ្នាក់ទី១ | ៥០ | ៤១ | ១៣ | ៣១,៦៥ |
| ថ្នាក់ទី២ | ២៩ | ២៦ | ១១ | ៤២,៣០ |
| ថ្នាក់ទី៣ | -- | -- | ១៦ | |
| ថ្នាក់ទី៤ | -- | -- | ៩ | |
| ថ្នាក់ទី៥ | | | ១៦ | |

## ផ្នែកខាងវេជ្ជបណ្ឌិតខាងវិជ្ជាពេទ្យ

| | | | | |
|---|---|---|---|---|
| ឆ្នាំទី១ | ៣៧ | ៣៤ | ១១ | ៣២,៣៥ |
| ឆ្នាំទី២ | ១៦ | ១៦ | ១៣ | ៨១,២៥ |
| ឆ្នាំទី៣ | -- | -- | ៦ | |
| ឆ្នាំទី៤ | -- | -- | ១០ | |
| ឆ្នាំទី៥ | -- | -- | ១៥ | |
| ឆ្នាំទី៦ | ១២ | ១២ | ១២ | ១០០,០០ |



# វេទិកាខ្មែរ

## សេចក្ដីស្នើអំពីបញ្ហាសំឡេងព្យញ្ជនៈសំយោគ

ដោយ ប៉ក់ - សាម័យ - ម៉ង់សាណា

ដើម្បីជាពតិមានដល់មិត្តអ្នកអាន ខ្ញុំសូមចុះជូនក្នុងទំព័រនេះ នូវលទ្ធផលនៃការស្រាវជ្រាវរបស់ខ្ញុំក្នុងក្បួនច្បាប់ នៃការឲ្យសំឡេងដល់ព្យញ្ជនសំយោគ ។

ក្បួនច្បាប់នេះជាមតិផ្ទាល់របស់ខ្ញុំដែលជាគ្រូបង្រៀនម្នាក់ ហើយចុះផ្សាយនេះទុកគ្រាន់តែជាការពិចារណារបស់មិត្តអ្នកអានប៉ុណ្ណោះ ។ ខ្ញុំចាំទទួលដោយសោមនស្សនូវយោបល់ ឬមតិពីមិត្ត ។

មុននឹងស្នើ ស្ដីពីព្យញ្ជនៈសំយោគ គប្បីយើងស្គាល់ថា តើអ្វីជាព្យញ្ជនៈសំយោគ ។ អក្ខរៈខ្មែរយើងមួយអង្គៗ ឬមួយសំឡេងៗ មានពីររូប គឺតួមួយ ជើងមួយ ។

ព្យញ្ជនៈសំយោគគឺជាព្យញ្ជនៈ ដែលកើតឡើងដោយការរួមសំឡេងពីរ ឬរូបពីរ គឺព្យញ្ជនៈគ្រួតលើមួយ នឹងព្យញ្ជនៈជើងមួយ ។

ឧទាហរណ៍ ក + ្ប = ក្ប

ខ + ្ញ = ខ្ញ

ក + ្ន = ក្ន

របៀបបង្កើតព្យញ្ជនៈសំយោគមាន៤យ៉ាងគឺ៖ (១)

១ – ពួក អ គ្រួតលើពួក អ អ/អ – ឧ– ក្ត

២ – ពួក អ៊ គ្រួតលើពួក អ៊ អ៊/អ៊ – – គ្ន

៣ – ពួក អ គ្រួតលើពួក អ៊ អ/អ៊ – – ស្គ

៤ – ពួក អ៊ គ្រួតលើពួក អ អ៊/អ – – ល្អ

បើយើងសង្កេតមើលព្យញ្ជនៈទាំង៤ក្រុមនេះទៅ យើងអាចយល់ថាក្នុងក្រុមទី ១ នឹងក្រុមទី ២ ព្យញ្ជនៈគ្រួតលើមានសំឡេងដូចព្យញ្ជនៈជើង ។ ដូច្នេះចំពោះការធ្វើសំឡេង ក៏គ្មានបញ្ហាអ្វីទេ ។ យើងគ្រាន់តែចាំថា ( អ/អ = អ; អ៊/អ៊ = អ៊ ) បើ អ គ្រួតលើ អ បានសំឡេង អ ។ បើ អ៊ គ្រួតលើ អ៊ បានសំឡេង អ៊ ។

ឥឡូវនេះ សូមលើកបញ្ហាសំឡេងព្យញ្ជនៈសំយោគមកជូន ។

(១) បូរាណភាសាថា អ ជាសំឡេងឯក អ៊ ជាសំឡេង គ ។

បញ្ហានេះកើតឡើងនៅពេលដែលយើងសង្កេតមើលក្រុមទី ៣ និងទី ៤ នៃកំណើតរបស់ព្យញ្ជនៈសំយោគ ។ ព្យញ្ជនៈសំយោគនៃក្រុមទី ៣ និងទី ៤ នេះកើតឡើងដោយព្យញ្ជនៈត្រួតលើ និង ព្យញ្ជនៈជើងដែលមានសំឡេងខុសគ្នា ។ ក្រុមទី ៣ មាន ង្អ ។ តើយើងយកសំឡេងព្យញ្ជនៈណាធ្វើជាគោល ។ ត្រង់នេះ សូមជូនព្យញ្ជនៈ ដែលដំរៀបជាក្បួន ជាវគ្គ ។

យើងចាំមាត់សឹងតែគ្រប់គ្នា គឺតាំងពី ក ខ រហូតដល់ ឡ អ យ៉ាងស្ទាត់ន្ទូរ:

ក ខ គ ឃ ង ហៅថា វគ្គ ក

ច ឆ ជ ឈ ញ ហៅថា វគ្គ ច

..........

យ រ ល វ ស ហ ឡ អ ហៅថា សេសវគ្គ

បើយើងគ្រាន់តែស្គាល់វគ្គ យើងមិនអាចនឹងរកក្បួន ដែលឲ្យសំឡេងដល់ព្យញ្ជនៈសំយោគបានឡើយ ។ យើងត្រូវស្គាល់ ហើយរៀបព្យញ្ជនៈទាំងនោះតាមសំឡេងវាទៀត ។

បើគិតពីសំឡេង យើងអាចរៀបពួកចុងវគ្គជាមួយក្រុមហើយ ដែលយើងឲ្យឈ្មោះវាថាជាពួកនាសិកៈ (nasales) ង ញ ណ ន ម ។

សល់ពីពួកបុង្គវគ្គ និងពួកសេសវគ្គ យើងអាចធ្វើមួយពួកដទៃទៀតគឺពួកបិទហាន៍ (occlusives) ដែលមានអក្សរ ក ខ គ ឃ ច ឆ ជ ឈ ដ ឋ ឌ ឍ ត ថ ទ ធ ប ផ ព ភ ។

របៀបមួយទៀត គឺចែកតាម ពមាន ឬ ពគ្មានសញ្ញា ( ˜ ) ( " )

១ – ពួកខ្យល់ អ៊ គ្មានត្រីសព្ទ គឺ គ ឃ ង ជ ឈ ញ ឌ ឍ
ទ ធ ន ព ភ ម យ រ ល វ

២ – ពួកខ្យល់ អ៊ មានត្រីសព្ទ គឺ ប៊ - ស៊ - ហ៊ - អ៊

៣ – ពួកខ្យល់ អ គ្មានមូសិកទន្ត គឺ ក ខ ច ឆ ដ ឋ ណ ត ថ ប ផ
ស ហ ឡ អ

៤ – ពួកខ្យល់ អ មានមូសិកទន្ត គឺ ង៉ ញ៉ ន៉ ម៉ យ៉ រ៉ ល៉ វ៉

ការចែកជាក្រុមតាមសំឡេងតូចធំនេះ តាមសញ្ញា ខាងលើនេះគ្រាន់តែជាជំនួយដល់ការយល់វិញ្ញាន នៃសំឡេងព្យញ្ជនៈសំយោគតែប៉ុណ្ណោះ ហើយដែលយើងនឹងជូនខាងក្រោមនេះ ។

ក្បួនទី ១: ក – ព្យញ្ជនៈសំយោគ ត្រូវយកតាមសំឡេងព្យញ្ជនៈត្រួតលើជាពួក បិទហាន៍ ដែលមានសំឡេងតូច ( អ ) ទោះបីផ្សំនឹងព្យញ្ជនៈជើងដែលជាពួក នាសិកៈ សំឡេងធំ អ៊ ក៏ដោយ ។

១ – ព្យញ្ជនៈសំយោគត្រូវយកតាមសំឡេងតូច ព្យញ្ជនៈត្រួតលើជាពួក បិទហាន់ ដែលមានសំឡេងតូច (អ) ទោះបីផ្សំនឹងព្យញ្ជនៈជើងដែលជាពួកសេសវគ្គ សំឡេងធំ អឺក៏ដោយ ។

ឧទាហរណ៍ :

ក– [អ/អ = អ] ក្ង ច្ង ប្ង ផ្ង ខ្ញ ឆ្ញ ក្ន ខ្ន ឆ្ន ត្ន ប្ន ផ្ន

ក្ម ខ្ម ឆ្ម ត្ម ប្ម

ខ– [អ/អ = អ] ខ្យ ក្រ ប្រ ប្រ ត្រ

ក្វ ខ្វ ឆ្វ ត្វ ប្វ ផ្វ ខ្ល ឆ្ល ត្ល ប្ល

ក្បួនទី ២ – ព្យញ្ជនៈសំយោគត្រូវយកតាមសំឡេងតូច (អ) នៃព្យញ្ជនៈត្រួតលើជាអក្សរ ស (សេសវគ្គ) ទោះបីផ្សំនឹង ព្យញ្ជនៈជើងជាពួកនាសិកៈ ឬ ពួកសេសវគ្គ សំឡេងធំ (អ៊) ក៏ដោយ ។

ឧទាហរណ៍ : [អ/អ = អ] ស្ង ស្ញ ស្ន ស្ម ស្យ ស្រ ស្វ ស្វ

ក្បួនទី ៣ – ព្យញ្ជនៈសំយោគត្រូវយកតាមសំឡេងព្យញ្ជនៈជើងជាពួកបិទហាន់ (អ៊) ។

ឧទាហរណ៍ : [អ/អ = អ៊] ង្គ ប្គ ស្គ ខ្ឃ ខ្ជ ង្ឈ ស្ជ ស្ឈ ខ្ទ ឆ្ទ ប្ទ ស្ទ

សេចក្ដីសង្កេត :

១ – ពួកបិទហាន់តែងមានឥទ្ធិពលលើពួក នាសិកៈ និងសេសវគ្គ ។

២ – ពួកសេសវគ្គមានឥទ្ធិពលលើពួក នាសិកៈ តែប៉ុណ្ណោះ ។

៣ – ពួកនាសិកៈ ត្រូវតែទាញពួកដទៃទៀតទាំងអស់ ។

ពួកនាសិកៈ និងពួកសេសវគ្គ ទាញពួកបិទហាន់ ពីព្រោះ អាចប្រែសំឡេងតាមគេបាន ដោយប្រើសញ្ញាមូសិកទន្ត ។

ង ងា ង៉　　យ ងា យ៉

ញ – ញ៉　　រ – រ៉

ន – ន៉　　ល – ល៉

ម – ម៉　　វ – វ៉

តាមសេចក្ដីសង្កេតខាងលើនេះ យើងអាចសន្និដ្ឋានបានថា របៀបលំអានសព្ទនៃពាក្យខ្លះរមែងធ្វើទៅតាមរបៀប ឬ ក្បួនខាងលើនេះដែរ ។

ឧទាហរណ៍ : សាលា ក្រមា សាសនា

ក្រយា សារុង ស្រាក់ ។ល។

# វាជាអ្វី ?



ចម្លើយ: វារកខោ នឹង អាវរបស់វា.

# ដំណឹងបន្ទាន់ក្រោយបង្អស់

បំពោះចំណោទ *ពាក្យខ្វែង* នេះយើងបាន ចុះពាក្យចម្លើយនៅទស្សនាវដ្ដីលេខ ២ ខែតុលា ១៩៦៣ ត្រង់ទំព័រ ៤៩ ហើយមានសេចក្ដីបរិយាយ ថា ( *ចម្លើយពាក្យខ្វែង* ) ដែលមានចោទ ក្នុងទស្សនាវដ្ដីគ្រូបង្រៀនខ្មែរលេខ ១ ខែ កញ្ញា មុននេះ ។

តែផ្ទុយទៅវិញ ដោយមានការភាន់ច្រឡំ យើងក៏បានយកសំនួរនេះមកចុះ ក្នុងទស្សនាវដ្ដី លេខ ៣ ខែ វិច្ឆិកា គ. ស. ១៩៦៣ នេះវិញ ។

ហេតុនេះសូមអស់មិត្តអ្នកអានទាំងឡាយ បើ បងកំសាន្តសាកល្បងនឹងពាក្យខ្វែងនេះ សូមមើល ចម្លើយនៅទស្សនាវដ្ដីលេខ ២ ។

ទស្សនាវដ្ដី

# មិត្តគ្រូទាំងឡាយ

*ចូរមិត្តសាកល្បងកំសាន្តជាមួយ « ពាក្យខ្វែង » របស់យើង ខាងក្រោមនេះ ដោយប្រើគំនិតត្រិះរិះ រកពាក្យដាក់ឲ្យទាក់ទងគ្នា នៅ គ្រប់បន្ទោះ ។*

ចម្លើយត្រឹមត្រូវរបស់យើង មានចុះផ្សាយជាស្រេចហើយក្នុង ទស្សនាវដ្ដីគ្រូបង្រៀនខ្មែរលេខ ២ ខែតុលា ១៩៦៣ ។

អរគុណមិត្តដែលរកជាមុន

ហត្ថលេខា: ជុំ - សូជី

គ្រូបង្រៀន

ធ្វើការនៅអធិការដ្ឋានបឋមសិក្សាព្រះវិហារ




## បន្ទាត់ផ្ដេក

១– អាហាររាវ ។

២– ប្រដាប់ធ្វើដោយខ្សែ ឬចំរៀកឫស្សី សម្រាប់ដាក់យកសត្វទ្វេបាទ ឬចតុប្បាទ ; បុរសសព្វនាម ជាពាក្យទាប ឥតគួរសម ។

៣– ចំណីបញ្ចោតមច្ឆជាតិ ; ធំ ។

៤– រំជួលចិត្ត ឬក្ដួចបំណង ; បុត្រទី ២៧ នៃគ្រួសារដែលមានបុត្រ ៣៣ នាក់ ។

៥– ឈ្មោះប្រទេសមួយនៅខាងលិចប្រទេសសៀម ; ថ្វាយឬជូន ។

៦– ភ្ជាប់គ្នាឲ្យវែង ; លាបបូកព្រលាំងជ័រឲ្យជិតសាច់ " ទូក ", ។

## បន្ទាត់សំយុងចុះក្រោម

I– ពោលពាក្យមិនពិត ។

II– បើថែម " ទនា ", ខាងក្រោយ បានសេចក្ដីថា ត្រេកអរតាម ឬទទួលគុណ ។

III– ឈ្មោះប្រាសាទថ្មបុរាណមួយ ; លើកដាក់លើចង្កេះ ; ។

IV– កិរិយាធ្វើឲ្យមានខ្យល់ និងផ្ចិត ; ឈ្មោះសំពត់សូត្រមួយយ៉ាង មានរឹមជាក្បាច់ ។

V– របងបោះពីក្នុងទឹក ការពារសត្វទឹកដែលសាហាវ កុំឲ្យចូលបាន ; កូនទី ២៩ ក្នុងបណ្ដាកូន ៣៣ ។

VI– គ្រឿងបរិភោគចំអែតកាយ ។

# ដំណឹងសៀវភៅ

## ចេញថ្មី

*យើងរៀនលេខ* នេះជាឈ្មោះសៀវភៅសិក្សាមួយ ដែលក្រុមគរុកោសល្យទើបនឹងរៀបចំរួច ។ សៀវភៅនេះនឹងមកដល់ដៃលោកគ្រូ - អ្នកគ្រូនឹងដៃសិស្សតូចៗរបស់យើងក្នុងពេលដ៏ខ្លីខាងមុខនេះ ។ សៀវភៅយើងរៀនលេខនេះបានបង្ហាញខ្លួនដល់លោកអ្នកខ្លះ ម្តងរួចហើយកាលនៅជាសំណៅនៅឡើយ ។

# មរណភាព

យើងទើបនឹងបានទទួលដំណឹងដោយសេចក្ដីសោកស្ដាយ នឹងក្រៀមក្រំជាទីបំផុត នូវមរណភាពនៃ:—

–លោក ឆួន-អ៊ុម អត្តលេខ ២៤៤ គ្រូបឋមសិក្សាជាន់ដំបូងដើមខ្សែថ្នាក់លេខ ១ ធ្វើការនៅសាលា ជីពូ ស្វាយរៀង បានអនិច្ចកម្មកាលពីថ្ងៃទី ២៩-៦-៦៣ ។

–លោក គង់-សារ៉ាង់ អត្តលេខ ៤៧៩៣ គ្រូបង្ហាត់វិជ្ជាខ្មែរថ្នាក់លេខ ៥ ធ្វើការនៅសាលា ជ្ញូវ ព្រៃវែង បានអនិច្ចកម្មកាលពីថ្ងៃទី ៥-៧-៦៣ ។

–លោក មៀក-ឬ អត្តលេខ ១៨៤៩ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ២ ធ្វើការនៅសាលារស្មីសោភ័ណ កណ្ដាល បានអនិច្ចកម្មកាលពីថ្ងៃទី ៦-៧-៦៣ ។

–លោក ចន្ទ-ជន អត្តលេខ ៣០២៦ គ្រូបឋមសិក្សាជាន់ដំបូងថ្នាក់លេខ ៣ ធ្វើការនៅសាលា តាគល់ កំពង់ឆ្នាំង បានអនិច្ចកម្មកាលពីថ្ងៃទី ២០-៧-៦៣ ។

ក្រុមទស្សនាវដ្ដីគ្រូបង្រៀនខ្មែរសូមសំដែងសេចក្ដីសោកស្ដាយជាទីបំផុតហើយចូលកាន់មរណសញ្ញាជាមួយគ្រួសារនៃសពទាំងនេះផង ។

(ក្រុមទស្សនាវដ្ដីគ្រូបង្រៀនខ្មែរ)